# ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ



# ឥស្សរជនអមតៈ

www.elibraryofcambodia.org

www.elibraryofcambodia.org

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះរាជអំណោយ
ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

១៩២២-២០១២

# វិញ្ញូជនអមតៈ

**ព្រះបរមនាម (ជាព្រះមហាក្សត្រ)**

ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

ព្រះរាជាណាចក្រកម្ពុជា
16298/14
8/10
បណ្ណាល័យជាតិ

---

**ព្រះបរមនាមកិត្តិយស**

ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ
បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ

National Library of Cambodia



www.elibraryofcambodia.org

www.elibraryofcambodia.org

# អារម្ភកថា

សង្គមរាស្ត្រនិយម ឬភាសាសាមញ្ញហៅថា សង្គមចាស់គឺជាពាក្យដ៏មានប្រជាប្រិយ បំផុត សូម្បីក្នុងការជជែកគ្នាលេងទៅតាមភូមិដាច់ស្រយាលក៏ដោយ នាអំឡុងក្រោយឆ្នាំ១៩៧០មកៗ ហើយតាំងពីកុមារភាពមក ខ្ញុំក៏ដូចជាជនរួមជាតិខ្មែរទូទៅធ្លាប់បានឮការសន្ទនានេះជារឿយៗ មិនដែលដាច់ៗ

ក្រោយមកនៅពេលចម្រើនវ័យឡើង ទើបខ្ញុំបានដឹងថា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ គឺជាស្ថាបនិក និងជាអគ្គមគ្គុទេសក៍ដ៏ឆ្នើមនៃសង្គមមួយដែលគេតែងនឹកដល់ឥតឈប់ឈរៗ គួរឲ្យអនិច្ចាពន់ពេកណាស់ ព្រះអង្គបានយាងចូលទិវង្គតទៅហើយ កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ៗ

បើទោះបីជាព្រះកាយរបស់ព្រះអង្គឃ្លាតទៅឆ្ងាយក៏ដោយក្តី ប៉ុន្តែព្រះគុណូបការៈក្នុងការបំពេញព្រះរាជបូជនីយកិច្ច ការលះបង់ខ្ពស់ប្រកបដោយមហាវីរភាពដ៏ស្មោះស្ម័គ្រ ព្រមជាមួយទឹកព្រះទ័យស្នេហាជាតិដ៏មោះមុត និងព្រះរាជទសពិធរាជធម៌នៃអង្គសម្តេចឪ សម្តេចតា សម្តេចតាទួត បន្តស្ថិតនៅក្នុងក្រអៅបេះដូងខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានឡើយៗ

ដោយមានបំណងចូលរួមរំលែកទុក្ខជាមួយរាជរដ្ឋាភិបាល ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី និងប្រជាជាតិខ្មែរទាំងមូលក្នុងកិច្ចតបស្នងសងគុណចំពោះព្រះមហាគុណូបការៈដ៏ឧត្តុង្គឧត្តមរបស់អង្គសម្តេចព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដីនិងឯកភាពជាតិខ្មែរនៃយើងទាំងអស់គ្នា ខ្ញុំបាទបានផ្តួចផ្តើមគំនិតរួមគ្នាចងក្រងនូវកម្រងអនុស្សាវរីយ៍ស្តីពីការយាងចូលព្រះទិវង្គត ការចូលរួមកាន់ព្រះបរមមរណទុក្ខរាជពិធីថ្វាយព្រះភ្លើង និងមនោសញ្ចេតនាសោកស្តាយអាឡោះអាល័យដ៏ជ្រាលជ្រៅពីសំណាក់ប្រជាជាតិខ្មែរ ក៏ដូចជាពិភពលោកទាំងមូលចំពោះអង្គព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ដើម្បីទុកជាការដឹងគុណ និងចងចាំអស់កាលជាអង្វែងតទៅៗ

សូមប្រជាជាតិខ្មែរ និងពិភពលោកទាំងមូលបន្តទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត និងសេចក្តីចម្រើនជារៀងរហូត៕

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣

**អាង គឹមអៀង**



www.elibraryofcambodia.org

# មាតិកា

| ចំណងជើង | ទំព័រ |
|---|---|
| ព្រះបរមបច្ឆាមរណនាម "ព្រះបរមរតនកោដ្ឋ" | ១១-១៨ |
| ព្រះរាជសារថ្លែងអំណរគុណផ្សេងៗរបស់ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ នៃព្រះរាជាណាចក្រកម្ពុជា និងរបស់ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា | ១៩-៣២ |
| ព្រះរាជពិធីដង្ហែព្រះបរមសពព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញឆ្ពោះទៅកាន់ព្រះបរមរាជវាំង (ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២) | ៣៣-៤២ |
| ការចូលរួមរំលែកព្រះរាជមរណទុក្ខពីសំណាក់សម្តេចព្រះមហាសង្ឃរាជ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី សម្តេចព្រះមហាសង្ឃរាជគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា | ៤៣-៤៦ |
| អារម្មណ៍របស់ឥស្សរជនជាន់ខ្ពស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ សាររំលែកព្រះរាជមរណទុក្ខរបស់ឥស្សរជនជាន់ខ្ពស់នានា និងសកម្មភាពចូលគោរពព្រះបរមសពនៅព្រះបរមរាជវាំង | ៤៧-៥២ |
| សាររំលែកព្រះបរមមរណទុក្ខពីសំណាក់ ឥស្សរជនជាន់ខ្ពស់នានា និងសកម្មភាពចូលគោរពព្រះបរមសពនៅព្រះបរមរាជវាំង | ៥៣-៦៤ |
| សាររំលែកព្រះបរមមរណទុក្ខពីសំណាក់ថ្នាក់ដឹកនាំ និងអតីតថ្នាក់ដឹកនាំបរទេស នានានៅលើពិភពលោក | ៦៥-៧៤ |



www.elibraryofcambodia.org

# មាតិកា

| ចំណងជើង | ទំព័រ |
|---|---|
| សាររំលែកព្រះបរមមរណទុក្ខពីសំណាក់ថ្នាក់ដឹកនាំអង្គការអន្តរជាតិនានា | ៧៥-៨០ |
| សកម្មភាពចូលគោរពព្រះវិញ្ញាណក្ខន្ធ<br>របស់ថ្នាក់ដឹកនាំបរទេស និងអង្គការអន្តរជាតិនានា | ៨១-៨៦ |
| ទស្សនៈរបស់ប្រព័ន្ធផ្សព្វផ្សាយនានាដែលសរសេរជាភាសាខ្មែរ<br>ទាក់ទងនឹងគុណសម្បត្តិរបស់សម្តេចព្រះវររាជបិតាព្រះបាទ ព្រះនរោត្តម សីហនុ | ៨៧-៩២ |
| ទស្សនៈរបស់បណ្តាសារព័ត៌មានអន្តរជាតិនានាបន្ទាប់ពីការយាងចូលទិវង្គត<br>របស់សម្តេចព្រះវររាជបិតាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ | ៩៣-១០៦ |
| ទស្សនៈនានារបស់មហាជនក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា | ១០៧-១៣២ |
| បទសម្ភាសជាមួយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ អតីតលេខាផ្ទាល់<br>របស់សម្តេចព្រះវររាជបិតា ដោយ លោក គី សុខលីម | ១៣៣-១៣៨ |
| វិភាគ ៖<br>ព្រះមហាវីរក្សត្រ និងការងារសង្គម ដោយ លោក ប៉ែន បូណា | ១៣៩-១៤២ |
| អតីតព្រះមហាវីរក្សត្រ និងភាពអច្ឆរិយៈ ដោយ លោក ប៉ែន បូណា | ១៤៣-១៤៦ |
| សំណង់ព្រះបរមមេរុតម្លៃប្រហែល ១,២លានដុល្លារអាមេរិក<br>(ប្រគេន ៖ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន)<br>និងកម្រងរូបភាពផ្សេងៗនៃព្រះរាជពិធីជង្ហែសាកល្បង | ១៤៧-១៦៤ |
| សេចក្តីជូនដំណឹងសារាចរណែនាំ និងព្រះរាជក្រឹត្យផ្សេងៗ<br>ក្រោយការយាងចូលទិវង្គតរបស់ព្រះមហាវីរក្សត្រព្រះវររាជបិតាឯករាជ្យ<br>បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ | ១៦៥-១៧៩ |



www.elibraryofcambodia.org



















www.elibraryofcambodia.org















www.elibraryofcambodia.org





www.elibraryofcambodia.org

ព្រះបរមបច្ឆាមរណនាម

# ព្រះបរមរតនកោដ្ឋ



www.elibraryofcambodia.org





www.elibraryofcambodia.org

ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ព្រះបរមបច្ឆាមរណនាម

## ព្រះបរមរតនកោដ្ឋ

ថ្វាយព្រះបរមសព

ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ
ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ

នរោត្តម សីហមុនី

៣៦ស.០២១១.៩៤៣

**មានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១២*



www.elibraryofcambodia.org

### អង្គប្រជុំ សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះសង្ឃ
### ពិភាក្សាអំពី ព្រះបរម បច្ឆាមរណនាម ថ្វាយ
### ព្រះបរមសព ព្រះករុណាព្រះបរមរាជបិតាជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
### នៅរសៀលថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១២







www.elibraryofcambodia.org







www.elibraryofcambodia.org

ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE

ព្រះបរមរាជវាំង

**សេចក្តីសម្រេច**

របស់អង្គប្រជុំពិភាក្សា អំពីព្រះបរមបច្ឆាមរណនាម ថ្វាយព្រះបរមសព
**ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
នៅលើព្រះទីនាំងកោដជ័យ. ព្រះបរមរាជវាំង

យោងតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជសវនីយ៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅថ្ងៃសៅរ៍ ១១រោច ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១២ វេលាម៉ោង ១៣:០០នាទីរសៀល អង្គប្រជុំដូចមានព្រះនាម-នាមខាងក្រោមនេះ បានពិភាក្សាអំពីព្រះបរមបច្ឆាមរណនាម ថ្វាយ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត បានមូលមតិសំរេចជាឯកច្ឆ័ន្ទ កំណត់យកពាក្យ :

..........ព្រះបរមរតនកោដ្ឋ..........

ជាព្រះបរមបច្ឆាមរណនាម ថ្វាយព្រះបរមសព **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

អង្គប្រជុំសូមក្រាបបង្គំទូលថ្វាយ សូមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ អំពីព្រះបរមបច្ឆាមរណនាមនេះ និងសូមប្រោសព្រះរាជទានព្រះរាជក្រឹត្យ ថ្វាយព្រះបរមសព ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស**
សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី**
សម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត**
សម្តេចព្រះធម្មលិខិត **លាស់ ឡាយ**
សម្តេចព្រះពោធិវង្ស **អំ លឹមហេង**
សម្តេចព្រះវនរ័ត **ណយ ជ្រឹក**
សម្តេចព្រះឧត្តមបញ្ញា **ជួន ធំ**
សម្តេចព្រះឧត្តមវង្សា **មួង រី**
សម្តេចព្រះឧត្តមចរិយា **ឈឹង ប៊ុនឈា**
សម្តេចព្រះមហាអរិយវង្ស **សៅ ចន្ទថុល**

សម្តេចចៅហ្វាវាំង **គង់ សំអុល**
អ្នកឧកញ៉ាកត្តិព្រះស្តេច **ហេង តិមគុណ**
ព្រះជ័យាធិបតី **គង់ កេន**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១២



www.elibraryofcambodia.org

**ព្រះរាជលេខាធិការដ្ឋាន**
**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ**
**នរោត្តម មុនិនាថ សីហនុ**
**នៃកម្ពុជា**

## <u>សេចក្តីជូនដំណឹង</u>

ភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២

ព្រះរាជលេខាធិការដ្ឋាន សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ មានកិត្តិយសសូមថ្វាយ និង ជំរាបសាធារណជនបានជ្រាបថា តាមប្រពៃណីដ៏យូរលង់ តាំងតែពីសម័យអង្គរ រហូតមកដល់បច្ចុប្បន្នកាលនេះ ប្រជាជាតិតែងតែថ្វាយព្រះមហាក្សត្រកម្ពុជាដែលយាងចូលព្រះទីវង្គតនូវព្រះបរមបច្ឆាមរណនាម ដើម្បីថ្វាយព្រះមហាកិត្តិយស និងការគោរពចំពោះព្រះរាជគុណដ៏ខ្ពង់ខ្ពស់ជាទីបំផុតនៃអង្គព្រះមហាក្សត្រ។

ព្រះរាជលេខាធិការដ្ឋាន សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ សូមថ្វាយ និងជូនព្រះបរមបច្ឆាមរណនាមអតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីព្រះករុណា ព្រះបាទសម្តេចព្រះអង្គឌួង ដូចខាងក្រោមនេះ :

១–ព្រះបាទសម្តេចព្រះអង្គឌួង ថ្វាយព្រះបរមបច្ឆាមរណនាម ព្រះករុណា ព្រះបរមកោដ្ឋ
២–ព្រះបាទសម្តេចព្រះនរោត្តម ថ្វាយព្រះបរមបច្ឆាមរណនាម ព្រះករុណា ព្រះសុវណ្ណកោដ្ឋ
៣–ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ថ្វាយព្រះបរមបច្ឆាមរណនាម ព្រះករុណា ព្រះរាជានុកោដ្ឋ
៤–ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស ថ្វាយព្រះបរមបច្ឆាមរណនាម ព្រះករុណា ព្រះបរមខត្តិយកោដ្ឋ
៥–ព្រះបាទសម្តេចព្រះនរោត្តម ព្រះសុរាម្រិត ថ្វាយព្រះបរមបច្ឆាមរណនាម ព្រះករុណា ព្រះមហាកញ្ញនកោដ្ឋ

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** បានថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** នូវព្រះបរមបច្ឆាមរណនាម **ព្រះករុណា ព្រះបរមរតនកោដ្ឋ** ។

សូមអរព្រះគុណ អរគុណជាអនេកប្បការ



www.elibraryofcambodia.org

www.elibraryofcambodia.org

ព្រះរាជសារថ្លែងអំណរគុណផ្សេងៗរបស់
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា
នរោត្តម មុនិនាថ សីហនុ
នៃព្រះរាជាណាចក្រកម្ពុជា

និងរបស់ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ
នរោត្តម សីហមុនី ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា


www.elibraryofcambodia.org

www.elibraryofcambodia.org

**សម្ដេចព្រះមហាក្សត្រ នរោត្តម សីហមុនី**
**ព្រះបរមរាជសារជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល**
**នៃព្រះរាជាណាចក្រកម្ពុជា**

ភ្នំពេញ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១២

សូមក្រាបថ្វាយបង្គំសម្ដេចព្រះសង្ឃរាជទាំងពីរគណៈជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
សូមគោរពសម្ដេច បងប្អូន ជនរួមជាតិ ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត

ក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះមហាក្សត្រ ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំសូមសំដែងនូវអំណរព្រះរាជគុណ អំណរព្រះគុណ និងអំណរគុណដ៏ជ្រាលជ្រៅជាទីបំផុតថ្វាយសម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ប្រគេនព្រះថេរានុត្ថេរៈគ្រប់ៗព្រះអង្គ ជូនសម្ដេច បងប្អូនជនរួមជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលបានសំដែងនូវមនោសញ្ចេតនា សមានចិត្តស្រណោះ អាឡោះអាល័យ ស្រឡាញ់ដ៏ជ្រាលជ្រៅថ្វាយសម្ដេចឪ សម្ដេចតា សម្ដេចតាទួត ដែលស្ដេចយាងចូលព្រះទិវង្គត។

ព្រះសង្ឃ ប្រជារាស្ត្រកម្ពុជាទូទាំងព្រះរាជាណាចក្រ បាននិមន្ត អញ្ជើញមកពីគ្រប់ទិសទី ជួបជុំគ្នាតាំងពីព្រលានយន្តហោះអន្តរជាតិភ្នំពេញ រហូតដល់ព្រះបរមរាជវាំង ដើម្បីថ្វាយការគោរពចំពោះព្រះបរមសព និងនៅថ្ងៃបន្តបន្ទាប់ ក្រោមកំដៅថ្ងៃ ហាលភ្លៀង ហាលខ្យល់ អញ្ជើញមកអុជធូប ថ្វាយកម្រងផ្កា ដើម្បីសំដែងនូវក្ដីក្រៀមក្រំជាពន់ពេក កាន់មរណទុក្ខ នឹកស្រណោះអាឡោះអាល័យសម្ដេចឪ សម្ដេចតា សម្ដេចតាទួតដែលមានគុណូបការគុណដ៏ធំធេង ក្នុងព្រះរាជបេសកកម្មបំរើប្រជាជាតិ មាតុភូមិ សាសនា និងប្រជារាស្ត្រកម្ពុជា។ មនោសញ្ចេតនាគោរពស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុតនៃព្រះសង្ឃ ប្រជារាស្ត្រចាស់ក្មេង ទាំងបុរស ទាំងស្ត្រីអញ្ជើញមកពីគ្រប់ទិសទី បាននាំឱ្យព្រះករុណា ព្រះមហាក្សត្រ និងខ្ញុំមានហឫទ័យរំជួលក្ដុកក្ដួលរំភើបជាពន់ពេក។ នេះជាកម្លាំងចិត្តធ្វើឱ្យយើងខ្ញុំទាំងពីរ មានហឫទ័យបន្តរួមរស់ជាមួយព្រះសង្ឃ និងប្រជារាស្ត្រទាំងអស់ជាទីស្នេហាដ៏ជ្រាលជ្រៅបំផុតនៃយើងខ្ញុំ ដើម្បីបន្តបំរើឧត្ដមប្រយោជន៍ប្រជាជាតិ សាសនា និងជនរួមជាតិលុះអវសាន្ត។

នរោត្តម សីហមុនី



www.elibraryofcambodia.org

ក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះមហាក្សត្រ ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ សូមសំដែងនូវអំណរគុណ និងកតវេទិតាដ៏ជ្រាលជ្រៅជាទីបំផុត ជូនសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាល ដែលបានរៀបចំដោះស្រាយ សំរួលគ្រប់កិច្ចការ បានឆាប់រហ័ស ថ្វាយព្រះបរមសពព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ ឱ្យសក្តិសមនឹងព្រះកិត្តិនាម ព្រះកិត្តិយសរបស់ព្រះអង្គ។

នៅក្នុងឱកាសដ៏ល្អប្រសើរនេះ ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ សូមទូលថ្វាយ ប្រគេន ជំរាបជូនជ្រាបថា លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិតចិនដ៏ចំណានៗលោកបានខិតខំថែរក្សាព្រះរាជសុខភាពសម្តេចឪ សម្តេចតា សម្តេចតាទួត ៤២ឆ្នាំហើយៗទទួលបានជោគជ័យធំៗជាច្រើនលើកមកហើយ ក្នុងការព្យាបាលព្រះរោគរបស់ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ។ ថ្នាក់ដឹកនាំ រដ្ឋាភិបាល ប្រជាជនចិន លោកយកហឫទ័យទុកដាក់ជាទីបំផុត ចំពោះព្រះរាជសុខភាពរបស់ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ ហើយខិតខំធ្វើយ៉ាងណាថ្វាយសម្តេចឪ សម្តេចតា សម្តេចតាទួត មានព្រះជន្មាយុយឺនយូរ។ ព្រះរាជវត្តមាន និងព្រះរាជសុខភាពរបស់ព្រះអង្គមានសារៈសំខាន់ណាស់ចំពោះប្រទេសចិន។

លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិតចិនដ៏ចំណានៗលោកបានឱ្យខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ បានដឹង២ឆ្នាំហើយថា សម្តេចឪ សម្តេចតា សម្តេចតាទួតប្រឈួនព្រះហទយៈ(បេះដូង) ដែលមានសភាពធ្ងន់ធ្ងរ តែលោកខេះតែខិតខំថែរក្សាព្យាបាលព្រះរោគដោយយកចិត្តទុកដាក់ជាទីបំផុត។

នៅក្នុងរយៈប៉ុន្មានខែក្រោយនេះ សម្តេចឪ សម្តេចតា សម្តេចតាទួត សោយមិនសូវបាន ផ្ទុំក៏មិនបាន តែព្រះអង្គគង់ស្ងប់ស្ងៀម មិនសូវមានព្រះរាជនិន្ទារ។ ជារៀងរាល់ថ្ងៃព្រះអង្គតែងតែថ្វាយបង្គំព្រះ។

នៅបីអាទិត្យមុនព្រះអង្គយាងចូលព្រះទីវង្គត ព្រះអង្គចាប់ផ្តើមមានអាការៈមិនស្រួល។ លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិតចិនដ៏ចំណានៗបានតាមដានជាប់រហូត និងខិតខំរិះរកវិធីគ្រប់បែបយ៉ាង ថែទាំព្យាបាល តាមដានព្រះរាជសុខភាពយ៉ាងល្អិតល្អន់។ នៅយប់ថ្ងៃទី១៤ ខែតុលា ព្រះអង្គចាប់ផុតនិរាព្រះហទយៈ(បេះដូង) ហើយខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ និងកូនចៅអ្នកបម្រើនៅប៉េកាំង បានតាមដង្ហែព្រះអង្គយាងទៅមន្ទីរពេទ្យប៉េកាំងជាបន្ទាន់។ នៅក្នុងមន្ទីរពេទ្យ ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ បានទូរស័ព្ទថ្វាយព្រះករុណា ព្រះមហាក្សត្រ ដើម្បីជ្រាបអំពីអាការៈព្រះរោគព្រះវររាជបិតា ហើយបានយកទូរស័ព្ទនេះទៅថ្វាយព្រះករុណា ព្រះវររាជបិតាជាតិខ្មែរព្រះសណ្តាប់។ ព្រះអង្គញញឹម និងមានព្រះនិន្ទារពីរ បីព្រះឱស្ឋដោយព្រះអង្គប្រឈួន





www.elibraryofcambodia.org

ខ្លាំង។ នេះជាលើកចុងក្រោយនៃព្រះជន្មសម្ដេចឪ សម្ដេចតា សម្ដេចតាទួត ដែលមានព្រះរាជនិង្គាតាមទូរស័ព្ទជាមួយរាជបុត្រ គឺព្រះករុណា ព្រះមហាក្សត្រកម្ពុជានៃយើង។ ក្នុងមួយព្រះជន្មរបស់ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ ព្រះអង្គមិនសព្វព្រះរាជហឫទ័យមានទំនាក់ទំនង ព្រះរាជនិង្គារតាមទូរស័ព្ទជាមួយអ្នកណាម្នាក់ឡើយ។

លោកសាស្ត្រាចារ្យ វេជ្ជបណ្ឌិតចិនដ៏ចំណានៗអញ្ជើញមកពីគ្រប់មន្ទីរពេទ្យ បានមកជួយសង្គ្រោះសម្ដេចឪ ដោយអស់ពីសមត្ថភាព កម្លាំងចិត្ត កម្លាំងកាយ និងបច្ចេកទេសដ៏ប៉ិនប្រសព្វ។

ក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះមហាក្សត្រ ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរគុណ និងកតវេទិតាដ៏ជ្រាលជ្រៅជាថ្មីម្ដងទៀត ជូនថ្នាក់ដឹកនាំ រដ្ឋាភិបាលនៃសាធារណរដ្ឋ ប្រជាមានិតចិនដ៏រុងរឿងដែលជាមហាមិត្តដ៏ល្អ និងស្មោះត្រង់ឥតងាករេរបស់សម្ដេចឪ សម្ដេចតា សម្ដេចតាទួត តាំងពីឆ្នាំ១៩៥៥ និងជារៀងរហូតមកដល់បច្ចុប្បន្នកាលនេះ បានផ្ដល់នូវការគាំទ្រទាំងផ្លូវចិត្ត ទាំងផ្លូវកាយ និងសម្ភារៈគ្រប់បែបយ៉ាង ថ្វាយសម្ដេចឪ សម្ដេចតា សម្ដេចតាទួត ដើម្បីបុព្វហេតុជាតិ មាតុភូមិ។

ក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះមហាក្សត្រ ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងជាថ្មីម្ដងទៀត នូវអំណរព្រះរាជគុណ អំណរព្រះគុណ អំណរគុណ និងកតវេទិតាដ៏ជ្រាលជ្រៅជាទីបំផុត ថ្វាយសម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុថេរៈគ្រប់ៗព្រះអង្គ ជនរួមជាតិជាទីស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត រាជរដ្ឋាភិបាល គ្រប់ស្ថាប័នទាំងអស់ដែលបានថ្វាយនូវការរំលែកទុក្ខ និងការគោរព សូមឱ្យព្រះវិញ្ញាណក្ខ័ន្ធព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ យាងចូលព្រះសុគតិភព ព្រះបរមនិព្វាន ។

ក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះមហាក្សត្រ ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយព្រះពរព្រះសង្ឃគ្រប់ៗព្រះអង្គ ជូនពរសម្ដេច ជនរួមជាតិទាំងអស់ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត សូមបានប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរព្រះរាជគុណ អរព្រះគុណ និងអរគុណ

នមុនិនាថ សីហនុ



www.elibraryofcambodia.org

ព្រះករុណាព្រះបាទសម្តេច
ព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
និង
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា
នរោត្តម មុនិនាថ សីហនុ
នៃព្រះរាជាណាចក្រកម្ពុជា

ជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សម្តេចអគ្គមហាសេនាបតីតេជោជាទីរាប់អានដ៏ខ្ពង់ខ្ពស់បំផុត និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត

យើងខ្ញុំមានមហាកិត្តិយសសូមសំដែងនូវអំណរគុណ និងកតវេទិតាដ៏ជ្រាលជ្រៅជាទីបំផុត ជូនសម្តេចអគ្គមហាសេនាបតីតេជោ ដែលមានមហាបូជ័យដ៏សប្បុរសជាទីបំផុត ក្នុងការអញ្ជើញទៅកាន់រដ្ឋធានីប៉េកាំង ដង្ហែព្រះបរមសពព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ យាងមកកាន់រាជធានីភ្នំពេញ និងណែនាំចាត់ចែងការយ៉ាងល្អិតល្អន់គ្រប់ជ្រុងជ្រោយ ដោះស្រាយសម្រួលគ្រប់កិច្ចការបានឆាប់រហ័ស ថ្វាយព្រះបរមសពព្រះករុណា ព្រះវររាជបិតាជាតិខ្មែរបានសក្តិសមតឹងព្រះកិត្តិយស ព្រះកិត្តិនាមជាព្រះមហាវីរក្សត្រនៃប្រជាជាតិ ប្រជារាស្ត្រកម្ពុជា។

ពាក្យពេចន៍សច្ចាប្រណិធានដែលសម្តេចអគ្គមហាសេនាបតីតេជោ បានថ្លែងជាឧឡារិកនៅចំពោះមុខព្រះបរមសព នាំឱ្យមហាបូជ័យរបស់យើងខ្ញុំរំជួលក្តុកក្តួលឥតឧបមា ហើយជាកម្លាំងចិត្តចំពោះយើងខ្ញុំ នៅក្នុងឱកាសដ៏មហាសែនក្រៀមក្រំ ពោរពេញទៅដោយមហាទុក្ខប៉ុនភ្នំព្រះសុមេរុ។

យើងខ្ញុំចងចាំជាដរាបនូវគុណូបការគុណដ៏ធំធេងនៃសម្តេចអគ្គមហាសេនាបតីតេជោ និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ដែលបានអញ្ជើញទៅកាន់រដ្ឋធានីប៉េកាំង យាងព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ មាតុភូមិនិវត្តន៍មកកាន់មាតុ


www.elibraryofcambodia.org

ប្រទេស នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ ហើយបានថ្វាយព្រះអង្គនូវព្រះឋានៈជាប្រមុខរដ្ឋនៃកម្ពុជា។ មហាជាតិ ក្រោយពី នៃព្រះរាជាណាចក្រកម្ពុជា បានបដិសន្ធិឡើងវិញនៅលើទឹកដីអង្គរដ៏បវររុងរឿង។ ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា បានថ្វាយយុត្តិធម៌ដល់ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ ក្នុងការបំរើប្រជាជាតិ មាតុភូមិ ប្រជារាស្ត្រកម្ពុជា និងពុទ្ធសង្គមរាស្ត្រនិយម។

សម្តេចអគ្គមហាសេនាបតីតេជោ និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត បានសំដែងនូវមនោសញ្ចេតនាដ៏ជ្រាលជ្រៅ បានចូលរួមប្រារព្ធពិធីបុណ្យឧទ្ទិសថ្វាយព្រះវិញ្ញាណក្ខន្ធព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ នៅក្នុងឱកាសថ្ងៃខួបចំរើនព្រះជន្មាយុគំរប់៩០ព្រះវស្សា នៅថ្ងៃទី៣០-៣១ ខែតុលា ឆ្នាំ២០១២ ដែលមានសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ និងព្រះសង្ឃចំនួនសរុប ៩២អង្គ។

ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ តែងសំដែងនូវការកោតសរសើរដ៏កក់ក្តៅជាទីបំផុត ចំពោះសម្តេចអគ្គមហាសេនាបតីតេជោ អ្នកដឹកនាំជាតិដ៏ឈ្លាសវៃ ប៉ិនប្រសព្វ ក្នុងការបំរើប្រជាជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។ សមិទ្ធផលដ៏ច្រើនសន្ធឹកសន្ធាប់ ពាសពេញព្រះរាជាណាចក្រកម្ពុជា គឺជាសក្ខីកម្មជាប្រវត្តិសាស្ត្រនៃការបំពេញបេសកកម្មដ៏ឧត្តុងឧត្តមរបស់សម្តេចអគ្គមហាសេនាបតីតេជោ ដើម្បីជាឧត្តមប្រយោជន៍ប្រជាជាតិ និងប្រជារាស្ត្រកម្ពុជា។

យើងខ្ញុំសូមប្រសិទ្ធិពរជ័យបវរ សូមសម្តេចអគ្គមហាសេនាបតីតេជោ និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ទទួលបាននូវមហាជោគជ័យធំៗជាដរាប ព្រមទាំងបានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមសម្តេចអគ្គមហាសេនាបតីតេជោ និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់បំផុត និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត អំពីយើងខ្ញុំ។

នរោត្តម សីហមុនី | នរោត្តម មុនិនាថ សីហនុ

ភ្នំពេញ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១២



www.elibraryofcambodia.org

ព្រះករុណាព្រះបាទសម្តេច
ព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
និង
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា
នរោត្តម មុនិនាថ សីហនុ
នៃព្រះរាជាណាចក្រកម្ពុជា

ជូន

ឯកឧត្តម Hu Jintao
ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រជាមានិតចិន

ឯកឧត្តមលោកប្រធានាធិបតីជាទីគោរព និងរាប់អានដ៏ខ្ពង់ខ្ពស់បំផុត

យើងខ្ញុំមានមហាកិត្តិយស និងហឫទ័យរំភើបពន់ពេកណាស់ សូមសំដែងនូវអំណរព្រះគុណ និងកតវេទិតាដ៏ជ្រាលជ្រៅជាទីបំផុត ជូនឯកឧត្តមលោកប្រធានាធិបតី ចំពោះកាយវិការ មនោសញ្ចេតនាដ៏មហាសប្បុរសគ្មានអ្វីប្រៀបផ្ទឹមបាន និងមហាមិត្តភាពជាទីបំផុតនៃរដ្ឋាភិបាល បក្សកុម្មុយនិស្ត ប្រជាជនចិនដ៏មហិមានៃមហាប្រទេសចិនដ៏រុងរឿងថ្កើងថ្កាន។ ឯកឧត្តមលោកប្រធានាធិបតីផ្ទាល់ ឯកឧត្តមអនុប្រធានាធិបតី ឯកឧត្តមនាយករដ្ឋមន្ត្រី ថ្នាក់ដឹកនាំជាន់ខ្ពស់នៃសាធារណរដ្ឋ ប្រជាមានិតចិន បានអញ្ជើញមកគោរពព្រះបរមសពព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ ផ្ញើសារលិខិតរំលែកទុក្ខយើងខ្ញុំ ទម្លាក់ទង់ជាតិចិនចូលរួមកាន់មរណទុក្ខជាមួយប្រជាជាតិ ប្រជាជនកម្ពុជាក្នុងឱកាសដ៏មហាសែនក្រៀមក្រំនេះ ព្រមទាំងផ្តល់នូវព្រះទីនាំងយន្តហោះ Boeing 747 ដ៏ធំមួយ ដោយមានឥស្សរជនជាន់ខ្ពស់ តំណាងរដ្ឋាភិបាល អ្នកបច្ចេកទេសផ្នែកមន្ទីរពេទ្យប៉េកាំងនៃសាធារណរដ្ឋ ប្រជាមានិតចិន រួមដង្ហែព្រះបរមសពពីរដ្ឋធានីប៉េកាំងមកកាន់រាជធានីភ្នំពេញ ឱ្យសក្តិសមនឹងព្រះកិត្តិយស ព្រះកិត្តិនាមព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ។

យើងខ្ញុំចងចាំជានិច្ចនូវគុណូបការគុណដ៏ធំធេងនៃសាធារណរដ្ឋ ប្រជាមានិតចិនដ៏រុងរឿងថ្កើងថ្កាន ដែលលោកតែងតែផ្តល់នូវការគាំទ្រ ទំនុកបំរុងជាដរាប និងឧបត្ថម្ភគ្រប់បែបយ៉ាង ប្រកបដោយក្តីសប្បុរស


www.elibraryofcambodia.org

ធម៌គ្មានអ្វីប្រៀបផ្ទឹមបាន ថ្វាយព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ ដើម្បីព្រះអង្គបំពេញព្រះរាជបេសកកម្មជាប្រវត្តិសាស្ត្រជូនប្រជាជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។

ថ្នាក់ដឹកនាំគ្រប់ជំនាន់ រដ្ឋាភិបាលនៃសាធារណរដ្ឋ ប្រជាមានិតចិន បានពង្រឹង និងពង្រីក រក្សាយ៉ាងខ្ជាប់ខ្ជួនឥតងាករេនូវចំណងមិត្តភាព មេត្រីភាពជាភាតរៈរវាងប្រជាជាតិ និងប្រជាជនយើងទាំងពីរ ដែលបានបដិសន្ធិនៅសន្និសីទ Bandung នាឆ្នាំ១៩៥៥ រវាងព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ និងឯកឧត្តមនាយករដ្ឋមន្ត្រី ជូ អេន ឡាយ។

ឯកឧត្តមសាស្ត្រាចារ្យ លោកវេជ្ជបណ្ឌិតជំនាញៗនៃសាធារណរដ្ឋ ប្រជាមានិតចិន លោកបានថែរក្សាជួយពិនិត្យព្យាបាលព្រះសុខភាពព្រះករុណា ព្រះវររាជបិតាជាតិខ្មែរចំនួន៤២ឆ្នាំមក ហើយដោយអស់ពីដួងហឫទ័យ និងអស់ពីសមត្ថភាព ហើយទទួលបានជោគជ័យដ៏ធំៗជាច្រើនលើក ដើម្បីព្រះអង្គមានព្រះសុខភាពល្អបរិបូរណ៍ បំរើប្រជាជាតិ មាតុភូមិ និងប្រជាជនកម្ពុជា។ ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ បានចាត់ទុកសាធារណរដ្ឋ ប្រជាមានិតចិនជាមិត្តដ៏ល្អ ដ៏ស្មោះត្រង់ ឥតកែប្រែ និងជាមាតុភូមិទី២ របស់ព្រះអង្គ។

ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ និងយើងខ្ញុំ ពេញហឫទ័យជាពន់ពេកចំពោះចំណងមិត្តភាពជាភាតរៈ និងកិច្ចសហប្រតិបត្តិរវាងកម្ពុជា–ចិន ដែលមានការរីកចំរើន រឹងប៉ឹង ស្អិតស្មិទ្ធចិរកាលតរៀងទៅ ប្រៀបបានដូចទន្លេឡានឆាន និងទន្លេមេគង្គ ដែលហូរទៅមុខរហូត មិនឈប់ឈរឡើយ។

យើងខ្ញុំសូមជូនពរដ៏ល្អបវរ សូមឯកឧត្តមលោកប្រធានាធិបតី បានប្រកបតែនឹងសុភមង្គល សុខភាពល្អបរិបូរណ៍ អាយុយឺនយូរជាដរាប។

ជយោមហាមិត្តភាពជាអមតៈ និងភាតរៈរវាងប្រជាជាតិ និងប្រជាជនយើងទាំងពីរ !

សូមឯកឧត្តម លោកប្រធានាធិបតី ព្រះមេត្តាទទួលនូវសេចក្តីគោរពស្រឡាញ់ និងរាប់អានដ៏ខ្ពង់ខ្ពស់បំផុត អំពីយើងខ្ញុំ។

នរោត្តម សីហមុនី

នរោត្តម នុរោត្តម មុនិនាថ សីហនុ

ភ្នំពេញ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២



www.elibraryofcambodia.org

ព្រះករុណាព្រះបាទសម្តេច
ព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
និង
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា
នរោត្តម មុនិនាថ សីហនុ
នៃព្រះរាជាណាចក្រកម្ពុជា

ជូន ឯកឧត្តម Lin Jia Bin
នាយកមន្ទីរពេទ្យប៉េកាំង
នៃសាធារណរដ្ឋ ប្រជាមានិតចិន

ឯកឧត្តមជាទីរាប់អានដ៏ខ្ពង់ខ្ពស់

យើងខ្ញុំមានកិត្តិយស សូមសំដែងនូវអំណរគុណ និងកតវេទិតាដ៏ជ្រាលជ្រៅជាទីបំផុត ជូនឯកឧត្តមនាយកទាំងអស់ ឯកឧត្តមសាស្ត្រាចារ្យ លោកវេជ្ជបណ្ឌិត គិលានុបដ្ឋាក គិលានុបដ្ឋាយិកាទាំងអស់នៃមន្ទីរពេទ្យប៉េកាំង ដែលមានមនោសញ្ចេតនាដ៏ជ្រាលជ្រៅ ហប្ញទ័យដ៏សប្បុរស និងមហាមិត្តភាពជាទីបំផុតថ្វាយព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ។

ក្រោមការណែនាំរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋ ប្រជាមានិតចិន ឯកឧត្តមនាយកទាំងអស់ ឯកឧត្តមសាស្ត្រាចារ្យ លោកវេជ្ជបណ្ឌិតដ៏ចំណានៗ លោកបានថែរក្សាជួយពិនិត្យព្យាបាលព្រះសុខភាព ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរចំនួន៤២ឆ្នាំមកហើយ ដោយអស់ពីដួងហប្ញទ័យ និងអស់ពីសមត្ថភាព ហើយទទួលបានជោគជ័យដ៏ធំៗជាច្រើនលើក ដើម្បីព្រះអង្គមានព្រះសុខភាពល្អបរិបូរណ៍ បំរើប្រជាជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។ ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ បានចាត់ទុកសាធារណរដ្ឋ ប្រជាមានិតចិនជាមិត្តដ៏ល្អ ដ៏ស្មោះត្រង់ ឥតកែប្រែ និងជាមាតុភូមិទី២របស់ព្រះអង្គ។


www.elibraryofcambodia.org

ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ មានព្រះជន្មាយុ៩០ព្រះវស្សា ដោយសារគុណបំណាច់ដ៏ធំធេងនៃឯកឧត្តមនាយកទាំងអស់ ឯកឧត្តមសាស្ត្រាចារ្យ លោកវេជ្ជបណ្ឌិតដ៏ចំណានៗ អនុវត្តន៍អនុសាសន៍ពីថ្នាក់ដឹកនាំយ៉ាងហ្មត់ចត់ និងទទួលខុសត្រូវខ្ពស់ បានតាមដានយ៉ាងល្អិតល្អន់ជាទៀងរាល់ថ្ងៃ រាល់ខែ រាល់ឆ្នាំ នូវព្រះសុខភាពតាមវិធីសាស្ត្របច្ចេកវិទ្យាទំនើប ទាំងសម័យ និងបុរាណប្រកបដោយទេពកោសល្យខ្ពង់ខ្ពស់ រួមផ្សំជាមួយនឹងឱសថបុរាណ ទទួលបានជោគជ័យដ៏ធំធេងក្នុងការព្យាបាលព្រះរោគធំៗរបស់ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ។

ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ រមែងរំលឹកអំពីគុណបំណាច់ដ៏ធំធេងរបស់ឯកឧត្តមនាយកទាំងអស់ ឯកឧត្តមសាស្ត្រាចារ្យ លោកវេជ្ជបណ្ឌិតចិនដ៏ចំណានៗ ដែលបានថែទាំព្រះសុខភាពព្រះអង្គបានល្អបរិបូរណ៍ ដើម្បីបំរើឧត្តមប្រយោជន៍ប្រជាជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។

យើងខ្ញុំចងចាំជាដរាបនូវគុណូបការគុណដ៏ធំធេងខាងលើនៃឯកឧត្តមនាយកទាំងអស់ ឯកឧត្តមសាស្ត្រាចារ្យ លោកវេជ្ជបណ្ឌិត គិលានុបដ្ឋាក គិលានុបដ្ឋាយិកានៃមន្ទីរពេទ្យបេកាំង។

នៅក្នុងមនោសញ្ចេតនាគោរព ស្រឡាញ់ដ៏ជ្រាលជ្រៅ និងមហាមិត្តភាពជាទីបំផុត យើងខ្ញុំសូមជូនពរឯកឧត្តមនាយកទាំងអស់ ឯកឧត្តមសាស្ត្រាចារ្យ លោកវេជ្ជបណ្ឌិត គិលានុបដ្ឋាក គិលានុបដ្ឋាយិកានៃមន្ទីរពេទ្យបេកាំង សូមមានសុខភាពល្អបរិបូរណ៍ អាយុយឺនយូរជាដរាប ព្រមទាំងទទួលបានជោគជ័យក្នុងការកិច្ចបំរើប្រជាជាតិ ប្រជាជនចិន។

សូមឯកឧត្តម ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ។

នរោត្តម សីហមុនី　　　　នរោត្តម មុនិនាថ សីហនុ

ភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២



www.elibraryofcambodia.org

**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា**
**នរោត្តម មុនិនាថ សីហនុ**
**នៃព្រះរាជាណាចក្រកម្ពុជា**

ជូន សម្តេចចៅហ្វាវាំង គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

សម្តេចចៅហ្វាវាំងជាទីរាប់អានដ៏ខ្ពង់ខ្ពស់

ខ្ញុំសូមសំដែងនូវអំណរគុណ និងកតវេទិតាដ៏ជ្រាលជ្រៅជាទីបំផុត ជូនសម្តេចចៅហ្វាវាំង ដែលបានផ្តល់ពត៌មានយ៉ាងឆាប់រហ័សជាទីបំផុត ជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំឱ្យបានទាន់ពេលវេលាថ្វាយព្រះករុណា ព្រះមហាក្សត្រ យាងទៅកាន់រដ្ឋធានីប៉េកាំង និងណែនាំចាត់ចែងការយ៉ាងល្អិតល្អន់ គ្រប់ជ្រុងជ្រោយ ថ្វាយព្រះបរមសពព្រះករុណា ព្រះវររាជបិតាជាតិខ្មែរបានសក្តិសមនឹងព្រះកិត្តិយស ព្រះកិត្តិនាមជាព្រះមហាវីរក្សត្រនៃប្រជាជាតិ ប្រជារាស្ត្រកម្ពុជា។

ខ្ញុំសូមសរសើរដ៏កក់ក្តៅជាទីបំផុតសម្តេចចៅហ្វាវាំង សហការី សហការិនី បុគ្គលិក កម្មករ ព្រមទាំងកងកម្លាំងនគរបាលការពារព្រះបរមរាជវាំងដែលមានស្មារតីទទួលខុសត្រូវខ្ពស់ បច្ចេកទេសទំនើប ក្នុងការរៀបចំតុបតែងថ្វាយព្រះបរមសពព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ គង់ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យបានយ៉ាងល្អឥតខ្ចោះ។

សម្តេចចៅហ្វាវាំងបានរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្មាយុ៩០ព្រះវស្សានៃអង្គសម្តេចឪ ព្រះរាជពិធីបុណ្យព្រះពុទ្ធសាសនាប្រារព្ធជារៀងរាល់ថ្ងៃដែលប្រព្រឹត្តទៅបានយ៉ាងល្អប្រពៃណាស់–កម្មវិធីគោរពព្រះបរមសព សំរាប់គណៈប្រតិភូជាន់ខ្ពស់ជាតិ និងអន្តរជាតិ អង្គការមហាជន សមាគម ប្រជារាស្ត្រ ។ល។ បន្ថែមពីលើនេះនៅមុខព្រះបរមរាជវាំងក៏មានការរៀបចំទីកន្លែងបានយ៉ាងសមរម្យ មានសុវត្ថិភាព សណ្តាប់ធ្នាប់សំរាប់ព្រះសង្ឃរាប់ពាន់អង្គ ប្រជារាស្ត្រកម្ពុជា ជនជាតិបរទេសដែលគោរពស្រឡាញ់ ស្រណោះអាឡោះអាល័យសម្តេចឪ និមន្ត និងអញ្ជើញមកពីគ្រប់ទិសទីជារៀងរាល់ថ្ងៃ ថ្វាយគ្រឿងសក្ការៈ ឧទ្ទិសថ្វាយព្រះវិញ្ញាណក្ខ័ន្ធព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ។

ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ រមែងសរសើរដ៏កក់ក្តៅជាទីបំផុតសម្តេចចៅហ្វាវាំង អ្នកស្នេហាជាតិដ៏ប្រពៃដែលបានបម្រើព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ និងខ្ញុំ តាំងតែពីស្តេចយាងនិវត្តន៍មកកាន់មាតុប្រទេសនៅខែវិច្ឆិកា ឆ្នាំ១៩៩១។ សម្តេចចៅហ្វាវាំងបានបំពេញការកិច្ចបំរើប្រជាជាតិ សាសនា ព្រះមហាក្សត្រ និងប្រជារាស្ត្រកម្ពុជា ទទួលបានជោគជ័យជាច្រើន គួរជាទីពេញហឫទ័យនៃព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ និងខ្ញុំ។

ខ្ញុំសូមជូនពរសម្តេចចៅហ្វាវាំង សូមទទួលបាននូវមហាជោគជ័យជាបន្តទៀត ក្នុងការកិច្ចដ៏ឧត្តុង្គឧត្តម ព្រមទាំងបានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមសម្តេចចៅហ្វាវាំង និងលោកជំទាវ ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ។

ន មុនិនាថ សីហនុ

**នរោត្តម មុនិនាថ សីហនុ**

ភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១២



www.elibraryofcambodia.org





www.elibraryofcambodia.org




www.elibraryofcambodia.org

ព្រះរាជពិធីដង្ហែព្រះបរមសព
ព្រះករុណា
ព្រះបាទសម្ដេច
ព្រះនរោត្ដម សីហនុ
ពីអាកាសយានដ្ឋានអន្ដរជាតិភ្នំពេញ
ឆ្ពោះទៅកាន់ព្រះបរមរាជវាំង

( ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ )


www.elibraryofcambodia.org

# ព្រះរាជជីវប្រវត្តិសង្ខេប ព្រះករុណា ព្រះចាងសម្តេច ព្រះនរោត្តម សីហនុ




ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ប្រសូតនៅថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំច បញ្ចស័ក ព.ស ២៤៦៦ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩២២ នៅរាជធានីភ្នំពេញ។ ព្រះអង្គជាព្រះរាជបុត្ររបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត និងព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរ័ត្ន សិរីវឌ្ឍនា។

ពីឆ្នាំ១៩៣០ ដល់ឆ្នាំ១៩៤០ ព្រះអង្គបានចូលសិក្សានៅសាលាបឋមសិក្សា ហ្វ្រង់ស័រ បូឌូអឹន (Francois Baudoin) និងវិទ្យាល័យព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ។ បន្ទាប់មក ព្រះអង្គបានបន្តការសិក្សានៅវិទ្យាល័យបារាំង សាសលូឡូបា (Lycée Chasseloup Laubat) នៅព្រៃនគរ (វៀតណាម







www.elibraryofcambodia.org











ខាងត្បូង)។



នៅថ្ងៃទី២៣ មេសា ១៩៤១ ក្រោយពីព្រះអយ្យកោ ព្រះបាទស៊ីសុវត្ថិ មុនីវង្ស ចូលទិវង្គត សម្តេចព្រះនរោត្តម សីហនុ ដែលកាលនោះមានព្រះជន្ម ១៨ ព្រះវស្សា ត្រូវបានក្រុមប្រឹក្សាព្រះរាជសម្បត្តិក្នុងសម័យនោះ ជ្រើសតាំង និងថ្វាយព្រះឋានៈព្រះអង្គ ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។



ព្រះអង្គឡើងគ្រងរាជសម្បត្តិនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៤១។ ខណៈនោះ ប្រទេសកម្ពុជាស្ថិតនៅក្រោមអាណានិគមបារាំង និងជាផ្នែកមួយនៃតំបន់ឥណ្ឌូចិនរបស់បារាំង។



www.elibraryofcambodia.org

នៅឆ្នាំ១៩៤៦ ព្រះអង្គបានយាងទស្សនកិច្ចជាលើកដំបូងនៅប្រទេសបារាំងតាមការអញ្ជើញរបស់លោកប្រធានាធិបតី Felix Gouin និងបានជួបលោកឧត្តមសេនីយ៍ Charles de Gaulle នៅ Colombey ។

ពីឆ្នាំ១៩៤៦ ដល់ឆ្នាំ១៩៤៨ ព្រះអង្គបានបន្តការសិក្សាជាន់ខ្ពស់នៅសាលាអនុវត្តទ័ពសេះ និងកងទ័ពរថពាសដែកនៅសូមួរ (Saumur) ប្រទេសបារាំង ។

ក្នុងឆ្នាំ១៩៤៧ ព្រះអង្គបានទទួលជោគជ័យក្នុងការទាមទារឲ្យរាជាណាចក្រថៃ សងមកព្រះរាជាណាចក្រកម្ពុជាវិញជាដាច់ខាតនូវខេត្តខ្មែរដែលថៃបានយកពីកម្ពុជាក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ គឺខេត្តបាត់ដំបង សៀមរាប កំពង់ធំ និងស្ទឹងត្រែង ។

ឆ្នាំ១៩៤៩ ព្រះអង្គបានទាមទារឲ្យប្រទេសបារាំងបញ្ឈប់នូវសន្ធិសញ្ញាអាណាព្យាបាលដែលបានចុះហត្ថលេខានៅឆ្នាំ១៨៦៣ និងឆ្នាំ១៨៨៤ ។

នៅឆ្នាំ១៩៤៩ដដែល ព្រះអង្គបានឡាយព្រះហស្តលេខាលើសន្ធិសញ្ញាឯករាជ្យដែលប្រទេសបារាំងព្រមទទួលស្គាល់តាមផ្លូវច្បាប់នូវឯករាជ្យរបស់ព្រះរាជាណាចក្រកម្ពុជា ។ សន្ធិសញ្ញាឆ្នាំ១៩៤៩ នេះ លុបចោលនូវសន្ធិសញ្ញាអាណាព្យាបាលឆ្នាំ១៨៦៣ និងឆ្នាំ១៨៨៤ ។

ពីឆ្នាំ១៩៥២ ដល់ឆ្នាំ១៩៥៣





www.elibraryofcambodia.org















ព្រះអង្គបានយាងបំពេញព្រះរាជបូជនីយកិច្ចទាមទារកេតនភណ្ឌឯករាជ្យ ១០០ ភាគរយជូនជាតិមាតុភូមិ។

នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ដោយស្នាព្រះហស្ថដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គ ព្រះរាជាណាចក្រកម្ពុជាបានទទួលឯករាជ្យទាំងស្រុងពីសាធារណរដ្ឋបារាំង។ ប្រជារាស្ត្រកម្ពុជាទូទាំងប្រទេសសូមថ្វាយព្រះកិត្តិនាមព្រះអង្គជា "ព្រះមហាវីរបុរសជាតិ-ព្រះបិតាឯករាជ្យជាតិ"។

នៅឆ្នាំ១៩៥៤ ព្រះអង្គបានបញ្ជូនរាជគណៈប្រតិភូជាតំណាងរបស់ព្រះអង្គទៅចូលរួមនៅក្នុងសន្និសីទស្តីពីឥណ្ឌូចិននៅទីក្រុងហ្សឺណែវដែលមានប្រទេសកម្ពុជាចូលរួមក្នុងឋានៈជារដ្ឋឯករាជ្យឯកភាពជាតិ។



www.elibraryofcambodia.org



នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៥៥ ព្រះ អង្គបានដាក់រាជ្យថ្វាយព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត ជាព្រះរាជបិតា ។ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត បានប្រទានចំពោះព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ នូវព្រះបរមងារជា "សម្តេចព្រះឧបយុវរាជនៃព្រះរាជាណាចក្រកម្ពុជា" ។

ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៥ ព្រះអង្គបានបង្កើតចលនាសង្គមរាស្ត្រនិយមដែលមានគណបក្សជាច្រើនចូលរួមនៅក្នុងចលនានេះ ។

ពីថ្ងៃទី ១៨ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥៥ ព្រះអង្គបានយាងចូលរួមក្នុងសន្និសីទកំពូលអាហ្វ្រិក-អាស៊ីលើកទី១ នៅទីក្រុងបានឌុង ប្រទេសឥណ្ឌូនេស៊ី ។ នៅទីនោះ ព្រះអង្គបានប្រកាសនយោបាយអព្យាក្រឹតក្នុងឯករាជ្យទាំងស្រុង និងសន្តិសហវិជ្ជមាននៃព្រះរាជាណាចក្រកម្ពុជាជាមួយបណ្តាប្រទេសទាំងអស់ដោយមិនគិតពីមនោគមវិជ្ជាឡើយ ។ ព្រះអង្គបានជួបជាលើកដំបូងជាមួយនឹងលោក Jawaharlal Nehru











www.elibraryofcambodia.org









នាយករដ្ឋមន្ត្រីឥណ្ឌា លោក Gamal Abdel Nasser ប្រធានាធិបតីសាធារណរដ្ឋអារ៉ាប់រួម លោក Ahmed Sukarno ប្រធានាធិបតីឥណ្ឌូនេស៊ី លោក Zhou An Lai នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ។





នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ ព្រះអង្គបានទទួលមហាជោគជ័យក្នុងការបោះឆ្នោតសកលជាតិ ក្រោមការគាំទ្រពីប្រជារាស្ត្រខ្មែរដ៏ច្រើនលើសលប់។





www.elibraryofcambodia.org



ព្រះអង្គបានទទួលព្រះរាជឋានៈជានាយករដ្ឋមន្ត្រី។ ក្នុងព្រះរាជឋានៈជាប្រមុខនៃប្រជារាស្ត្រខ្មែរ ព្រះអង្គបានបំពេញព្រះរាជកិច្ចដឹកនាំ ដើម្បីអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជាជាទូទៅនៅក្នុងគ្រប់វិស័យនៃការកសាងជាតិរបស់ព្រះអង្គ ជាពិសេសការលើកស្ទួយនារីឲ្យមានសិទ្ធិស្មើភាពនឹងបុរសក្នុងការងារ។

ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៥៥ ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះអង្គ ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិ។



នៅឆ្នាំ១៩៥៦ នៅទីក្រុង Brioni នៃសាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី ព្រះអង្គបានក្លាយជាបិតាស្ថាបនិកទី៥នៃចលនាមិនចូលបក្សសម្ព័ន្ធ ដោយបានឡាយព្រះហស្តលេខាលើធម្មនុញ្ញនៃចលនាមិនចូលបក្សសម្ព័ន្ធ បន្ទាប់ពីអ្នកផ្តួចផ្តើមគំនិតដ៏សំខាន់៤រូបទៀតគឺលោក Josip Broz Tito ប្រធានាធិបតីយូហ្គោស្លាវី លោក Jawaharlal Nehru នាយក

















www.elibraryofcambodia.org







រដ្ឋមន្ត្រី លោក Ahmed Sukarno ប្រធានាធិបតីឥណ្ឌូនេស៊ី និងលោក Gamal Abdel Nasser ប្រធានាធិបតីសាធារណរដ្ឋអារ៉ាប់រួម។

នៅខែកុម្ភៈ ឆ្នាំ១៩៥៦ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ក្នុងព្រះរាជឋានៈជានាយករដ្ឋមន្ត្រី ព្រះអង្គបានយាងទៅបំពេញទស្សនកិច្ចជាផ្លូវរដ្ឋនៅសាធារណរដ្ឋប្រជាមានិតចិន និងបានជួបជាមួយថ្នាក់ដឹកនាំចិនជាច្រើនរូប មានឯកឧត្តមប្រធាន ម៉ៅ សេទុង (Mao Tse-Tung) ជាដើម។ ព្រះអង្គបានឡាយព្រះហស្ថលេខាលើសេចក្តីប្រកាសរួមស្តីពីមិត្តភាពកម្ពុជា-ចិន។

នៅឆ្នាំ១៩៦០ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត ទ្រង់បានសោយព្រះទិវង្គត ដោយនៅពេលនោះ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ត្រូវបានសមាជិកសភាខ្មែរសម្រេចជាឯកច្ឆន្ទ ជ្រើសតាំងព្រះអង្គជាព្រះប្រមុខរដ្ឋខ្មែរក្នុងព្រះរាជកិច្ចកសាងជាតិមាតុភូមិយ៉ាងសកម្មបំផុត។



ខែកញ្ញា ឆ្នាំ១៩៦០ នៅមហា



www.elibraryofcambodia.org




www.elibraryofcambodia.org

ការចូលរួមរំលែកព្រះរាជមរណទុក្ខ
ពីសំណាក់សម្តេចព្រះមហាសង្ឃរាជ

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស
សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា


www.elibraryofcambodia.org

សន្និបាតអង្គការសហប្រជាជាតិ ព្រះអង្គបានលើកឡើងនូវផែនការបង្កើតនៅអាស៊ីអាគ្នេយ៍ជាតំបន់អព្យាក្រឹតរវាងប្លុកមហាអំណាចទាំងពីរ។

នៅខែឧសភា ឆ្នាំ១៩៦១ តាមព្រះរាជតម្រិះផ្ដួចផ្ដើមរបស់ព្រះអង្គ សន្និសីទអន្តរជាតិមួយត្រូវបានបង្កើតឡើងនៅទីក្រុងហ្សឺណែវ ដើម្បីដោះស្រាយទំនាស់រវាងភាគីទាំងបីនៅប្រទេសឡាវ។



ចាប់ពីខែឧសភា ឆ្នាំ១៩៦១ ព្រះអង្គបានបំពេញព្រះរាជសកម្មភាពនយោបាយការទូតដើម្បីទាមទារប្រាសាទព្រះវិហារជាសម្បត្តិវប្បធម៌បេតិកភណ្ឌជាតិខ្មែរពីប្រទេសថៃវិញ ដោយតុលាការក្រុងឡាអេ។ ព្រះវិហារត្រូវបានប្រគល់មកឱ្យព្រះរាជាណាចក្រកម្ពុជាវិញនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២។

នៅខែវិច្ឆិកា ឆ្នាំ១៩៦១ ព្រះអង្គបានយាងចូលរួមក្នុងសន្និសីទកំពូលលើកទីមួយនៃចលនាមិនចូលបក្សសម្ព័ន្ធនៅទីក្រុងបែលក្រាដនៃប្រទេសយូហ្គោស្លាវីដែលមាន២៥ប្រទេសចូលរួម។ នៅទីនោះ ព្រះអង្គបានថ្កោលទោសចំពោះអំពើរបស់ពួកអាណានិគមនិយមចក្រពត្តិនិយម និងការប្រកាន់ពូជសាសន៍។

**សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស សម្ដេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា**



*«ព្រះវររាជបិតាជាតិខ្មែរគឺជាព្រះមហាវីរក្សត្រ ដែលមានគុណធំធេងសម្រាប់ជាតិមាតុភូមិទឹកដីអង្គរនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាដោយបាននាំមកជូនជាតិ និងប្រជារាស្ត្របស់ព្រះអង្គនូវឯករាជ្យ បូរណភាពទឹកដី ឯកភាពជាតិ ការអភិវឌ្ឍជាតិ និងកិត្យានុភាពជាតិនៅលើឆាកអន្តរជាតិ ពិសេសព្រះអង្គជាអគ្គពុទ្ធសាសនូបត្ថម្ភក៍មហាធំធេងមួយព្រះអង្គ»។*



www.elibraryofcambodia.org

## សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា



«ថ្វីបើព្រះរូបព្រះកាយរបស់ព្រះករុណាព្រះមហាវីរក្សត្ររំលាយខន្ធយាងទៅកាន់បរលោកហើយក្តី ព្រះគុណធម៌ ព្រះកិត្តិសព្ទ ព្រះរាជកិច្ចសម្បូរបែបយ៉ាងប្រកបដោយព្រះមេត្តាស្នេហាប្រជាជាតិប្រជារាស្ត្រខ្មែរ ដឹកនាំឆ្ពោះទៅរកសន្តិភាព ប្រកបដោយព្រះបញ្ញាញាណ ជាព្រះបិតាដ៏ឆ្នើមនៅគ្រប់វិស័យរបស់អង្គសម្តេចឪជាអម្ចាស់ ទ្រង់ស្ថិតជាប់នៅជានិច្ចស្ថិតស្ថេរគង់វង្សជាអមតៈរៀងរហូតតទៅក្នុងដួងចិត្តប្រជារាស្ត្រខ្មែរដែលមិនអាចលុបទៅបានឡើយ»។

នៅខែមិថុនាឆ្នាំ១៩៦៤ លោកឧត្តមសេនីយ៍ Charles de Gaulles ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង បានរៀបចំបដិសណ្ឋារកិច្ចជាឱឡារិកថ្វាយព្រះករុណាព្រះបាទ សម្តេចនរោត្តម សីហនុ នៅទីក្រុងប៉ារីស។ លោកប្រធានាធិបតីបានទទួលដោយស្មោះសរនូវសំណើរបស់ភាគីកម្ពុជាស្តីពីការទទួលស្គាល់អព្យាក្រឹតនៃព្រះរាជាណាចក្រកម្ពុជា។



នៅចុងខែសីហា និងដើមខែកញ្ញា ឆ្នាំ១៩៦៦ ព្រះអង្គបានរៀបចំបដិសណ្ឋារកិច្ចទទួលជាឱឡារិក លោកឧត្តមសេនីយ៍ Charles de Gaulle ដែលមកបំពេញទស្សនកិច្ចជាផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៦៦ នៅក្នុងសុន្ទរកថាដែលថ្លែងនៅពហុកីឡដ្ឋានជាតិអូឡាំពិកភ្នំពេញ លោកប្រធានាធិបតី Charles de Gaulle បានគាំទ្រព្រះរាជាណាចក្រកម្ពុជាដែលការពារឯករាជ្យ បូរណភាពទឹកដី អព្យាក្រឹត សន្តិភាពនៃខ្លួន។

ពីថ្ងៃទី២៦ ខែវិច្ឆិកា ដល់ថ្ងៃទី៦



www.elibraryofcambodia.org

www.elibraryofcambodia.org

# អារម្មណ៍របស់ឥស្សរជនជាន់ខ្ពស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម
ប្រធានព្រឹទ្ធសភា

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន
ប្រធានរដ្ឋសភា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី

សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ
ប្រធានឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ

សាររំលែកព្រះរាជមរណទុក្ខរបស់ឥស្សរជនជាន់ខ្ពស់នានា
និងសកម្មភាពចូលគោរពព្រះបរមសពនៅព្រះបរមរាជវាំង


www.elibraryofcambodia.org

LES PREMIERS JEUX DES NOUVELLES FORCES MONTANTES D'ASIE (25 NOVEMBRE - 6 DÉCEMBRE 1966)



កីឡា "ហ្គានេហ្វូ" អាស៊ីលើកទី១

(២៥ វិច្ឆិកា - ៦ ធ្នូ ១៩៦៦)



ATHLETISME
អត្តពលកម្ម

ខែធ្នូ ឆ្នាំ១៩៦៦ ព្រះអង្គបានយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងឱកាសព្រះរាជពិធីបើក និងបិទកីឡា Ganefo អាស៊ីលើកទីមួយ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្នុងពេលដែលព្រះអង្គកំពុងបំពេញព្រះរាជទស្សនកិច្ចជាផ្លូវការនៅសហភាពសូវៀត ព្រះអង្គត្រូវទម្លាក់ចេញ ដោយសាររដ្ឋប្រហារ មិនស្របច្បាប់មួយនៅភ្នំពេញ។ រដ្ឋប្រហារនោះមានលន់ នល់ ជាមេខ្លោង។ សាធារណរដ្ឋខ្មែររបស់ លន់ នល់

## សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា



«ព្រះអង្គបានធ្វើព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិ ប្រកបដោយព្រះរាជគតិបណ្ឌិត។
ព្រះអង្គជានិមិត្តរូបជាតិដ៏ឧត្តុង្គឧត្តមក្នុងការនាំមកនូវការផ្សះផ្សាបង្រួបបង្រួមជាតិ ឯកភាពជាតិ សុខសន្តិភាព ស្ថិរភាព និងជាម្លប់ដ៏ត្រជាក់ត្រជុំ ដល់ប្រជានុរាស្ត្រទូទៅរស់នៅក្នុងសុភមង្គល សម្បូណ៌សប្បាយរុងរឿង»។



www.elibraryofcambodia.org

## សម្តេចអគ្គមហាពញាចក្រី ហេង សំរិន
## ប្រធានរដ្ឋសភាជាតិ



«ខ្ញុំ និងភរិយានៅតែចងចាំមិនអាចបំភ្លេចបាននូវព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់សម្តេចព្រះវររាជបិតាជាតិខ្មែរដែលមួយជីវិតរបស់ព្រះអង្គ ទ្រង់បានបំពេញព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរប្រកបដោយព្រះបញ្ញាញាណភ្លឺថ្លាគ្រប់កាលៈទេសៈ»។



ត្រូវបានបង្កើតឡើងនៅខែតុលា ឆ្នាំ១៩៧០។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ព្រះអង្គជាព្រះប្រធានចលនាតស៊ូកម្ពុជា "រណសិរ្សរួបរួមជាតិកម្ពុជា" (FUNC) ព្រមជាមួយនោះក៏មានបង្កើតនូវរដ្ឋាភិបាលរួមជាតិកម្ពុជា (GRUNK)។

នៅខែមេសា ឆ្នាំ១៩៧០នៅកង់តុង (សាធារណរដ្ឋប្រជាមានិតចិន) ព្រះអង្គជាអ្នកផ្តួចផ្តើមនៃសន្និសីទកំពូលរបស់ប្រជាជនឥណ្ឌូចិនដែលនៅក្នុងនោះមានការចូលរួមដោយថ្នាក់ដឹកនាំមកពីប្រទេសកម្ពុជា ពីសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដឹកនាំដោយលោកនាយករដ្ឋមន្ត្រី Pham Van Dong ពីរណសិរ្សជាតិរំដោះវៀតណាមខាងត្បូងដឹកនាំដោយលោក Nguyen Huu Tho និងរណសិរ្សស្នេហាជាតិឡាវ (Neo Lao Haksat) ដឹកនាំដោយព្រះអង្គម្ចាស់ Souphanouvong។

ភាគីទាំងនេះបានប្រកាសជាឱឡារិកថា ប្រទេសរបស់ខ្លួនទទួលស្គាល់ និងគោរពជាដាច់ខាត បូរណភាពទឹកដីក្នុងព្រំដែនបច្ចុប្បន្នរបស់កម្ពុជា។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពរំដោះប្រជាជនជាតិនៃរណសិរ្សរួបរួមជាតិកម្ពុជា (FUNC) ផង្តើម



www.elibraryofcambodia.org



បានជ័យជម្នះទាំងស្រុងនៅកម្ពុជា។ «កម្ពុជាប្រជាធិបតេយ្យ» ត្រូវបានបង្កើត ដែលមានព្រះករុណា ព្រះបាទសម្ដេចព្រះនរោត្ដម សីហនុ ជាព្រះប្រធាន។ ប៉ុន្តែនៅខែមេសា ឆ្នាំ១៩៧៦ ព្រះអង្គបានសព្វព្រះរាជហឫទ័យលាលែងមុខងារជាព្រះប្រធាននៃកម្ពុជាប្រជាធិបតេយ្យនេះ ហើយត្រូវបានពួកខ្មែរក្រហមឃុំឃាំងព្រះអង្គ និងសម្ដេចព្រះរាជអគ្គមហេសី ព្រមទាំងធ្វើគត់ព្រះរាជបុត្រាបុត្រីមួយចំនួនផង។



នៅឆ្នាំ១៩៨២ ព្រះអង្គត្រូវបានជ្រើសតាំងជាព្រះប្រធានកម្ពុជាប្រជាធិបតេយ្យជាលើកទីពីរ។

ពីឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៩០ ព្រះអង្គជាព្រះប្រធាននៃចលនាតស៊ូជាតិកម្ពុជា (SNC)។



ចាប់ពីឆ្នាំ១៩៨៧ ព្រះអង្គបាន

## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា



*«ខ្ញុំមានការសោកសៅណាស់ ដោយសារពី ២១ ឆ្នាំមុន ( ឆ្នាំ១៩៩១ ) ខ្ញុំ និងភរិយាបានទៅដង្ហែព្រះអង្គពីប៉េកាំងមក។ ២១ ឆ្នាំក្រោយ នៅក្នុងថិរវេលាមិនខុសគ្នាប៉ុន្មានទេ ខ្ញុំទៅដង្ហែសាជាថ្មីម្ដងទៀត ប៉ុន្តែលើកនេះ គឺខុសប្លែកគ្នា។ ស្ថានភាពហ្នឹងហើយដែលជាទុក្ខសោករបស់ខ្ញុំ។ កាលពីឆ្នាំ១៩៩១ ខ្ញុំ និងភរិយាខ្ញុំ ដង្ហែសម្ដេចឪ និងសម្ដេចម៉ែមកទាំងគូ... ប៉ុន្តែ២១ឆ្នាំក្រោយ ទិដ្ឋភាពផ្សេងគ្នា ខ្ញុំទៅដង្ហែមកដែរ តែខ្ញុំទៅបានតែម្នាក់ ហើយក៏ដង្ហែបានតែហ្លួងម៉ែ ឯសម្ដេចឪ គឺស្ថិតក្នុងស្ថានភាពមួយផ្សេង...»។*



www.elibraryofcambodia.org

### សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះរាជបុត្រ និងជាប្រធានក្រុម ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ



«ប៉ាប៉ាមានគុណដ៏មហាសាលចំពោះប្រទេសជាតិលើគ្រប់វិស័យដែលប្រវត្តិសាស្ត្របានចារឹកថ្វាយនូវគុណូបការៈដ៏ធំធេងនេះថាជាវីរជនដឹកនាំប្រទេសដ៏កំពូលក្នុងការបម្រើប្រទេសជាតិមាតុភូមិឲ្យរុងរឿងថ្កុំថ្កើង និងជាព្រះប្រមុខរដ្ឋដឹកនាំដ៏ល្បីល្បាញលើឆាកជាតិ និងអន្តរជាតិ»។

ខិតខំអស់ពីព្រះកាយពល ដើម្បីបង្រួបបង្រួមភាគីជម្លោះកម្ពុជាទាំងអស់ រិះរកនូវដំណោះស្រាយនយោបាយសមស្រប ដើម្បី បញ្ចប់ជម្លោះនៅកម្ពុជា។ ព្រះអង្គតែងតែប្រទានចំពោះឯកឧត្តមលោក ហ៊ុន សែន និងគណៈប្រតិភូនៃរដ្ឋកម្ពុជា ចូលក្រាបថ្វាយបង្គំគាល់ជាបន្តបន្ទាប់ នៅប្រទេសបារាំង៖

-ពីថ្ងៃទី០២ ដល់ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩៨៧ ជំនួបលើកទីមួយនៅ Fère-en-Tardenois ។

-ពីថ្ងៃទី២០-២១ ខែមករា ឆ្នាំ ១៩៨៨ ជំនួបលើកទីពីរនៅ Saint-Germain-en-Laye ។



នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ១៩៩១ ព្រះអង្គបានទទួលពីមេដឹកនាំនៃភាគីខ្មែរទាំង៤ ដើម្បីប្រកាសជាឱឡារិកនូវក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ហើយទទួលស្គាល់ការបញ្ឈប់ជាបណ្តោះអាសន្ននូវការបាញ់គ្នានៅក្នុងប្រទេសកម្ពុជាទាំងមូល និងបញ្ឈប់ការផ្តល់ជំនួយយោធាអាវុធ... ពីប្រទេសដទៃ ដល់កងទ័ពកម្ពុជាទាំង៤ភាគី។ ទីក្រុងភ្នំពេញត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ( SNC ) ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ជាទីស្នាក់ការ ផ្លូវការអចិន្ត្រៃយ៍ និងលេខាធិការដ្ឋាន



www.elibraryofcambodia.org





www.elibraryofcambodia.org

# សាររំលែកព្រះបរមមរណទុក្ខពីសំណាក់
# ឥស្សរជនជាន់ខ្ពស់នានា
# និងសកម្មភាពចូលគោរព
# ព្រះបរមសពនៅព្រះបរមរាជវាំង

*«ការយាងចូលព្រះទិវង្គតរបស់ព្រះមហាវីរក្សត្រ*
*គឺជាការបាត់បង់ដ៏ធំធេងបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជា*
*នូវព្រះអត្តមត្តទេសក៍ដ៏ឆ្នើម ព្រះបិតាឯករាជ្យជាតិ*
*ផ្សះផ្សាជាតិ បង្រួបបង្រួមជាតិដែលព្រះអង្គ*
*បានប្រកាន់ខ្ជាប់ខ្ជួននូវទស្សនៈពិធរាជធម៌*
*ក្នុងការដឹកនាំប្រទេសជាតិ*
*និងតែងតែយកព្រះទ័យទុកដាក់អស់ពីព្រះកាយពល*
*និងព្រះបញ្ញាញាណពុំខ្វាចទៀយហត់ ហើយបានលះបង់*
*ព្រះរាជទ្រព្យដើម្បីរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍ*
*សង្គមជាតិ ជាពិសេសនៅក្នុងវិស័យមនុស្សធម៌»។*

***ថ្នាក់ដឹកនាំជាន់ខ្ពស់ថ្នាក់ឧបនាយករដ្ឋមន្ត្រី***
***ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី អភិបាលខេត្ត-រាជធានី***
***និងប្រធានស្ថាប័ននានានៅក្នុងព្រះរាជាណាចក្រកម្ពុជា***



www.elibraryofcambodia.org

របស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (SNC)។



នៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ១៩៩១ ព្រះអង្គបានយាងចាកចេញពីប្រធាននៃកម្ពុជាប្រជាធិបតេយ្យ និងចលនាតស៊ូជាតិកម្ពុជា (CNR) ដើម្បីដាក់ព្រះកាយព្រះអង្គនៅពីលើគាត់ និងខ្សែនយោបាយកម្ពុជានានា។ ព្រះអង្គត្រូវបានសមាជិកទាំង ១១ នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (CNC) ជ្រើសតាំងជាឯកច្ឆន្ទជាព្រះប្រធាន «អញ្ញាក្រឹត» នៃក្រុមប្រឹក្សានេះ។

ថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៩១ នៅទីក្រុងប៉ារីស ព្រះអង្គបានឡាយព្រះហស្តលេខា «លើកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា» ជាមួយសមាជិកនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ១១ រូបទៀត ជាមួយតំណាងរដ្ឋាភិបាល នៃប្រទេសចំនួន ១៨ និងជាមួយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ។

នៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ១៩៩១ ព្រះអង្គបានយាងនិវត្តន៍មកកាន់រាជធានីភ្នំពេញវិញប្រកបដោយជោគជ័យ និងសុវត្ថិភាព។ ក្រោយមាតុភូមិនិវត្តន៍របស់ព្រះអង្គ រដ្ឋាភិបាលនៃរដ្ឋកម្ពុជាដែលមានឯកឧត្តមលោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រី និងឯកឧត្តមលោក ជា ស៊ីម



សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម
ប្រធានព្រឹទ្ធសភា



សម្តេចអគ្គមហាពញាចក្រី ហេង សំរិន
ប្រធានរដ្ឋសភាជាតិ និងលោកជំទាវ



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន



www.elibraryofcambodia.org



គណៈប្រតិភូក្រសួងមហាផ្ទៃ
ដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង



គណៈប្រតិភូក្រសួងការបរទេសនិងសហប្រតិបត្តិការ អន្តរជាតិ
ដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង



គណៈប្រតិភូក្រសួងការពារជាតិ
ដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់



ជាប្រធានគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច ដែលមាន ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ជាប្រធាន គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាដែលមាន សម្តេចបវរសេដ្ឋា សឺន សាន ជាប្រធាន និងគាតីកម្ពុជាប្រជាធិបតេយ្យដែលមានលោក ខៀវ សំផន ជាប្រធាន បានប្រកាសជាបន្តបន្ទាប់ ជាផ្លូវការ និងជាលាយលក្ខណ៍អក្សរថា ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ នៅតែជាព្រះប្រមុខរដ្ឋពេញលក្ខណៈច្បាប់នៃប្រទេសកម្ពុជាទាំងមូល ម្យ៉ាងទៀត ព្រះអង្គជាផ្លូវការ នៅតែរក្សាទុកតួនាទីជាព្រះប្រមុខរដ្ឋ រហូតដល់មានការបោះឆ្នោតនៅកម្ពុជានាឆ្នាំ១៩៩៣។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ព្រះអង្គបានឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនូវរដ្ឋធម្មនុញ្ញថ្មីនៃព្រះរាជាណាចក្រកម្ពុជាដែលសភាធម្មនុញ្ញកម្ពុជាបាន អនុម័ត។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដដែល មហាមិទ្ទិញមហាជនមួយ ក៏ត្រូវបានរៀបចំឡើងដោយមានមហាជនយ៉ាងច្រើនកុះករចូលរួម ដើម្បីសម្តែងមនោសញ្ចេតនាអបអរគាំទ្រស្វាគមន៍ចំពោះរដ្ឋធម្មនុញ្ញថ្មី និងព្រះឋានៈ



www.elibraryofcambodia.org

ព្រះអង្គជា «ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា»។ ការយាងគ្រងរាជសម្បត្តិសាជាថ្មីនៅឆ្នាំ១៩៩៣ របស់ព្រះអង្គដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រពិភពលោកកន្លងមក ត្រូវបានកត់ត្រាទុកនៅក្នុងសៀវភៅកំណត់ត្រាពិភពលោក។

ព្រះអង្គបានបំពេញព្រះរាជកិច្ចដ៏ឧត្តុង្គឧត្តមជាទីបំផុតក្នុងការបង្រួបបង្រួមផ្សះផ្សាជាតិតាំងពីដើមរហូតមក។ ព្រះអង្គបានធ្វើឲ្យចេញជារូបរាងនូវរដ្ឋាភិបាលចម្រុះដែលមានសហនាយករដ្ឋមន្ត្រីនៅឆ្នាំ១៩៩៣ ហើយជាពិសេសព្រះអង្គបានបំពេញព្រះរាជកិច្ចធ្វើឲ្យថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច ចុះហត្ថលេខាលើសេចក្ដីប្រកាសរួមអំពីគោលការណ៍សហប្រតិបត្តិការដែលបានសម្រេចក្នុងកិច្ចប្រជុំកំពូល ក្រោមព្រះរាជាធិបតី ភាពរបស់ព្រះអង្គនៅមហាប្រាសាទខេមរិន្ទ ព្រះបរមរាជវាំង នាថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨។

នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៤ ព្រះអង្គបានសព្វព្រះរាជហឫទ័យប្រកាសយាងចូលនិវត្តន៍។

នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៤ ក្រុមប្រឹក្សារាជសម្បត្តិបានកោះប្រជុំ និងបោះឆ្នោតជាឯកច្ឆន្ទជ្រើសរើសសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ជាព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា។

វង្សសកាជាតិនៃព្រះរាជាណាចក្រកម្ពុជា បានព្រមព្រៀងថ្វាយជូនព្រះអង្គនូវព្រះគោរមងារជាផ្លូវការជា



គណៈប្រតិភូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី គាត ឈន់



គណៈប្រតិភូក្រសួងពាណិជ្ជកម្ម
ដឹកនាំដោយឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ



គណៈប្រតិភូក្រសួងអភិវឌ្ឍន៍ជនបទ
ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រី ជា សុផារ៉ា



www.elibraryofcambodia.org



*គណៈប្រតិភូក្រសួងផែនការ*
*ដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី ឆាយ ថន*



*គណៈប្រតិភូក្រសួងព័ត៌មាន*
*ដឹកនាំដោយឯកឧត្តម រដ្ឋមន្ត្រី ខៀវ កាញារីទ្ធ*



*គណៈប្រតិភូក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល*
*ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រី ស៊ុយ សែម*

«ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ» ជាមួយនឹងព្រះរាជបុព្វសិទ្ធិពិសេស ក៏ដូចជាព្រះរាជអភ័យឯកសិទ្ធិដូចកាលដែលព្រះអង្គនៅគ្រងរាជ្យ។

ព្រះមហាវីរក្សត្រតែងតែបំពេញព្រះរាជសកម្មភាពសង្គមកិច្ច ដូចជាកសាងព្រះវិហារ កុដិ សាលាបុណ្យ សាលារៀន មន្ទីរពេទ្យ ផ្ទះសម្បែង ផ្លូវថ្នល់ ទំនប់ប្រឡាយ អណ្តូងទឹក ស្រះទឹក សម្រាប់ប្រគេនព្រះសង្ឃ និងជូនប្រជារាស្ត្រ។

ព្រះអង្គបានប្រោសព្រះរាជទាន និងបន្ត នូវការប្រោសព្រះរាជទាន (រៀងរាល់ សប្តាហ៍) ព្រះរាជអំណោយដល់ប្រជារាស្ត្រទីទ័លក្រ និងជីវភាពខ្វះខាតខ្លាំង។ ព្រះអង្គបានប្រោសព្រះរាជទានដល់ប្រជារាស្ត្រដោយមិនប្រកាន់ជាតិកំណើត ជំនឿសាសនា ពណ៌សម្បុរឡើយ។

នៅទីបំផុត ព្រះអង្គបានយាងចូលព្រះទិវង្គត នៅថ្ងៃចន្ទ ទី ១៥ ខែតុលា ឆ្នាំ២០១២ ត្រូវនឹងថ្ងៃ ១៥ កើត ខែកត្តិក ឆ្នាំរោង ចត្វាស័ក វេលាម៉ោង ១ និង ២០ នាទីយប់ (ម៉ោងនៅកម្ពុជា) នៅទីក្រុងប៉េកាំង គឺនៅមុន ១៦ ថ្ងៃ នៃថ្ងៃបុណ្យចម្រើនព្រះជន្ម៩០ព្រះវស្សា របស់ព្រះអង្គដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១២។

បើទោះបីព្រះអង្គយាងចូលទិវង្គតក្តី ក៏ព្រះរាជបុជនីយកិច្ចដើម្បីជាតិដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គឋិតជាប់ជានិរន្តរ៍ ក្នុងដួងចិត្តកូនចៅខ្មែរគ្រប់រូប។



www.elibraryofcambodia.org

# ព្រះរាជបូជនីយកិច្ច ទាមទារឯករាជ្យ បរិបូរជូនជាតិមាតុភូមិ



យោងតាមឯកសាររបស់ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ឲ្យដឹងថា នៅក្នុង ព្រះរាជបេសកកម្ម ដើម្បីជាតិមាតុភូមិ និងប្រជារាស្ត្រខ្មែរ សម្តេចព្រះបាទនរោត្តម សីហនុ ទ្រង់បានលះបង់ ព្រះកាយពល និងព្រះបញ្ញាញាណយ៉ាងក្លៀវក្លាបំផុត ធ្វើការតស៊ូក្នុងក្របខ័ណ្ឌនៃ ព្រះរាជបូជនីយកិច្ច ដើម្បីទាមទារឯករាជ្យនៅកម្ពុជាឱ្យរួចចាកផុតពីអាណានិគមនិយមបារាំង ដែលប្រវត្តិសង្ខេប នៃ ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យនៅកម្ពុជា ដូចតទៅនេះ ៖

តាមសន្ធិសញ្ញាចុះថ្ងៃទី ០៨ វិច្ឆិកា ឆ្នាំ១៩៤៩ បារាំងបានទទួលស្គាល់តាមផ្លូវច្បាប់នូវ ឯករាជ្យ របស់ ព្រះរាជាណាចក្រកម្ពុជា ។



គណៈប្រតិភូស្ថាប័នព្រឹទ្ធសភា
ដឹកនាំដោយ ឯកឧត្តម សាយ ឈុំ ប្រធានស្តីទី



គណៈប្រតិភូស្ថាប័នរដ្ឋសភាជាតិ
ដឹកនាំដោយ ឯកឧត្តម ង៉ួន ញិល អនុប្រធានទី១



គណៈប្រតិភូទេសាភិបាលធនាគារជាតិនៃកម្ពុជា
ដឹកនាំដោយឯកឧត្តម ជា ចាន់តូ



www.elibraryofcambodia.org



គណៈប្រតិភូក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
ដឹកនាំដោយលោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន



គណៈប្រតិភូក្រសួងសាធារណការ និងដឹកជញ្ជូន
ដឹកនាំដោយឯកឧត្តម ត្រាំ អ៊ីវតឹក



គណៈប្រតិភូក្រសួងសង្គមកិច្ច និងយុវនីតិសម្បទា
ដឹកនាំដោយឯកឧត្តម អ៊ិត សំហេង



ជាគោលការណ៍តាមផ្លូវច្បាប់ ឯករាជ្យនេះ យើងទទួលបានមែន ប៉ុន្តែ ចំពោះការអនុវត្តជាក់ស្តែង ឯករាជ្យនេះ នៅខ្វះវិស័យជាច្រើនទៀត ដូចជា អធិបតេយ្យខាង យុត្តិធម៌ ប៉ូលិស អំណាចបញ្ជាការយោធា ការទូត ការប្តូរ និងការឱ្យតាយធនប័ត្រ ដើម្បីឲ្យមាន ឯករាជ្យ ទាំងស្រុង។

តាមសេចក្តីប្រកាសថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៥២ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន បានសន្យាយ៉ាង ឱឡារិកចំពោះ ប្រជាពលរដ្ឋរបស់ព្រះអង្គថា ព្រះអង្គនឹង ដណ្តើមយក ឯករាជ្យទាំងស្រុងនេះ ដើម្បីមាតុភូមិក្នុងរយៈពេល ៣ ឆ្នាំ យ៉ាងយូរបំផុត។

នៅថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ១៩៥៣ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន បានយាងចាកចេញ ពី ព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅកាន់ ប្រទេសបារាំង ដើម្បីទាមទារឯករាជ្យ របស់កម្ពុជាជាមួយប្រមុខរដ្ឋបារាំង។

នៅដីឡូណាពូល ថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៥៣ ព្រះករុណា ព្រះបាទ



www.elibraryofcambodia.org



សម្តេចព្រះ នរោត្តម សីហនុ វ្រ៉ែន បានផ្ញើព្រះរាជសារលិខិតមួយច្បាប់ជូនចំពោះលោក វ៉ាំងសង់ អូរីយ៉ុល ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ដើម្បីរៀបរាប់បង្ហាញឱ្យប្រធានាធិបតី នៃសាធារណរដ្ឋបារាំងដឹងពីភាពចាំបាច់សំដៅ ធ្វើឱ្យបារាំងពង្រីកក្របខ័ណ្ឌឯករាជ្យខ្មែរ។ ភ្ជាប់នឹងព្រះរាជសារលិខិតនេះ មានការសិក្សាគ្រប់គ្រាន់ ដោយទឡ្ហីករណ៍សំអាងបញ្ជាក់ អំពីការទាមទាររបស់សម្តេច និងការផ្តល់យោបល់ពីបែបបទនៃការផ្ទេរអំណាចជាយថាហេតុ។



គណៈប្រតិភូក្រសួងបរិស្ថាន
ដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី ម៉ុក ម៉ារ៉េត



គណៈប្រតិភូក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
ដឹកនាំដោយឯកឧត្តម សូ ឃុន



នៅជីឡាណាពូល ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៥៣ បន្ទាប់មកនៅ ហុងតែនណាប្លូ ថ្ងៃទី០៣ ខែ មេសា ឆ្នាំ១៩៥៣ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវ្រ៉ែន បានសរសេរព្រះរាជសារលិខិតចំនួន ០២ ច្បាប់បន្ថែមទៀត ផ្ញើជូន វ៉ាំងសង់ អូរីយ៉ុល និងរដ្ឋាភិបាលបារាំង ដើម្បីបំពេញបន្ថែមលើ ទស្សនៈរបស់ព្រះអង្គ ដែលទាក់ទងនឹងឯករាជ្យខ្មែរ និងដើម្បីស្នើឱ្យរដ្ឋាភិបាលបារាំងប្រញាប់ប្រញាល់ដោះស្រាយបញ្ហានេះ។



គណៈប្រតិភូក្រសួងធនធានទឹក និងឧតុនិយម
ដឹកនាំដោយឯកឧត្តម លឹម គានហោ



www.elibraryofcambodia.org



គណៈប្រតិភូក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម



គណៈប្រតិភូក្រសួងសុខាភិបាល
ដឹកនាំដោយឯកឧត្តម ម៉ម ប៊ុនហេង



គណៈប្រតិភូក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ដឹកនាំដោយឯកឧត្តម ច័ន្ទ សារុន



នៅចំពោះមុខការលាក់លៀមរបស់រដ្ឋាភិបាលបារាំង ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុវរ្ម័ន បានយាងចាកចេញពីប្រទេសបារាំង នៅថ្ងៃទី ១១ ខែមេសា ឆ្នាំ១៩៥៣ ឆ្ពោះទៅកាន់ប្រទេសកាណាដា និងសហរដ្ឋអាមេរិក ដែលនៅទីនោះ ព្រះអង្គបានធ្វើយុទ្ធនាការឃោសនា ដើម្បីឯករាជ្យរបស់ប្រទេសព្រះអង្គ។

សេចក្ដីថ្លែងការណ៍របស់ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុវរ្ម័ន ត្រូវបានចុះផ្សាយដោយកាសែតដ៏ធំញូវយ៉កថែម នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ ១៩៥៣ លាន់ឮខ្ទរខ្ទារពេញពិភពលោកទាំងមូល ហើយបានបង្ខំឱ្យរដ្ឋាភិបាលបារាំងទទួលយល់ព្រមធ្វើការចរចាជាមួយតំណាងផ្ទាល់ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ។ តំណាងនេះ គឺឯកឧត្តម ប៉ែន នុត





www.elibraryofcambodia.org




ដោយ មានការចូលរួមពីឯកឧត្តម សម សារី ផងដែរ។

ការចរចានៅប៉ារីសបានឈានទៅដល់សំណើមួយ ដែលធ្វើឡើងដោយមានប្រទេសបារាំង យល់ព្រមផ្តល់សម្បទានដីសំខាន់ខ្លះដល់កម្ពុជា។ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ ១៩៥៣ ឯកឧត្តម ប៉ែន នុត បានអញ្ជើញវិលត្រឡប់មកកាន់កម្ពុជាវិញ ដើម្បីទូលថ្វាយព្រះមហាក្សត្រអំពីលទ្ធផលដែលទទួលបាននៅប៉ារីស។ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន បានយាងមកកាន់ រាជធានី ភ្នំពេញវិញ នៅថ្ងៃ ទី១៤ ខែឧសភា ឆ្នាំ១៩៥៣ ដើម្បីជួបជា[illegible]ហសេរីក និងនាយករដ្ឋមន្ត្រី [illegible]អង្គ។



គណៈប្រតិភូកំណែទម្រង់រដ្ឋបាលកម្ពុជា
ដឹកនាំដោយឯកឧត្តមប្រធាន ងោ ហុងលី



គណៈប្រតិភូអាជ្ញាធរជាតិកំចាត់មីនកម្ពុជា ដឹកនាំដោយ
ឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី





គណៈប្រតិភូ ក្រុមហ៊ុនសូគីមិចគ្រុប
ដឹកនាំដោយអ្នកឧកញ៉ា សុខ គង់

ចំពោះប្រជាពលរដ្ឋរបស់ព្រះអង្គដែលបានថ្វាយ ព្រះកិត្តិយសចំពោះព្រះអង្គជាអ្នកទទួលជ័យជម្នះ និងជាវីរបុរសនោះ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ទ្រង់បានសន្យា



www.elibraryofcambodia.org



គណៈប្រតិភូអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន
ដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន



គណៈប្រតិភូកងយោធពលខេមរភូមិន្ទ
ដឹកនាំដោយឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ុល សារឿន



គណៈប្រតិភូស្នងការនគរបាលជាតិ
ដឹកនាំដោយឯកឧត្តម នាយឧត្តមសេនីយ៍ ទេត សារឿន



យ៉ាងមហោឡារិកនៅក្នុងព្រះសុន្ទរកថាមួយដែលទ្រង់បានថ្លែង នៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ១៩៥៣ ពីព្រះទីនាំង ចន្ទឆាយា ថា ព្រះអង្គនឹងបូជាជីវិតដើម្បីដណ្តើមយកឯករាជ្យឲ្យបាន១០០ភាគរយ។

នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៥៣ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ទ្រង់បានភៀសព្រះកាយទៅប្រទេសថៃ ក្រោយពីមានសេចក្តីប្រកាសមួយដែលទាក់ទាញពិភពលោកស្តីពីការមិនពេញចិត្ត និងបំណងប្រាថ្នាស្របច្បាប់របស់ប្រជាជនខ្មែរ។ ការមិនពេញចិត្តនេះអាចនាំមកនូវផលវិបាកយ៉ាងធ្ងន់ធ្ងរទាំងសម្រាប់ប្រទេសកម្ពុជា និងពិភពលោកទាំងមូល។

ក្រោយពីបានដឹងថា គ្រប់ប្រជាជាតិមានការយោគយល់ចំពោះការទាមទារឯករាជ្យ និង ចំពោះព្រឹត្តិការណ៍នៅប្រទេសកម្ពុជា ព្រះករុណាព្រះបាទ





www.elibraryofcambodia.org





www.elibraryofcambodia.org

# សាររំលែកព្រះបរមមរណទុក្ខ
# ពីសំណាក់ថ្នាក់ដឹកនាំ
# និងអតីតថ្នាក់ដឹកនាំបរទេសនានា
# នៅលើពិភពលោក


www.elibraryofcambodia.org



សម្តេច ព្រះនរោត្តម សីហនុវរ្ម័ន បានយាងត្រឡប់មកមាតុភូមិរបស់ព្រះអង្គវិញ ហើយយាងទៅគង់នៅតំបន់ស្វយ័តមួយ ដែលរួមមានខេត្ត សៀមរាប បាត់ដំបង និងកំពង់ធំ ។

ស្វយ័តភាពផ្នែកយោធានៃខេត្តទាំងនេះ ត្រូវបានប្រគល់ឱ្យប្រទេសកម្ពុជា ដោយមានការទាមទារមួយរបស់ព្រះរាជា ដែលបានធ្វើឡើងនៅឆ្នាំ ១៩៤៩ សម្រាប់ខេត្តសៀមរាប និងខេត្តកំពង់ធំ និងនៅឆ្នាំ១៩៥២សម្រាប់ខេត្តបាត់ដំបង។

ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ទ្រង់បានប្តូរពាក្យសច្ចាព្រះអង្គនឹងយាងចូលរាជធានីភ្នំពេញវិញ នៅពេលណាដែលបារាំងព្រមផ្ទេរមកឲ្យប្រទេសកម្ពុជាវិញនូវកេតនភណ្ឌចុងក្រោយនៃឯករាជ្យរបស់ខ្លួន ។

ដើម្បីគាំពារនូវព្រះរាជបូជនីយកិច្ចនេះ ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ទ្រង់បានបង្កើតកងកម្លាំងជីវពល និងនាវិក្ខាហាន ដែល





*«ព្រះករុណា ព្រះមហាវីរក្សត្រធ្លាប់បានចាត់ទុកប្រទេសចិន គឺជាមាតុភូមិទីពីររបស់ព្រះអង្គ ហើយព្រះអង្គក៏ជាអ្នកបង្កើតទំនាក់ទំនងមិត្តភាពជាមួយថ្នាក់ដឹកនាំចិនជាច្រើនជំនាន់ ជាង៍កន្លះសតវត្សរ៍មកហើយ។ ព្រះអង្គគឺជាស្ថាបនិកថែរក្សា និងបង្កើនទំនាក់ទំនងមិត្តភាពចិន-កម្ពុជា ដែលត្រូវចារទុកក្នុងប្រវត្តិសាស្ត្រជារៀងរហូត។ ខ្ញុំបានជួបព្រះអង្គជាច្រើនដង ហើយខ្ញុំនៅចងចាំយ៉ាងច្បាស់នូវស្នាមព្រះភក្ត្រដ៏រស់រវើកស្នាមញញឹម និងព្រះរាជសព្ទរបស់ព្រះអង្គ»។*

**ឯកឧត្តម Jiang Zemin**
***អតីតប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន***



*«ព្រះបាទ នរោត្តម សីហនុ គឺជាមេដឹកនាំដែល មានការគោរពពាសពេញពិភពលោក។ ការយាងចូលទិវង្គតរបស់ព្រះអង្គបានបង្ហាញឲ្យឃើញនូវការគោរព និងសេចក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅអស់ពីដួងចិត្តពីប្រជាជនកម្ពុជាគ្រប់រូបចំពោះព្រះអង្គ»។*

**លោកជំទាវ Julia Gillard**
***នាយករដ្ឋមន្ត្រីអូស្ត្រាលី***



*«ព្រះបាទ នរោត្តម សីហនុ ជាឥស្សរជនប្រវត្តិសាស្ត្រដ៏ឆ្នើមមួយរូបនៅក្នុងទ្វីបអាស៊ី ជាអ្នកទ្រទ្រង់ និងជាស្ថាបនិកនៃចលនាមិនចូលបក្សសម្ព័ន្ធ។ ព្រះអង្គបានខិតខំបំពេញព្រះរាជកិច្ចអស់មួយជីវិតដើម្បីប្រជាជន និងស្ថិរភាពនៅកម្ពុជា ក៏ដូចជាទ្វីបអាស៊ី ព្រមទាំងគាំពារសិទ្ធិ យុត្តិធម៌ និងសន្តិភាពនៅលើពិភពលោក និងបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងចំពោះសិទ្ធិរបស់ប្រជាជនប៉ាឡេស្ទីន ក្នុងការសម្រេចចិត្តដោយខ្លួនឯង និងការបង្កើតរដ្ឋប៉ាឡេស្ទីនឯករាជ្យ។ ការយាងចូលទិវង្គតរបស់ព្រះអង្គគឺជាការបាត់បង់នូវមិត្ត និងអ្នកគាំទ្រដ៏ស្មោះចំពោះសិទ្ធិជាតិស្របច្បាប់នៃប្រជាជនប៉ាឡេស្ទីនយើង»។*

**ឯកឧត្តម Mahmoud Abbas**
***ប្រធានអាជ្ញាធរជាតិ ប៉ាឡេស្ទីន***



www.elibraryofcambodia.org



«ខ្ញុំដឹងអំពីទំនាក់ទំនងដ៏ខ្លាំងក្លា និងផ្សា ប្រវត្តិសាស្ត្រ រវាង ព្រះអង្គ និងប្រទេសបារាំង ហើយដែលតាមរយៈព្រះអង្គទំនាក់ទំនងទាំងនេះ បានរួមចំណែកធ្វើឱ្យប្រទេសជាតិ និងប្រជាជនយើងទាំងពីរ កាន់តែខិតជិតគ្នា។ សម្រាប់មនុស្ស ភាគច្រើន ព្រះអង្គគឺជានិមិត្តរូបនៃនយោបាយអាស៊ីមួយដែលលើកតម្កើងនូវសមភាព និងការការពារអធិបតេយ្យភាព នៃប្រជាជាតិនានា។ ទ្រង់គឺជាអ្នកការពារដ៏ក្លៀវក្លានូវវប្បធម៌ហ្វ្រង់កូហ្វូនី ភាសា និងសិល្បៈនៃប្រទេសប្រើប្រាស់ភាសាបារាំងព្រមទាំងទស្សនៈ ពហុសាសន៍នៃទំនាក់ទំនងអន្តរជាតិ»។

**ឯកឧត្តម Francois Hollande**
**ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង**



«ការយាងចូលទិវង្គតរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ គឺជាការបាត់បង់ដ៏ធំធេងរបស់ប្រជាជនកម្ពុជា។ ទោះបីជាយ៉ាងណាក្តី ខ្ញុំជឿជាក់ថា ប្រជាជនកម្ពុជានឹងឆ្លងផុតពីទុក្ខសោកដ៏មហាធំធេងនេះ និងបន្តការអភិវឌ្ឍ ដោយផ្អែកលើស្នាដៃដែលព្រះអង្គសម្រេចបាន»។

**ឯកឧត្តម Kim Hwang-sik**
**នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋកូរ៉េ**



«ព្រះបាទ នរោត្តម សីហនុ បានបន្សល់នូវស្នាព្រះហស្តសំខាន់ពិតប្រាកដមិនត្រឹមតែចំពោះប្រជាជាតិកម្ពុជាប៉ុណ្ណោះទេ ថែមទាំងចំពោះពិភពលោកផងដែរ។ យើងនឹងចងចាំនូវការរួមចំណែកដ៏ធំធេងរបស់ព្រះអង្គជានិច្ចកាល ចំពោះការជំរុញឱ្យមានសន្តិភាពតំបន់ វិបុលភាព និងចំពោះការពង្រឹងសាមគ្គីភាពក្នុងចំណោមប្រជាជាតិកំពុងអភិវឌ្ឍន៍»។

**ឯកឧត្តម Susilo Bambang**
**ប្រធានាធិបតីនៃប្រទេសឥណ្ឌូនេស៊ី**



ក្រោយមកមានគូនាទីយ៉ាងធំធេង។ ឯកឧត្តម ប៉ែន នុត នាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រាប់រងការពារតំបន់ស្វយ័តរបស់ព្រះរាជា។

ការបេះបោរដែលប្រព្រឹត្តទៅ នៅក្រុងភ្នំពេញ ដោយមានការណែនាំពីព្រះរាជា និងក្រោមការដឹកនាំរបស់ឯកឧត្តម ប៉ែន នុត បានសម្រេចដោយជោគជ័យទាំងស្រុង ។ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៣ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្ទេរអំណាចតុលាការ ។





www.elibraryofcambodia.org

ថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៣ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្ទេរសមត្ថកិច្ចរបស់ប៉ូលិស នៅចុងបញ្ចប់ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៥៣ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីអធិបតេយ្យ ខាងយោធារបស់ប្រជារាស្ត្រខ្មែរនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះ អធិបតេយ្យទាំងមូលលើផ្នែកការទូតត្រូវបានធ្វើឡើងតាមរយៈការប្តូរលិខិតរវាងរដ្ឋាភិបាលបារាំង និងរាជរដ្ឋាភិបាល (ចម្លើយរបស់រដ្ឋាភិបាលបារាំងចំពោះកំណត់មួយរបស់រាជរដ្ឋាភិបាលនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៥៣ ដែលប្រគល់ដោយអគ្គស្នងការរបស់សាធារណរដ្ឋបារាំង លេខ ៣៩៣ អឺរ ចុះថ្ងៃ ទី២៤ ខែកក្កដា ឆ្នាំ១៩៥៣ លិខិតទទួល និងភាពត្រឹមត្រូវលើការអនុវត្តនៃកិច្ច ព្រមព្រៀងមានចែងក្នុងកំណត់មួយសម្រាប់រាជរដ្ឋាភិបាលដែលប្រគល់ជូនអគ្គស្នងការនៃសាធារណរដ្ឋបារាំងនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៥៣ ក្រោមលេខ ៦៧-ប៉េ សេ អឹម អែស អឹម)។

នៅថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ១៩៥៣





«ព្រះអង្គគឺជាមហាមិត្តរបស់ប្រជាជនចិន។ ព្រះអង្គតែងតែបានប្តេជ្ញាបង្កើននូវមិត្តភាពរវាងចិន-កម្ពុជា និងបានជំរុញមិត្តភាពនេះឲ្យកាន់តែជិតស្និទ្ធថែមទៀតជាមួយថ្នាក់ដឹកនាំចិន ជាច្រើនជំនាន់កន្លងមក។ ក្រោមព្រះរាជយកព្រះទ័យទុកដាក់របស់ព្រះអង្គ និងកិច្ចខិតខំប្រឹងប្រែងរបស់ភាគីទាំងពីរ មិត្តភាពរវាងចិន-កម្ពុជា បានចាក់ឫសយ៉ាងជ្រៅ និងទទួលបាននូវលទ្ធផលជាផ្លែផ្កាជាលំដាប់។ វិភាគទានយ៉ាងធំធេងរបស់ព្រះអង្គដើម្បីអភិវឌ្ឍទំនាក់ទំនងរវាងចិន-កម្ពុជានឹងចារជាប់ក្នុងប្រវត្តិសាស្ត្រជាអមតៈ»។

**ឯកឧត្តម Hu Jintao**

**ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន**



«ព្រះអង្គគឺជារដ្ឋបុរសអន្តរជាតិមួយអង្គត្រូវបានគោរពយ៉ាងខ្ពង់ខ្ពស់បំផុតដែលមានព្រះរាជហឫទ័យស្រឡាញ់ប្រទេស និងប្រជាជនរបស់ព្រះអង្គ។ ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះអង្គ ប្រទេសកម្ពុជាបានទទួលឯករាជ្យនៅឆ្នាំ១៩៥៣ និងជាគំរូមួយនៃការអភិវឌ្ឍសម្រាប់តំបន់នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ ព្រះអង្គជានិមិត្តរូបនៃក្តីសង្ឃឹមសម្រាប់ប្រទេសក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ហើយព្រះអង្គបានដឹកនាំប្រជាជនឆ្លងកាត់ការលំបាកជាច្រើនឆ្នាំដោយសេចក្តីក្លាហាន និងការប្តេជ្ញាខ្ពស់»។

**ឯកឧត្តម Tony Tan Keng Yam**

**ប្រធានាធិបតីសិង្ហបុរី**



«ព្រះអង្គជាអ្នកនយោបាយដ៏ឆ្នើមដែលបានបូជាអស់មួយជីវិតដើម្បីឯករាជ្យ បូរណភាពទឹកដី ឯកភាពផ្សះផ្សាជាតិ និងរុងរឿងនៃប្រទេសកម្ពុជា និងជាមិត្តភក្តិដ៏ជិតស្និទ្ធរបស់ប្រជាជនយើង ដែលបានរួមវិភាគទាន យ៉ាងធំធេងក្នុងការរីកចម្រើនទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការរវាងប្រជាជននៃប្រទេសទាំងពីរ កូរ៉េ-កម្ពុជា»។ **ឯកឧត្តម លោក Choe Yong-rim**

**នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិត ប្រជាធិបតេយ្យកូរ៉េ**



www.elibraryofcambodia.org



«ព្រះអង្គជាអ្នកដឹកនាំដ៏ឆ្នើមបំផុតនៃព្រះរាជាណាចក្រកម្ពុជាដែលបានលះបង់ព្រះកាយពល និងព្រះជន្មរបស់ព្រះអង្គដើម្បីបម្រើជាតិ។ ព្រះអង្គនឹងត្រូវបានចងចាំជាព្រះនិមិត្តរូបនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា»។

**ឯកឧត្តម Janos Ader**
**ប្រធានាធិបតីហុងគ្រី**



«ព្រះអង្គគឺជារដ្ឋបុរសដ៏ពិតប្រាកដដែលបានបូជាព្រះជន្មដើម្បីប្រទេស និងប្រជាជនកម្ពុជា។ ការសោយទិវង្គតរបស់ព្រះអង្គគឺជាការបាត់បង់ដ៏ធំធេងបំផុតរបស់ព្រះរាជាណាចក្រកម្ពុជា និងក្នុងតំបន់»។

**ឯកឧត្តម Najib Abdul Razak**
**នាយករដ្ឋមន្ត្រីម៉ាឡេស៊ី**



«ព្រះអង្គគឺជានិមិត្តរូបបញ្ជាក់ពីកម្ពុជានាសម័យបច្ចុប្បន្ន។ សមត្ថភាព ភាពទន់ភ្លន់ និងកម្លាំងពលំ អាកប្បកិរិយារបស់ព្រះអង្គត្រូវបានគេលើកសរសើរខ្ទរខ្ទារទៅក្រៅប្រទេសផងដែរ»។

**ឯកឧត្តម Jean Asselborn**
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេសលុចសំបួ**



«ព្រះអង្គគឺជាឥស្សរជនដឹកនាំដ៏ឆ្នើមមួយព្រះអង្គដែលបានតស៊ូដើម្បីសន្តិភាព និងសេរីភាព។ ព្រះអង្គបានបន្តការតស៊ូអស់មួយព្រះជន្មារបស់ព្រះអង្គដោយបានទទួលសំឡេងគាំទ្រពីប្រជារាស្ត្ររបស់ព្រះអង្គ»។

**ឯកឧត្តម Heinz Fischer ប្រធានាធិបតី**
**នៃសាធារណរដ្ឋសហព័ន្ធអូទ្រីស**



ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុវរ្ម័ន បានយាងចូលមកក្នុងរាជធានីភ្នំពេញវិញ លើចម្ងាយផ្លូវ ៣០០ គ.ម ដែលព្រះអង្គធ្វើដំណើរ ប្រជារាស្ត្រខ្មែរក្នុងក្ដីរំជួលចិត្តបានធ្វើឱ្យព្រះអង្គទទួលបាននូវជោគជ័យមួយដែលមិនធ្លាប់មានពីមុនមក។ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ គឺ ៨ ខែមុនសន្និសីទក្រុង ហ្សឺណែវ មានធ្វើពិធីមួយនៅមុខព្រះបរមរាជវាំង ដែលឧទ្ទិសចំពោះការដកថយ នៃអំណាចរបស់បារាំងពីប្រទេសកម្ពុជា ។

លោកឧត្តមសេនីយ៍ ឡង់ក្លាត បានប្រគល់យ៉ាងមហោឡារិកនូវអំណាចបញ្ជាការរបស់ខ្លួនថ្វាយព្រះរាជា។ កងទ័ព និងអគ្គសេនាធិការរបស់បារាំងបាន





www.elibraryofcambodia.org



ឯករាជ្យ ពីព្រះរាជាណាចក្រកម្ពុជា ។

ឯករាជ្យរបស់ខ្មែរបានក្លាយទៅជាឯករាជ្យអចិន្ត្រៃយ៍ និងទាំងស្រុង ។ វិបត្តិរវាងខ្មែរនិងបារាំងត្រូវបានបញ្ចប់។ ពពកខ្មៅចុងក្រោយដែលបិទបាំងមិត្តភាពខ្មែរបារាំងបានរលាយសាបសូន្យទាំងស្រុង បន្ទាប់ពីការទទួលស្គាល់ទាំងស្រុងពីប្រទេសបារាំងនៅ ខែធ្នូ ឆ្នាំ ១៩៥៤ លើអធិបតេយ្យទាំងមូលរបស់កម្ពុជាលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គណៈប្រតិភូខ្មែរ ដែលបញ្ជូនទៅក្រុងប៉ារីស ដោយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ដើម្បីស្នើឱ្យរដ្ឋាភិបាលបារាំង ទទួលស្គាល់ជាផ្លូវការ គឺត្រូវដឹកនាំដោយឯកឧត្តម ពាន់ ណាក បន្ទាប់ពីឯកឧត្តម បានទទួលមរណភាពនៅទីក្រុងប៉ារីសនោះ គណៈប្រតិភូខ្មែរត្រូវដឹកនាំដោយ ឯកឧត្តម ញឹក ជូឡុង និងនៅចុងក្រោយបង្អស់ដឹកនាំដោយ ឯកឧត្តម អូ ឈឿន ដែលនៅពេលនោះ ជាឧបនាយករដ្ឋមន្ត្រី និងចូលរួមដោយឯកឧត្តម សឺន សាន ។

នៅខែកក្កដា ឆ្នាំ១៩៥៤ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅ





«ព្រះបាទ នរោត្តម សីហនុ នឹងត្រូវបានគេចងចាំ និងគោរពកោតសរសើរចំពោះព្រះរាជប្តេជ្ញាភារកិច្ចក្នុងមួយជីវិតរបស់ព្រះអង្គចំពោះប្រជាជន និងប្រទេសជាតិកម្ពុជា។ យើងខ្ញុំទាំងអស់គ្នានៅក្នុងប្រទេសឥណ្ឌា សូមថែរក្សាចំណងមិត្តភាពដ៏ពិសេសរបស់ព្រះអង្គជាមួយនឹងថ្នាក់ដឹកនាំឥណ្ឌាច្រើនជំនាន់ដែលក្នុងនោះរួមមានទាំងឯកឧត្តម Pandit Jawaharla Nehru (អតីតប្រធានាធិបតីឥណ្ឌា) និងលោកជំទាវ Indira Gandhi (អតីតនាយករដ្ឋមន្ត្រីឥណ្ឌា) ដែលបានរួមគ្នាជាមួយព្រះអង្គនាំមកនូវសន្តិភាពដល់តំបន់របស់យើង»។

**ឯកឧត្តមបណ្ឌិត Manmohan Singh**
**នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋឥណ្ឌា**



«ក្នុងវិស័យទំនាក់ទំនងជាមួយប្រទេសជប៉ុន ព្រះអង្គបានកសាងគ្រឹះ នៃទំនាក់ទំនងមិត្តភាពរវាងប្រទេសយើងទាំងពីរ សម្រាប់អនាគតដោយបានធ្វើព្រះរាជកិច្ចដូចជា ការយាងមកបំពេញព្រះរាជដំណើរទស្សនកិច្ចជាផ្លូវរដ្ឋនៅប្រទេសជប៉ុន នៅឆ្នាំ១៩៥៥ ហើយបានយល់ដឹងយ៉ាងជ្រាលជ្រៅជាទីបំផុតអំពីវិភាគទានរបស់ប្រទេស ជប៉ុន ក្នុងដំណើរការស្វែងរកសន្តិភាពនៅប្រទេសកម្ពុជា»។

**ឯកឧត្តម Yoshihiko Noka**
**នាយករដ្ឋមន្ត្រីនៃប្រទេសជប៉ុន**



«ព្រះរាជវិភាគទានរបស់ ព្រះករុណា នរោត្តម សីហនុ ក្នុងការពង្រឹងចំណងមិត្តភាព និងសាមគ្គីភាពរវាងប្រទេសយើងទាំងពីរ ព្រមទាំងព្រះរាជសកម្មភាពជានិរន្តរ៍របស់ព្រះអង្គក្នុងបុព្វហេតុជួយរំដោះប្រជាជាតិចេញពីរបបអាណានិគម ការជួយគ្នាទៅវិញ ទៅមក និងកិច្ចសហប្រតិបត្តិការក្នុងពិភពលោកមួយសន្តិភាព នៅតែជិតជាប់ជានិច្ចក្នុងស្មារតីចងចាំរបស់ទូលព្រះបង្គំយើងខ្ញុំ»។ **ឯកឧត្តម Abdelaziz Bouteflika ប្រធានាធិបតី**
**នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតអាល់ហ្សេរី**



www.elibraryofcambodia.org



«ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ស្តេចទ្រង់បានយាងទៅជួបជុំជាមួយបុព្វបុរសរបស់ព្រះអង្គ។ ដោយព្រះអង្គជាបិតានៃរបបរាជានិយមដ៏ចំណាស់មួយក្នុងពិភពលោក ព្រះវររាជបិតាគឺជានិមិត្តរូប អភិបាលកិច្ចល្អក្នុងបរិយាកាសលទ្ធិប្រជាធិបតេយ្យ»។

**បណ្ឌិត Goodluck Ebele Azikiwe Jonathan ប្រធានាធិបតី អគ្គបញ្ជាការកងទ័ពនៃសាធារណរដ្ឋសហព័ន្ធ នីហ្សេរីយ៉ា**



«ព្រះបាទ នរោត្តម សីហនុ បានលះបង់ព្រះកាយពលដ៏ថ្លៃថ្លាពេញមួយព្រះជន្មរបស់ព្រះអង្គដើម្បីប្រជាជនកម្ពុជា។ ព្រះអង្គ បានតស៊ូយ៉ាងខ្ជាប់ខ្ជួនដើម្បីសុខមាលភាពប្រជារាស្ត្រខ្មែរ ទោះបីជានៅក្នុងកាលៈទេសៈលំបាកក៏ដោយ។ ព្រះរាជកិត្តិនាមរបស់ព្រះអង្គនឹងផ្សារភ្ជាប់ជានិច្ចជាមួយនឹងការសម្រេចបានឯករាជភាព ការអភិវឌ្ឍនៃរដ្ឋដ៏ទំនើប ការការពារអធិបតេយ្យភាពរបស់ប្រទេស និងចុងក្រោយបង្អស់គឺជ័យជម្នះលើក្រុមខ្មែរក្រហមដែលធ្លាប់បានបង្កការឈឺចាប់ និងភាពអយុត្តិធម៌យ៉ាងខ្លាំងមកលើប្រទេសរបស់ព្រះអង្គ»។

**ឯកឧត្តម Joachim Gauck ប្រធានាធិបតីនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**



«ប្រទេសវៀតណាមបានបាត់បង់នូវមហាមិត្តដែលជួយឧបត្ថម្ភដ៏មានតម្លៃ និងគាំទ្រ និងចែករំលែកចំណងមិត្តភាពដ៏ស្អិតល្មួតក្នុងអំឡុងការតស៊ូដ៏លំបាកដើម្បីឯករាជ្យជាតិ ក៏ដូចជាក្នុងបុព្វហេតុការកសាងជាតិ និងការអភិវឌ្ឍនៃប្រទេសនីមួយៗ។ សម្តេច នរោត្តម សីហនុ នឹងស្ថិតនៅក្នុងការចងចាំជានិច្ចរបស់បក្ស រដ្ឋ រដ្ឋសភា រដ្ឋាភិបាល និងប្រជាជនវៀតណាមចំពោះការរួមចំណែកដ៏ធំធេងរបស់ព្រះអង្គ»។

**ឯកឧត្តម Nguyen Tan Dung នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម**



ហ្សឺណែវ បានប្រព្រឹត្តទៅ ដោយរួមបញ្ចូលគូបដិបក្ខដែលមានវិវាទនៅឥណ្ឌូចិន ។ នៅសន្និសីទក្រុងហ្សឺណែវ ព្រះមហាក្សត្របានបញ្ជូន គណៈប្រតិភូមួយក្រុមដឹកនាំដោយឯ.ឧ ទេព ផន នៅពេលនោះជារដ្ឋមន្ត្រីការបរទេស និងមានឯ.ឧ ញឹក ជូឡុង ឯ.ឧ សម សារី ឯ.ឧ នង គឹមនី ឯ.ឧ សឺន សាន ។ល។ ដែលក្រោមការណែនាំពីព្រះមហាក្សត្របានដឹងថា សន្និសីទ ប្រកាសដកទ័ពរបស់ប្រទេសជិតខាងមួយចេញពីព្រះរាជាណាចក្រកម្ពុជា ។ ប្រទេសកម្ពុជាចេញពីសន្និសីទហ្សឺណែវនេះ «កម្ពុជា-១៩៥៤» ដោយគ្មានការខូចខាតអ្វីទាំងអស់។ ផ្ទុយពីប្រទេសឡាវ និងវៀតណាម ព្រះរាជាណាចក្រកម្ពុជាអាចចៀសវាងការបែងចែកទឹកដី ។

ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន ក្នុងរយៈពេលយ៉ាងតិច ៣ ឆ្នាំ ទើបអាចបំពេញនូវកិច្ចសន្យារបស់ព្រះអង្គចំពោះប្រជារាស្ត្រ ។ ប្រជារាស្ត្រខ្មែរ បានថ្វាយព្រះងារៈចំពោះព្រះអង្គថា ជាព្រះបិតាឯករាជ្យជាតិ ហើយតាមសំណូមពរ របស់តំណាងរាស្ត្រក្នុងក្របខ័ណ្ឌក្រុមប្រឹក្សាពិគ្រោះជាតិ រដ្ឋាភិបាលបានលើកព្រះអង្គជាវីរបុរសជាតិ [illegible]ព្រះមហាកិត្តិយសដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមរបស់ព្រះអង្គ ។



www.elibraryofcambodia.org

# សមិទ្ធផលសំខាន់ៗ នៅក្នុងសម័យ សង្គមរាស្ត្រនិយម

ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះអង្គក្នុងសម័យសង្គមរាស្ត្រនិយម ប្រជារាស្ត្របានថ្វាយព្រះនាមព្រះអង្គថាជា ព្រះបិតាឯករាជ្យជាតិ ព្រះបិតាសិក្សាធិការជាតិ ព្រះបិតាសុខាភិបាលជាតិ ព្រះបិតាស្ថាបនាជាតិ តាមរយៈសមិទ្ធផលធំៗដែលត្រូវបានកសាងឡើង និងប្រារព្ធព្រះរាជពិធីសម្ពោធជាបន្តបន្ទាប់។

សមិទ្ធផលទាំងនោះមានដូចជា៖

-វិមានឯករាជ្យ









«ព្រះអង្គគឺជាមហាបុរសជនដ៏ឆ្នើមដែលបានដឹកនាំកម្ពុជាឆ្លងកាត់ពេលវេលាដ៏លំបាកជាច្រើន ហើយបាននាំមកនូវសន្តិភាព និងស្ថិរភាពជូនព្រះរាជាណាចក្រកម្ពុជា។ ការយាងចូលទិវង្គតរបស់ព្រះអង្គគឺជាបាត់បង់ដ៏ធំធេងមិនចំពោះប្រជាជនកម្ពុជាប៉ុណ្ណោះទេ តែក៏ចំពោះប្រជាជនបង់ក្លាដែសដែលព្រះអង្គទទួលបាននូវការគោរពដ៏ជ្រាលជ្រៅ»។

**លោកជំទាវ Sheikh Hasina**

**នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស**



«សិង្ហបុរីនឹងមិនបំភ្លេចតួនាទីដ៏សំខាន់របស់ព្រះមហាវីរក្សត្រដែលបានទ្រទ្រង់មិត្តភាពស្អិតស្មួររវាងប្រទេសទាំងពីរ។ កម្ពុជាគឺជាមិត្តភក្តិដ៏ជិតស្និទ្ធរបស់សិង្ហបុរី ហើយយើងចងចាំដោយដឹងគុណថា កម្ពុជាជាប្រទេសទីមួយដែលទទួលស្គាល់សាធារណរដ្ឋថ្មីរបស់យើង ក្នុងពេលសិង្ហបុរីបានទទួលឯករាជ្យនៅឆ្នាំ១៩៦៥»។

**ឯកឧត្តម Lee Hsien Loong**

**នាយករដ្ឋមន្ត្រីសិង្ហបុរី**



«ព្រះអង្គជាអ្នកនយោបាយដ៏ឆ្នើម ដែលបានដឹកនាំប្រទេសកម្ពុជាទទួលបានឯករាជ្យ។ ដោយសារព្រះរាជកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លារបស់ព្រះអង្គ ព្រះរាជាណាចក្រកម្ពុជាបានក្លាយជាប្រទេសមួយល្បីល្បាញនៅក្នុងសាធារណរដ្ឋឆែក»។

**ឯកឧត្តម Vaclav Klaus**

**ប្រធានាធិបតីនៃសាធារណរដ្ឋឆែក**



«ព្រះអង្គគឺជាថ្នាក់ដឹកនាំដ៏ប្រពៃ ហើយស្នាព្រះហស្តរបស់ព្រះអង្គនឹងត្រូវបានចងចាំជាពិសេសការរួមចំណែករបស់ព្រះអង្គចំពោះសន្តិភាព ស្ថិរភាពនិងអភិវឌ្ឍប្រទេស»។

**ស្តេចស៊ុលតង់ Hassnal Bolkiah**

**នៃប្រទេសប្រ៊ុយណេ**



www.elibraryofcambodia.org



«ព្រះអង្គនឹងស្ថិតនៅជាប់ក្នុងការចងចាំរបស់យើងទាំងអស់គ្នាដោយព្រះអង្គបានបំពេញព្រះរាជតួនាទីជាប្រវត្តិសាស្ត្រក្នុងការអភិវឌ្ឍកម្ពុជានាសម័យកាលថ្មី»។

**ឯកឧត្តម Rosen Plevneliev**
**ប្រធានាធិបតីនៃសាធារណរដ្ឋប៊ុលហ្គារី**



«រដ្ឋាភិបាល និងប្រជាជនម៉ុងហ្គោលីចងចាំជានិច្ចនូវការធ្វើព្រះរាជទស្សនកិច្ចក្នុងនាមព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជាឆ្នាំ១៩៦០ និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតនូវមូលដ្ឋានរឹងមាំសម្រាប់ចំណងមិត្តភាពទ្វេភាគីរវាងប្រទេសយើងទាំងពីរ»។

**ឯកឧត្តម Tsakhiagiin Elbegdorj**
**ប្រធានាធិបតីម៉ុងហ្គោលី**



«ភាពជាអ្នកដឹកនាំដ៏វិសាមញ្ញ ភាពក្លៀវក្លា និងព្រះរាជបញ្ញាញាណរបស់ព្រះអង្គ គឺជាគំរូធ្វើឲ្យព្រះអង្គមាន ព្រះរាជតួនាទីដ៏សំខាន់បំផុតក្នុងការដឹកនាំប្រទេសកម្ពុជាឆ្លងកាត់ស្ថានភាពប្រឈម និងភាពមិនច្បាស់លាស់ក្នុងអតីតកាល រហូតដល់ភាពជោគជ័យ និងវិបុលសុខជាតិនាពេលបច្ចុប្បន្ន»។

**លោកជំទាវ Yingluck Sinawatra**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ**



«ខ្ញុំមានសេចក្ដីសោកស្ដាយយ៉ាងជ្រាលជ្រៅ ដោយបានដឹងថា ព្រះករុណាព្រះបិតានរោត្តម សីហនុ បានសោយទិវង្គតដែលព្រះអង្គជាមហាមិត្តរបស់ប្រជាជនគុយបា»។

**ឯកឧត្តម Raul Castro Ruz**
**ប្រធានក្រុមប្រឹក្សារដ្ឋ**
**និងក្រុមប្រឹក្សារដ្ឋមន្ត្រីនៃប្រទេសគុយបា**

-វិមានរដ្ឋចំការមន (បច្ចុប្បន្ន ព្រឹទ្ធសភា)











-ចំណតអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង (បច្ចុប្បន្ន អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ)



www.elibraryofcambodia.org

www.elibraryofcambodia.org

# សាររំលែកព្រះបរមមរណទុក្ខ
# ពីសំណាក់ថ្នាក់ដឹកនាំ
# អង្គការអន្តរជាតិនានា



www.elibraryofcambodia.org

-ចំណតអាកាសយានដ្ឋាន
សៀមរាប
-ចំណតអាកាសយានដ្ឋាន
បែកចាន (ខេត្តបាត់ដំបង)
-ផ្លូវជាតិលេខ [illegible]
ព្រះសី[illegible]
-ផ្លូវដែកក្រុង[illegible]
ព្រះសី[illegible]

LA PREMIERE GARE DE [illegible]
PHNOM PENH - SIHANO[illegible]





Vue générale de la gare de Kep, sur la ligne Phnom Penh-Sihanoukville.





-កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ
-សណ្ឋាគារ "ឯករាជ្យ"
ក្រុងព្រះសីហនុ



«កេរដំណែលរបស់អតីតព្រះមហាក្សត្រ នឹងអនុញ្ញាតឲ្យព្រះរាជាណាចក្រកម្ពុជា បន្តឈានមុខក្នុងដំណើរការផ្សះផ្សាជាតិរួមទាំងតាមរយៈការបន្តប្តេជ្ញាចិត្តចំពោះយុត្តិធម៌»។

**លោក Ban Ki-Moon**
**អគ្គលេខាធិការអង្គការសហប្រជាជាតិ**



«តាងនាមធនាគារអភិវឌ្ឍន៍អាស៊ី ខ្ញុំសូមសម្តែងនូវមរណទុក្ខយ៉ាងក្រៀមក្រំជាមួយប្រជាជនកម្ពុជាចំពោះការសោយទិវង្គតរបស់ព្រះករុណាព្រះ នរោត្តម សីហនុ។ យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខជាពិសេសជាមួយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី និងព្រះញាតិវង្សានុវង្ស»។

**លោក Haruhiko Kuroda**
**ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី**



«ព្រះអង្គគឺជាមិត្តរបស់អង្គការអន្តរជាតិហ្វ្រង់[illegible]ចំពោះកិច្ចការដែលព្រះអង្គបានបំ[illegible]កបដោយភាពស្វាហាប់ ដោយក្តីសាទរ និងដោយមិនចេះនឿយហត់។ ការសោយទិវង្គតរបស់ព្រះអង្គគឺជាបាត់បង់ដ៏ធំធេងសម្រាប់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី និងសម្រាប់បុព្វហេតុដែលយើងបាន និងកំពុងបំពេញ ហើយទន្ទឹមគ្នានោះដែរ ក៏ជាការបន្តចំណងមិត្តភាពជាមួយមិត្តចាស់របស់ព្រះអង្គគឺ ឯកឧត្តម Léopold Sédar Senghor ដែលជាអ្នកស្នេហាជាតិ និងជាបុព្វការីថ្នាក់ដឹកនាំរបស់ប្រទេសសេណេហ្គាល់»។

**លោក Abdou DIOUF អគ្គលេខាធិការ**
**អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី**

www.elibraryofcambodia.org



«ការសោយទិវង្គតរបស់ព្រះអង្គ គឺជាការបាត់បង់ឥស្សរជនដ៏ឆ្នើមក្នុងប្រវត្តិសាស្ត្រកម្ពុជាដែលក្នុងនោះព្រះមហាវីរក្សត្រ បានភ្ជាប់វាសនាព្រះអង្គយ៉ាងជិតស្និទ្ធជាមួយនឹងប្រទេសជាតិ និងប្រជាពលរដ្ឋ»។

**លោក Herman Van Rompuy**
**ប្រធានក្រុមប្រឹក្សាអឺរ៉ុប**



«អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ព្រះវររាជបិតាបានដើរតួនាទីដ៏សំខាន់ក្នុងការផ្សារភ្ជាប់ទំនាក់ទំនងកម្ពុជាជាមួយនឹងសហគមន៍អន្តរជាតិ និងជាក្សត្រមួយអង្គដ៏ពិតប្រាកដក្នុងការគាំទ្រដល់ការអភិវឌ្ឍប្រទេសកម្ពុជា»។

**លោក Douglas Broderick អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា**



«ព្រះអង្គធ្លាប់ជាឥស្សរជនគួរឲ្យស្ញប់ស្ញែង និងមានសេចក្តីស្រឡាញ់ដែលព្រះអង្គបានភ្ជាប់វាសនាព្រះអង្គយ៉ាងជិតស្និទ្ធជាមួយនឹងប្រទេសជាតិ និងប្រជាជនក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ»។

**លោក Jose Manuel Barroso**
**ប្រធានគណៈកម្មការអឺរ៉ុប**



«ព្រះអង្គជាមេដឹកនាំដែលមានព្រះចក្ខុវិស័យវែងឆ្ងាយប្រកបដោយសុភវិនិច្ឆ័យ ហើយបានបង្ហាញនូវព្រះមេត្តាធម៌ជាគំរូចំពោះអ្នករស់នៅដែលមានផ្ទុកមេរោគហ៊ីវ»។

**លោក Michel Sidibé នាយកប្រតិបត្តិនៃអង្គការកម្មវិធីសហប្រជាជាតិស្តីពីមេរោគហ៊ីវ/អេដស៍**

LE THEATRE NATIONAL "PREAH SURAMARIT"
សាលមហោស្រពជាតិ "ព្រះសុរាម្រិត"





-សាលមហោស្រពជាតិ "ព្រះសុរាម្រិត" ភ្នំពេញ
-សាលសន្និសីទ "ចតុមុខ"
-ពហុកីឡដ្ឋានជាតិអូឡាំពិក ភ្នំពេញ

LE COMPLEXE SPORTIF NATIONAL
ពហុកីឡដ្ឋានជាតិ





UNE RÉALISATION MARQUANTE DU SANGKUM : LE PONT PREAH BAT MONIVONG



www.elibraryofcambodia.org



-ស្ពានព្រះមុនីវង្សទី ២
-ស្ពាន "សង្គមរាស្ត្រនិយម" ឆ្លងកាត់ទន្លេសាប
-សាកលវិទ្យាល័យ "សង្គមរាស្ត្រនិយម" ភ្នំពេញ
-សាកលវិទ្យាល័យភូមិន្ទបច្ចេកទេស
-សាលាភូមិន្ទរដ្ឋបាល
-មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
-មហាវិទ្យាល័យគរុកោសល្យ
-ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
-មហាវិទ្យាល័យសិល្បៈស្ថាបនា
-មហាវិទ្យាល័យសិល្បៈ និងមុខរបរ
-សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
-សាកលវិទ្យាល័យភូមិន្ទកសិកម្ម
-សាកលវិទ្យាល័យភូមិន្ទកំពង់ចាម
-សាកលវិទ្យាល័យភូមិន្ទបាត់ដំបង
-សាកលវិទ្យាល័យភូមិន្ទតាកែវ-កំពត
-រោងកាត់យន្តរដ្ឋ
-ស្ថានីយទូរទស្សន៍ខេមរភូមិន្ទ



«ព្រះករុណាព្រះបាទព្រះ នរោត្តម សីហនុ តែងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជានិច្ចជាមួយយូណេស្កូដែលធ្វើឲ្យបាននូវសមិទ្ធផលធំៗដូចជាយុទ្ធនាការដើម្បីរក្សាការពារប្រាសាទអង្គរវត្ត និងការចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនាឆ្នាំ១៩៩២»។

**លោក Kishore Rao នាយកមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោកថ្នែកវប្បធម៌**



«ភក្តីភាពរបស់ព្រះអង្គចំពោះប្រទេសជាតិ និងប្រជារាស្ត្ររបស់ព្រះអង្គ គឺអនុលោមតាមមាគ៌ាដែលពុទ្ធបរិស័ទត្រូវប្រណិប័តន៍តាមព្រះធម៌ដ៏ប្រសើរថ្លៃថ្លារបស់ព្រះពុទ្ធជាម្ចាស់។ ព្រះអង្គគឺជាក្សត្រដ៏ឧត្តុង្គឧត្តមដែលដឹកនាំមនុស្សទៅកាន់សន្តិភាព ភាពសុខសាន្ត និងវិបុលភាព។ ព្រះអង្គស័ក្តិសមនឹងទទួលព្រះបរមងារកិត្តិយសកំពូល ជាព្រះរាជបិតាព្រះពុទ្ធសាសនាពិភពលោកដែលពុទ្ធបរិស័ទទូទាំងសកលលោកឧទ្ទិសថ្វាយព្រះអង្គ»។

**មហាព្រះតេជគុណ បណ្ឌិត Kyuse Enshinjoh ប្រធានកិច្ចប្រជុំកំពូលព្រះពុទ្ធសាសនាពិភពលោក**



«ព្រះអង្គបានបង្កើតឲ្យមានសម័យកាលដ៏សំខាន់ក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា តាមរយៈការស្រោចស្រង់ប្រជាជនឲ្យរួចផុតពីឆ្នាំដ៏ច្របូកច្របល់ទៅកាន់ភាពទាន់សម័យ។ កិច្ចការមនុស្សធម៌ និងសមត្ថភាពជាច្រើនរបស់សម្តេចព្រះវររាជបិតានរោត្តម សីហនុ ទទួលបាននូវការកោតសរសើរជាខ្លាំង។ ព្រះអង្គទទួលបាននូវការស្រឡាញ់ និងការគោរពជានិច្ចពីសំណាក់ប្រជាជនកម្ពុជា»។

**លោកស្រី Christine Beerli អនុប្រធានកាកបាទក្រហមអន្តរជាតិ**



www.elibraryofcambodia.org

យោងតាមគេហទំព័រ

norodomsihanouk.info, norodomsihamoni.info,

គេហទំព័រទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួងការបរទេស សាររំលែកព្រះរាជមរណទុក្ខដ៏ច្រើនលើសលប់ត្រូវបានផ្ញើមកកាន់ស្ថាប័នគ្រប់លំដាប់ថ្នាក់ ព្រះមហាក្សត្រ រដ្ឋាភិបាល ក្រសួង និងស្ថាប័នជំនាញនានា។ ឥស្សរជននៅលើពិភពលោកដែលចូលរួមរំលែកព្រះរាជមរណទុក្ខ រួមមាន ព្រះមហាក្សត្រ ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ថ្នាក់ដឹកនាំស្ថាប័នជំនាញ ថ្នាក់ដឹកនាំអង្គការអន្តរជាតិ រួមទាំងអតីតថ្នាក់ដឹកនាំបរទេសនានា ដែលធ្លាប់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសម្ដេចឪ។

ខាងក្រោមនេះ គ្រាន់តែឈ្មោះឥស្សរជនបរទេសមួយចំនួនប៉ុណ្ណោះ៖

ឯកឧត្ដម Vaclav Klaus ប្រធានាធិបតីនៃសាធារណរដ្ឋឆែក, ឯកឧត្ដម Heinz Fischer ប្រធានាធិបតីនៃសាធារណរដ្ឋអូទ្រីស, ឯកឧត្ដម Abdelaziz Bouteflika ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិត អាល់ហ្សេរី, ឯកឧត្ដម Pranab Kumar Mukherjee ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌា, ឯកឧត្ដម Vladimir Putin ប្រធានាធិបតីនៃសហព័ន្ធរុស្ស៊ី, ឯកឧត្ដម Rosen Pleveneliev ប្រធានាធិបតីនៃសាធារណរដ្ឋប៊ុលហ្គារី, លោកជំទាវ Quentin Bryce AC អគ្គទេសាភិបាលអូស្ត្រាលី, ព្រះអង្គម្ចាស់ និងព្រះអង្គម្ចាស់ក្សត្រី Akishino នៃប្រទេសជប៉ុន, ឯកឧត្ដម Choymmaly Sayasone ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ, ព្រះមហាក្សត្រ Juan Carlos R នៃរាជាណាចក្រអេស្ប៉ាញ, ឯកឧត្ដម U Thein Sein ប្រធានាធិបតីនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា, ព្រះមហាក្សត្រិយានី Elizabeth II ព្រះមហាក្សត្រីនៃចក្រភពអង់គ្លេស លោក ជំទាវ Eveline Widmer-Schlumpf ប្រធានាធិបតីនៃសហព័ន្ធស្វ៊ីស, អ្នកអង្គម្ចាស់ Tamim Bin Hamad Al-Thani រាជទាយាទនៃរដ្ឋកាតា, ព្រះចៅអធិរាជ Akihito នៃប្រទេសជប៉ុន, ព្រះបាទ Bhumibol Adulyadej ព្រះមហាក្សត្រនៃរាជាណាចក្រថៃ, ឯកឧត្ដម Lee Myunk-Bak ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ, ព្រះចៅ Abdul Halim នៃប្រទេសម៉ាឡេស៊ី, ឯកឧត្ដម Michael Chilufya Sata ប្រធានាធិបតីនៃសាធារណរដ្ឋហ្សំប៊ី...។






www.elibraryofcambodia.org

www.elibraryofcambodia.org

# សកម្មភាពចូលគោរព
# ព្រះវិញ្ញាណក្ខន្ធ
# របស់
# ថ្នាក់ដឹកនាំបរទេស
# និងអង្គការអន្តរជាតិនានា



www.elibraryofcambodia.org





លោកជំទាវ Yingluck Shinawatra
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ



ឯកឧត្តម Lee Hsien Loong
នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសិង្ហបុរី



ឯកឧត្តម Nguyen Tan Dung
នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម



www.elibraryofcambodia.org



ឯកឧត្តម Sai Mauk Kham

អនុប្រធានាធិបតីសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា



ឯកឧត្តម Thongsing Thammavong នាយករដ្ឋមន្ត្រី

នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ



លោក Surin Pitsuwan

អគ្គលេខាធិការសមាគមអាស៊ាន



-មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

-រោងចក្រចម្រាញ់ប្រេងកាត

ក្រុងព្រះសីហនុ

-រោងចក្រស្រាបៀរក្រុងព្រះសីហនុ

-រោងចក្រ "ព្រះនរោត្តម"

ដំឡើងគ្រាក់ទ័រ និងរថយន្តធំ

ក្រុងព្រះសីហនុ

-រោងចក្រស្ករស កំពង់ត្រាំ

ខេត្តកំពង់ស្ពឺ

-រោងចក្រវាយនភណ្ឌ

ខេត្តកំពង់ចាម

-រោងចក្រវាយនភណ្ឌ





www.elibraryofcambodia.org

ខេត្តបាត់ដំបង

-រោងចក្របាវក្រចៅ ជូនទាវ

ខេត្តបាត់ដំបង

-រោងចក្រស៊ីម៉ងត៍ចក្រីទីង

ខេត្តកំពត

-រោងចក្រកែវជើងឯក

រាជធានីភ្នំពេញ

-រោងចក្រក្លាបេន្ទះដីឥដ្ឋ

ខេត្តកណ្ដាល

-រោងចក្រក្រដាសឆ្លូង ខេត្តក្រចេះ

-រោងចក្រជីផូស្វាតទូកមាស





ឯកឧត្តម Yang Hyong-Sop អនុប្រធានគណៈប្រធានសភាប្រជាជន
ជាន់ខ្ពស់នៃសាធារណរដ្ឋ ប្រជាមានិតប្រជាធិបតេយ្យកូរ៉េ



ស្ដេចស៊ុលតង់ Haji Hassanal Bolkiah
នាយករដ្ឋមន្ត្រីនៃរាជាណាចក្រ ប្រ៊ុយណេដា រូសាឡឹម



ឯកឧត្តម Haruhiko Kuroda
ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី



www.elibraryofcambodia.org



ឯកឧត្តម John Phillip Key
នាយករដ្ឋមន្ត្រីនៃប្រទេសនូវែលសេឡង់



លោកជំទាវ Julia Gillard
នាយករដ្ឋមន្ត្រីនៃប្រទេសអូស្ត្រាលី



ឯកឧត្តម Manmohan Singh
នាយករដ្ឋមន្ត្រីនៃប្រទេសឥណ្ឌា

ខេត្តកំពត
-រោងចក្រកង់ឡានតាខ្មៅ
ខេត្តកណ្ដាល









www.elibraryofcambodia.org

www.elibraryofcambodia.org

# ទស្សនៈរបស់ប្រព័ន្ធផ្សព្វផ្សាយ
# នានាដែលសរសេរជាភាសាខ្មែរ
# ទាក់ទងនឹងគុណសម្បត្តិរបស់
# សម្តេចព្រះវររាជបិតា
# ព្រះបាទ ព្រះនរោត្តម សីហនុ



www.elibraryofcambodia.org

-រោងចក្រត្រីខប្រអប់ ខេត្តកោះកុង
-រោងចក្រផលិតជ័រកៅស៊ូជប់
ខេត្តកំពង់ចាម
-រោងចក្រភឹមអុត្តិសនីគិរីរម្យ
ខេត្តកំពង់ស្ពឺ។
និងសមិទ្ធផលនានាជាច្រើន
ទៀតនៅតាមបណ្តាស្រុក ខេត្ត ក្រុង
ដូចជាសាលារៀន មន្ទីរពេទ្យ
ទំនប់ទឹក ស្រះទឹក ប្រឡាយ ផ្លូវ
ថ្នល់ ស្ពាន ជាដើម។ល។






ព្រះមហាវីរក្សត្រគឺជា
ស្មារមួយព្រះអង្គដែលផ្តល់
នូវព្រះតំរូដ៏មានតម្លៃឥត
គណនាសម្រាប់អ្នក
សារព័ត៌មានកម្ពុជារៀនសូត្រតាម។

**លោក ប៉ែន សមិទ្ធិ ប្រធានក្លឹបអ្នកកាសែតកម្ពុជា**

មេដឹកនាំខ្មែរ និងអ្នកនយោ
បាយខ្មែរពីគ្រប់និន្នាការត្រូវយក
គំរូតាមព្រះមហាវីរក្សត្រក្នុងការ
ដឹកនាំប្រទេសជាតិដើម្បីឲ្យប្រជា
ពលរដ្ឋគោរពស្រឡាញ់ និងរំឭកពីគុណបំណាច់ជារៀងរហូត។

**មនសិការខ្មែរ**

សម្រាប់ប្រជារាស្ត្រកម្ពុជាគ្រប់
គណបក្ស និងនិន្នាការនយោបាយ
តែងតែចាត់ទុកព្រះអង្គជា
និមិត្តរូបនៃការបង្រួបបង្រួមជាតិ
ផ្សះផ្សាជាតិ និងជាព្រះបិតា
ឯករាជ្យជាតិខ្មែរជាប់ជានិច្ច។ បើទោះបីជាព្រះអង្គយាងចូលទិវង្គត
ក្តី ក៏ព្រះរាជបូជនីយកិច្ចដើម្បីជាតិដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គ
ដិតជាប់ជានិរន្តរ៍ក្នុងដួងចិត្តកូនចៅខ្មែរគ្រប់រូប។ **ភ្នំពេញ ប៉ុស្តិ៍**

ស្នាព្រះហស្តរបស់ព្រះអង្គ
មានដូចជាការដណ្តើមឯករាជ្យ
ពីប្រទេសបារាំង និងការ
ទាមទារយកប្រាសាទ ព្រះវិហារ
និងខេត្តមួយចំនួនទៀតពីប្រទេស
ថៃប្រគល់ឲ្យប្រជាជាតិខ្មែររបស់ព្រះអង្គវិញ។ ក្រៅពីស្នាព្រះហស្ត
ដ៏សំខាន់ៗនេះ ព្រះអង្គបានបំពេញតួនាទីដ៏សំខាន់មួយទៀតក្នុង
ការផ្សះផ្សាជាតិខ្មែរដែលបានបែកបាក់នោះឡើងវិញ។

**ខ្មែរម្ចាស់ស្រុក**



www.elibraryofcambodia.org

នយោបាយផ្សះផ្សាបង្រួបបង្រួមជាតិ គឺជាមរតកដែលគេបានលើកយកមកនិយាយញឹកញាប់ជាងគេ ចាប់តាំងពីការសោយទិវង្គតរបស់សម្តេចព្រះនរោត្តម សីហនុ កាលពីថ្ងៃទី១៥តុលាមក។ មិនថាអ្នកនយោបាយ សង្គមស៊ីវិល ឬមហាជនទូទៅឡើយពួកគេបាននិយាយស្ទើរតែគ្រប់មាត់ថា គេគួរតែអនុវត្តនយោបាយផ្សះផ្សាបង្រួបបង្រួមជាតិ ប្រសិនណាបើគេពិតជាគោរពស្រឡាញ់ និងចង់ដើរតាមព្រះរាជតម្រិះសម្តេចឪមែន។ **វិទ្យុបារាំងអន្តរជាតិ**

ព្រះរាជកិច្ចដ៏ធំធេងទោះមោយរលត់ទៅហើយក៏ប្រជាពលរដ្ឋខ្មែរមិនអាចបំភ្លេចបានទោះ គឺព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យជាតិពីអាណាព្យាបាលបារាំង ការទាមទារធ្វើជាម្ចាស់ស្របច្បាប់ពីកណ្តាប់ដៃសៀមលើប្រាសាទព្រះវិហារ និងតំបន់ជុំវិញ ការទាមទារខេត្តទាំង៤ពីកណ្តាប់ដៃសៀមទទួលបានជោគជ័យគឺខេត្តបាត់ដំបងសៀមរាប កំពង់ធំ និងស្ទឹងត្រែង និងជាស្ថាបនិករួមជាមួយសម្តេចតេជោ ហ៊ុន សែន បង្កើតឱ្យខ្មែរគ្រប់ភាគីរួបរួមគ្នា គឺកិច្ចចរចាសន្តិភាពក្រុងប៉ារីស។ **កោះសន្តិភាព**

សម្រាប់ប្រជាពលរដ្ឋខ្មែរភាគច្រើន សម្តេចនរោត្តម សីហនុ មិនមែនគ្រាន់តែជាតួអង្គក្សត្រមួយអង្គដូចក្សត្រដទៃនោះទេ។ នៅក្នុងបេះដូងរបស់ពួកគេ ព្រះអង្គគឺជាអង្គក្សត្រអច្ឆរិយមួយអង្គ។ អច្ឆរិយមានតាំងពីព្រះអង្គនៅមានព្រះជន្មក្មេងខ្ចីម្ល៉េះ។ កាលពីសង្គមចាស់តែងតែគិតថា ព្រះអង្គជាមនុស្សមានបុណ្យមានបារមី អឺចឹងហើយ ទើបពេលព្រះអង្គយាង ទៅខេត្តណាឬទីណា ពេលនោះ មេឃនឹងស្រទំ ឬមេឃរកកលនឹងភ្លៀង។ មេឃស្រទំឬរកកលនឹងភ្លៀង មានន័យថា ព្រះអង្គជាមនុស្សត្រជាក់ត្រជុំ។ **គេហទំព័រថ្មីថ្មី**

SOUVENIRS SRN (suite).

Je me permets, dans le présent "ALBUM", de montrer, avec des images "éloquentes" à l'appui, que notre CAMBODGE au temps du SANGKUM REASTR NIYUM (années 1960), était très fort et "very successful" au plan international en matière de sports, athlétisme, cultures etc... organisation d'une jeunesse saine, unie, enthousiaste, vraiment patriote.













www.elibraryofcambodia.org

## ព្រះរាជសកម្មភាព សម្តេចឪនៅក្នុង វិស័យភាពយន្ត



ក្រៅពីកិច្ចការនយោបាយ និង សង្គមកិច្ច ព្រះករុណាព្រះបាទសម្តេច ព្រះ នរោត្តម សីហនុ ក៏ត្រូវបានកូនចៅ របស់ព្រះអង្គចាត់ទុកជាព្រះមហាក្សត្រ ផ្នែកសិល្បៈដ៏ឆ្នើមផងដែរ ពោលគឺ ព្រះរាជសកម្មភាពរបស់ព្រះអង្គក្នុង វិស័យមួយនេះ មានតាំងពីសម័យសង្គម រាស្ត្រនិយមរហូតដល់សម័យបច្ចុប្បន្ន។

យោងតាមឯកសារនានា ជាពិសេស គេហទំព័រផ្ទាល់របស់ព្រះអង្គ (www.norodomsihanouk.info) ខ្សែភាពយន្ត ទាំងខ្នាតខ្លី ខ្នាតវែង និងភាពយន្តឯកសារដែលជាព្រះរាជ និពន្ធ និងដឹកនាំដោយព្រះអង្គផ្ទាល់ មានចំនួនជាង៥០រឿង។ រឿងមួយ ចំនួនត្រូវបានទទួលស្គាល់ជាអន្តរជាតិ តាមរយៈការចូលរួមក្នុងមហោស្រព ភាពយន្តនានា។

The CAMBODIA DAILY

ការបញ្ចប់យុគសម័យ ព្រះនរោត្តម សីហនុ។ អតីតព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហនុ ទ្រង់បានទាម ទារឯករាជ្យពីប្រទេសបារាំង បានដោយជោគជ័យនៅឆ្នាំ១៩៥៣ និងបានតស៊ូដឹកនាំបញ្ចប់សង្គ្រាមត្រជាក់នៅឆ្នាំ១៩៨០ នៅ ប្រទេសកម្ពុជា ហើយរយៈពេល១០ឆ្នាំក្រោយមក ប្រជាជនកម្ពុជា ទាំងអស់បានស្គាល់អំពីសុខសន្តិភាពនៅក្នុងប្រទេសទាំងមូល។

**ឌឹ ខេមបូឌា ដេលី**

sabay
Knong Dai Neak

សង្គមរាស្ត្រនិយម ត្រូវបាន គេចាត់ទុកថាជាយុគសម័យ មាសរបស់កម្ពុជា ក្រោយពេល ប្រទេសមួយនេះរួចផុតពីនឹម អាណានិគមនិយមបារាំង និងការដួលរលំសម័យអង្គរ។ ក្រោម ព្រះរាជដឹកនាំប្រកបដោយប្រាជ្ញាញាណរបស់អតីតព្រះមហា វីរក្សត្រខ្មែរ ព្រះករុណា សម្តេចព្រះបាទ ព្រះនរោត្តម សីហនុ ព្រះ អង្គបានយកព្រះរាជហឫទ័យទុកដាក់លើការកសាង ហេដ្ឋារចនាសម្ព័ន្ធស្ទើរគ្រប់វិស័យ ដែលបម្រើឲ្យសង្គម និងប្រទេសជាតិទាំងមូល។ **គេហទំព័រសប្បាយ**

រស្មីកម្ពុជា
RASMEI KAMPUCHEA DAILY NEWSPAPER

ព្រះវីរភាពរបស់សម្តេចឪ សម្តេចព្រះ នរោត្តម សីហនុ ក៏បានដឹកនាំប្រទេសកម្ពុជា ស្គាល់ភាពរីកចម្រើនខាង ឧស្សាហកម្ម ក្នុងសម័យសង្គមរាស្ត្រនិយម ( ចន្លោះពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៧០ ) ព្រមទាំងព្រះអង្គ ចូលរួមជាមួយសម្តេច ហ៊ុន សែន ដើម្បីស្វែងរកសន្តិភាពដល់ប្រទេសកម្ពុជា ដែលនាំដល់ការចុះកិច្ច ព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស នៅថ្ងៃ២៣ តុលា ឆ្នាំ១៩៩១ និងការបោះឆ្នោតជាតិ ក្នុងសម័យព្រះរាជាណាចក្រ កម្ពុជា ឆ្នាំ១៩៩៣។

**រស្មីកម្ពុជា**



www.elibraryofcambodia.org

សមិទ្ធផលសម័យ សង្គមរាស្ត្រនិយម ក្រោមស្នាព្រះហស្តដឹកនាំរបស់សម្តេចឪ ព្រះបាទ នរោត្តម សីហនុ ពុំមានពេលណាដែលប្រជារាស្ត្រកម្ពុជា អាចបំភ្លេចបានឡើយ ។ រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ដែលមានសម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី បានយកគំរូ តាមការដឹកនាំរបស់សម្តេចឪ ធ្វើឱ្យព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នមានការរីកចម្រើនលើគ្រប់វិស័យ ជីវភាពរស់នៅរបស់ប្រជារាស្ត្រ កាន់តែល្អប្រសើរជាលំដាប់ទាំង នៅក្នុងរាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុងទូទាំងប្រទេស។ **គេហទំព័រដើមអម្ពិល**

ព្រះបាទ នរោត្តម សីហនុ ជាព្រះមហាក្សត្រដែលបានដឹកនាំគ្រប់គ្រងប្រទេសកម្ពុជាឲ្យបានទទួលឯករាជ្យពេញលេញពីប្រទេសបារាំង ក្នុងឆ្នាំ១៩៥៣ និងបានធ្វើឲ្យប្រទេសកម្ពុជាមានឈ្មោះល្បីល្បាញលើពិភពលោក ថាជាប្រទេសមានការរីកចម្រើនលើគ្រប់វិស័យ ប្រជាពលរដ្ឋមានជីវភាពធូរធាររហូតដល់ប្រជាពលរដ្ឋបានហៅព្រះអង្គថាជាសម្តេចឪ ទៀតផង។ **វិទ្យុអាស៊ីសេរី**

ក្រៅពីចាកជីវិតដែលបែងចែករវាងនយោបាយ និងការគ្រងរាជ្យ អតីតព្រះមហាក្សត្របានសាងស្នាព្រះហស្តដែលនឹងស្ថិតនៅជាអមតៈក្នុងប្រជាជាតិខ្មែរគឺការដណ្តើមឯករាជ្យពីអាណានិគមនិយមបារាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ បារាំងត្រួតត្រាកម្ពុជាអស់រយៈពេល៩០ឆ្នាំ។ **វិទ្យុសំឡេងសហរដ្ឋអាមេរិក**

ការតស៊ូរបស់ព្រះអង្គបានធ្វើឱ្យប្រទេសលែងត្រូវជាប់ពាក់ព័ន្ធនឹងប្រាសាទព្រះវិហារមកខ្មែរវិញនៅឆ្នាំ១៩៦២ ហើយព្រះអង្គក៏ជាតួអង្គសំខាន់សម្រាប់ការផ្សះផ្សាជាតិ ដែលឈានទៅរកការចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅឆ្នាំ ១៩៩១ រួមទាំងការបោះឆ្នោតជាតិនៅឆ្នាំ១៩៩៣ផងដែរ។ **ទូរទស្សន៍ហង្សមាស**

កាលពីឆ្នាំ២០០៧ ក្រុមអ្នករៀបចំទិវាភាពយន្តឯករាជ្យអន្តរជាតិនៅទីក្រុងប្រ៊ុចសែល បានផ្តល់ពានរង្វាន់ដល់ព្រះអង្គ «Lifetime Achievement Award» ។

ព្រះវររាជបិតាធ្លាប់បានលើកឡើងថាស្នាព្រះហស្តភាពយន្តរបស់ព្រះអង្គគឺបង្ហាញពីក្តីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ព្រះអង្គចំពោះប្រទេសជាតិ និងប្រជារាស្ត្រ។ ភាពយន្តភាគច្រើននិយាយប្រវត្តិ អតីតកាល ឬបច្ចុប្បន្ន ទំនៀមទម្លាប់ ប្រពៃណី សីលធម៌ វិថីជីវិត ភាពសប្បាយ និងទុក្ខសោករបស់ប្រជាជនកម្ពុជា។

សម្តេចព្រះវររាជបិតាបានបញ្ជាក់ផងដែរ ក្នុងព្រះនាមជាព្រះប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ឬក៏ព្រះមហាក្សត្រ ព្រះអង្គមិនដែលប្រព្រឹត្តអំពើពុករលួយឡើយ។ ថវិកាសម្រាប់ការផលិតខ្សែភាពយន្តរបស់ព្រះអង្គគឺចន្លោះពី ២ម៉ឺនទៅ៧ម៉ឺនដុល្លារអាមេរិក តាមរយៈការឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ពីព្រោះភាពយន្តរបស់ព្រះអង្គមិនមែនសំដៅលើការធ្វើពាណិជ្ជកម្មនោះឡើយ។

ខាងក្រោមនេះគឺជាចំណងជើងនៃភាពយន្តមួយចំនួនរបស់ព្រះអង្គ ហើយរឿងមួយចំនួនត្រូវបានសម្តែងដោយព្រះអង្គផ្ទាល់ផងដែរ។

- អប្សរា (១៩៦៦)
- ព្រៃប្រសិទ្ធិ (១៩៦៦)
- ប្រជាកុមារ (១៩៦៧)
- សន្និប្រកាស (១៩៦៨)
- រស់ដោយសប្បាយ (១៩៦៨)



www.elibraryofcambodia.org





www.elibraryofcambodia.org

# ទស្សនៈរបស់បណ្តាសារព័ត៌មានអន្តរជាតិនានា
# បន្ទាប់ពីការយាងចូលទិវង្គត
# របស់សម្តេចព្រះវររាជបិតា
# ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ



www.elibraryofcambodia.org





សម្ដេចព្រះ នរោត្តម សីហនុ ជាព្រះមហាក្សត្រប្រកបដោយឥទ្ធិពល និងសមត្ថភាពដ៏អស្ចារ្យក្នុងការបត់បែនតាមនយោបាយ។ ក្រោមក្រសែចក្ខុរបស់មនុស្សទូទៅ ព្រះអង្គជាក្សត្រដែលបានធ្វើឲ្យពិភពលោកស្គាល់នូវព្រះរាជាណាចក្រដ៏តូចរបស់ព្រះអង្គដែលព្រះអង្គបានដឹកនាំអស់រយៈពេល ៦០ ឆ្នាំក្នុងប្រវត្តិសាស្ត្រមួយដែលពោរពេញទៅដោយការផ្លាស់ប្ដូរ។ **Courrier International**

*« Charismatique, [Norodom Sihanouk] était doué d'une remarquable capacité d'adaptation politique et, aux yeux du monde, finit par incarner le minuscule royaume qu'il domina de sa présence pendant soixante ans d'une histoire mouvementée»* ***Courrier International***

ប្រសូតរនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ សម្ដេច សីហនុ បានក្លាយជាបុគ្គលដែលទទួលបាននូវការគោរពស្រឡាញ់ក្នុងប្រទេសកម្ពុជា ក្នុងព្រះនាមជាព្រះបិតាឯករាជ្យជាតិ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ។ នាព្រះជន្ម១៩ព្រះវស្សា សម្ដេច សីហនុ ត្រូវបានអាណានិគមនិយមបារាំងលើកឲ្យឡើងសោយរាជ្យជាព្រះមហាក្សត្រកម្ពុជា ដោយពួកគេគិតថាស្ដេចវ័យក្មេងអង្គនេះជាបុគ្គលដែលងាយស្រួលបង្វែរ។ ទោះបីជាយ៉ាងណាក៏ដោយ សម្ដេច សីហនុ បានធ្វើឲ្យការរំពឹងទុកនេះ ខុសស្រឡះ និងបានជួយប្រទេសជាតិឲ្យបញ្ចប់របបអាណានិគមនិយមបារាំងក្នុងឆ្នាំ១៩៥៣។ ពីរឆ្នាំក្រោយមក ព្រះអង្គបានដាក់រាជ្យ និងបានផ្ទេរអំណាចថ្វាយព្រះបិតា ព្រះបាទ ព្រះនរោត្តម សុរាម្រិត។ បន្ទាប់មក អតីតព្រះមហាក្សត្រអង្គនេះ បានបង្កើតរបបសង្គមរាស្ត្រនិយម ហើយក្នុងរយៈពេលត្រឹមតែប៉ុន្មានខែប៉ុណ្ណោះ ព្រះអង្គបានក្លាយជានាយករដ្ឋមន្ត្រីរបស់កម្ពុជា។ **The China Daily**

*Born on Oct 31,1922,Sihanouk became revered in Cambodia as the Father of Independence,Territorial Integrity and Khmer Unification. At the age of 19, Sihanouk was installed as king by Cambodia's French colonial rulers, amid hopes that the mildmannered young man would be easily manipulated. However, Sihanouk proved less malleable than expected and helped to end French rule in1953. Two years later, he abdicated and transferred power to his father, Norodom Suramarit.The former king then established the Sangkum Reasniyum regime, becoming Cambodia's prime minister just a few months later.*

***The China Daily***









- គុណបបួកតោ (១៩៦៩)
- វាសនាអកុសល (១៩៦៩)
- MY VILLAGE OF DUSK (១៩៩២)
- UN CRESUS SAUVETEUR DE FEMMES PAUVERS (១៩៩៣)



www.elibraryofcambodia.org

ក្នុងចំណោមអ្នកដែលបានរំឭកព្រះវិញ្ញាណក្ខន្ធនៅភ្នំពេញ សម្តេច សីហនុ ត្រូវបានចងចាំថា ជាអ្នកដែលគិតគូរខ្វល់ដល់ប្រជារាស្ត្រទីទ័លក្រ និងគ្មានអំណាច។ អ្នកស្រី សោម ស្រីពៅ វ័យ ៤៩ឆ្នាំដែលបានធ្វើដំណើរទៅកាន់ព្រះបរមរាជវាំងជាមួយកូនបីនាក់ ដើម្បីប្រារព្ធពិធីកាន់ព្រះរាជមរណទុក្ខបាននិយាយថា «សម្តេចឪបានធ្វើគ្រប់បែបយ៉ាងសម្រាប់ប្រជារាស្ត្រ។ ព្រះអង្គបានបូជាព្រះកាយរបស់ព្រះអង្គដើម្បីប្រជារាស្ត្រ»។ ***The New York Times***

*Among mourners in Phnom Penh, King Sihanouk was remembered mostly as someone concerned with the plight of the poor and powerless. "The king did everything for the people," said Som Srey Pao, 49, who traveled to the Royal Palace with her three children. "He sacrificed himself for the people."* ***The New York Times***

ពេញមួយព្រះជន្មរបស់ព្រះអង្គ ព្រះអង្គតែងតែធ្វើឲ្យគេស្មានមិនត្រូវជានិច្ច។ នៅឆ្នាំ ១៩៤១ ឧត្តមនាវី Decoux បានសម្រេចជ្រើសរើស ព្រះអង្គម្ចាស់ដ៏វ័យក្មេងអង្គនេះ ដែលចូលចិត្តធ្វើអ្វី តាមទំនើងចិត្ត ឲ្យឡើងគ្រងរាជសម្បត្តិជាជាងការលើកព្រះអង្គម្ចាស់ មុនីរ៉េត ដែលជាព្រះបិតុលារបស់ព្រះអង្គ ដោយលោកយល់ថា ខ្លួនអាចងាយគ្រប់គ្រងព្រះអង្គម្ចាស់ដ៏តូចនេះ ដែល សព្វព្រះទ័យនឹងឧបករណ៍តន្ត្រី Jazz និងស្រីស្អាតៗ ស្រាប់តែបួនឆ្នាំក្រោយមក ព្រះអង្គម្ចាស់ អង្គនេះប្រកាសទាមទារឯករាជ្យជូនកម្ពុជា ហើយព្រះអង្គបានទទួលនៅឆ្នាំ១៩៥៣។ សម្តេចសីហនុគឺជាមនុស្សដែលចូលចិត្តបោះជំហានទៅមុខដោយកាច់កុង បត់បែនយ៉ាងខ្លាំង ប៉ុន្តែឆ្ពោះទៅកាន់គោលដៅមួយជាក់លាក់ដដែល។

**La Croix**

*Toute sa vie, l'homme a surpris, agacé, déjoué les prévisions. Quand en 1941, l'amiral Decoux place ce jeune prince fantaisiste sur le trône de préférence à son oncle, le sévère prince Monireth, il pense pouvoir contrôler facilement cet adolescent amateur de jazz et de belles femmes. Quatre ans après, le jeune roi proclame l'indépendance du Cambodge. Il l'obtiendra en 1953. Sihanouk fait songer à ces organismes vivants qui avancent à coups de furieux zigzags, mais dont la trajectoire générale reste parfaitement rectiligne.* ***La Croix***









www.elibraryofcambodia.org







លោក Hu Jintao បានសម្តែងនូវការចូលរួមរំលែកព្រះរាជមរណទុក្ខចំពោះសម្តេចម៉ែ នរោត្តម មុនីនាថ សីហនុ ព្រះមហាក្សត្រ នរោត្តម សីហមុនី និងលោកនាយករដ្ឋមន្ត្រីហ៊ុន សែន។ លោកបានប្រកាសថា សម្តេចព្រះ នរោត្តម សីហនុ គឺជាអ្នកដឹកនាំកម្ពុជាដ៏ឆ្នើមមួយព្រះអង្គ និងជាមហាមិត្តរបស់ប្រទេសចិន។ លោកបានបន្តថា ព្រះអង្គបានពង្រឹងទំនាក់ទំនងចិន-កម្ពុជាក្នុងប្រវត្តិសាស្ត្រ ហើយព្រះរាជសកម្មភាពរបស់ព្រះអង្គនឹងស្ថិតក្នុងការចងចាំរបស់ប្រជាជនចិន។ **CCTV**

*"Hu Jintao a présenté ses condoléances à la reine-mère Norodom Monineath Sihanouk, au roi Norodom Sihamoni et au Premier ministre Hun Sen. Hu Jintao s'est dit attristé par le décès de Norodom Sihanouk qu'il a qualifié de dirigeant cambodgien brillant et grand ami de la Chine. Il a ajouté que le défunt avait apporté des contributions historiques au développement des relations sino-cambogdiennes et que ses actions demeureraient dans la mémoire du peuple chinois. »* **CCTV**

ជាឥស្សរជននយោបាយដ៏ឆ្នើមមួយអង្គក្នុងសតវត្សរ៍ទី២០ សម្តេចព្រះ នរោត្តម សីហនុ បានសោយទិវង្គត នៅទីក្រុងប៉េកាំង នៅប៉ុន្មានថ្ងៃមុនឈានចូលដល់ការចម្រើនព្រះជន្មគម្រប់ ៩០ព្រះវស្សារបស់ព្រះអង្គ។ ព្រះអង្គបានលេចធ្លោយ៉ាងខ្លាំងក្នុងឆាកអន្តរជាតិ នាសន្និសីទក្រុង Bandoung ដែលបានបង្កើតចលនាមិនចូលបក្សសម្ព័ន្ធក្នុងឆ្នាំ១៩៥៥ ជាមួយនឹងវត្តមានរបស់លោក Nasser លោក Tito លោក Nehru និងលោក Zhou Enlai ជាដើម។ ជាតួអង្គសំខាន់មួយអង្គក្នុងប្រវត្តិសាស្ត្រឥណ្ឌូចិនក្រោយសម័យអាណានិគម ព្រះអង្គតែងតែមានព្រះរាជវត្តមានទាំងក្នុងបណ្តាញសារព័ត៌មាន ទាំងក្នុងសមរភូមិ មិនថាផ្នែកប្រដាប់អាវុធ ឬការទូតនោះទេ។ **La Libre Belgique**

*« Avec la mort de Norodom Sihanouk, lundi, à Pékin, c'est une des dernières grandes figures politiques du XXe siècle qui a disparu, quelques jours avant son 90e anniversaire. Sihanouk fit sa grande entrée sur la scène internationale lors de la conférence de Bandoung, qui fonda le mouvement des Non-Alignés en 1955, aux côtés des Nasser, Tito, Nehru et autres Zhou Enlai. Personnage clé de l'histoire de l'Indochine post-coloniale, il fut tout aussi présent sur le terrain médiatique que sur les champs de bataille, qu'ils fussent militaires ou diplomatiques.* **La Libre Belgique**



www.elibraryofcambodia.org

www.news.cn 新华网 NEWS www.xinhuanet.com

សម្តេច ហ៊ុន សែន បានអរគុណដល់ប្រទេសចិនដែលបានរៀបចំយ៉ាងល្អសម្រាប់ព្រះបាទ សីហនុ។ សម្តេចបាននិយាយថា «ការយកចិត្តទុកដាក់របស់ចិនលើសម្តេចឪនាពេលជាច្រើនឆ្នាំកន្លងមក បានពង្រឹងចំណងមិត្តភាពកម្ពុជា-ចិន នៅក្នុងបេះដូងរបស់ប្រជាជនកម្ពុជា។ លោក Dai Bigguo ទីប្រឹក្សារដ្ឋចិន បានសម្តែងនូវការរំលែកទុក្ខ និងការសោកស្តាយចំពោះការសោយទិវង្គតរបស់សម្តេចឪ សីហនុ ដោយលោកបានចាត់ទុកព្រះអង្គជា «មហាមិត្តរបស់ប្រជាជនចិន»។ លោកបាននិយាយថា ប្រជាជនចិននឹងឈរនៅកៀកជាដកបជាមួយប្រជាជនកម្ពុជា ហើយលោកជឿជាក់ថាប្រជាជនកម្ពុជាអាចកសាងប្រទេសជាតិកាន់តែរីកចម្រើន បន្តពីសម្តេចឪ សីហនុ»។ **Xinhua**

*Hun Sen thanked China's meticulous arrangements for Sihanouk. "China's care for King-Father Sihanouk during the past years has erected a monument of Cambodia-China friendship in the hearts of the Cambodian people," he said. Chinese State Councillor Dai Bingguo expressed condolences and sympathy over the death of King-Father Sihanouk, commending the late king as "a great friend of the Chinese people." He said the Chinese people will firmly stand side by side with the Cambodian people and believes that the Cambodian people can build up a better country by inheriting King-Father Sihanouk's will.*

***Xinhua***

DW Deutsche Welle

លោក Julio Jeldres អ្នកសរសេរព្រះរាជជីវប្រវត្តិផ្លូវការរបស់សម្តេច សីហនុ បាននិយាយប្រាប់ Deutsche Welle តាមអ៊ីមែលថា អតីតព្រះមហាក្សត្រគឺជា «ថ្នាក់ដឹកនាំដ៏វៃឆ្លាត និងមានចក្ខុវិស័យខ្ពស់» ដោយព្រះអង្គបានបង្កើតទំនាក់ទំនងជាមួយប្រជារាស្ត្រនៅតាមជនបទៗ លោកបាននិយាយថា ការសោយទិវង្គតរបស់ព្រះអង្គ គឺជា «ការបញ្ចប់នៃយុគសម័យមួយ»។

***Deutshe Welle***

*"Julio Jeldres, Sihanouk's official biographer, told Deutsche Welle via email that the former king was "an extremely clever and visionary leader" who had established a rapport with Cambodia's rural population. He said his death marked "the end of an era."* ***Deutsche Welle***

LA FILMOGRAPHIE DE NORODOM SIHANOUK
DU CAMBODGE
LA FORET ENCHANTEE (1966)
(suite 2)



La Filmographie de Norodom Sihanouk
(suite 3)









www.elibraryofcambodia.org







ក្នុងរយៈពេលជាង៥០ឆ្នាំ ព្រះអង្គដែលមានចរិតលក្ខណៈចម្លែក សំឡេងខ្លាំង និងជាក្សត្រសព្វព្រះរាជហឫទ័យនឹងស្រាសំប៉ាញ ម្ហូបថ្លើមក្ងាន វិស័យភាពយន្ត តែងកំណាព្យ និងបទភ្លេង តែងតែប្រឡូកក្នុងឆាកការទូតអន្តរជាតិ បើទោះបីជាឥទ្ធិពលរបស់ព្រះអង្គ ជួនខ្លាំងក្លា ជួនថមថយក៏ដោយៗ ជាក្សត្រដែលនិយមភាសាបារាំង ព្រះអង្គមានព្រះរាជមោទនភាព ដែលជាអ្នកស្និទ្ធស្នាលនឹងឥស្សរជនល្បីៗទាំងឡាយនៅសម័យក្រោយសង្គ្រាម ដូចជាលោក Tito លោក Mao និងលោក De Gaulleៗ ព្រះអង្គកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះពួកលោកៗ សម្ដេចព្រះ នរោត្ដម សីហនុ ធ្លាប់បានហែលឆ្លងនូវការប្រើប្រាស់ពីសំណាក់អាណាព្យាបាល បារាំង ហែលឆ្លងនូវភាពអាម៉ាស់ក្នុងអំពើរដ្ឋប្រហារ ហែលឆ្លងនូវការចាប់បង្ខាំង ក្រោមរបបខ្មែរក្រហម និងការនិរទេសព្រះកាយៗ ព្រះអង្គត្រូវបានប្រជាពលរដ្ឋថ្វាយព្រះគោរមងារថា ជាអង្គ សម្ដេចឪ និងត្រូវបានគោរពដូចជាអាទិទេពៗ

***TV5 Monde***

*Pendant plus de 50 ans, le petit homme au caractère souvent déconcertant et à la voix haut perchée, grand amateur de champagne et de foie gras, cinéaste, poète et compositeur, s'est déployé inlassablement sur la scène diplomatique internationale en dépit d'une carrière à éclipses. Fier d'avoir côtoyé tous les grands de l'après-guerre, Tito, Mao et de Gaulle, qu'en francophone passionné il admirait profondément, Sihanouk a survécu aux manipulations de ses protecteurs français, à l'humiliation d'un coup d'Etat, à la captivité sous les Khmers rouges et à l'exil. Pour le petit peuple cambodgien qui le vénérait comme un demi-dieu, il était Samdech Euv, Monseigneur Papa.* ***TV5 Monde***

សម្ដេច សីហនុ នៅតែមានអ្នកការពារជាច្រើន ដោយរាប់បញ្ចូលទាំងអ្នកប្រវត្តិសាស្ត្រកម្ពុជាមួយចំនួនដែលបាន និយាយថា អ្វីដែលព្រះអង្គចង់បានគឺការធ្វើឲ្យបានល្អប្រសើរបំផុតសម្រាប់ប្រទេសរបស់ព្រះអង្គ ដែលក្នុងនោះរួមមានសន្តិភាព ឯករាជ្យ និងការទទួលស្គាល់នៅលើឆាកអន្តរជាតិៗ **AP**

*Sihanouk still has many defenders, including some Cambodian historians who argue he wanted what he thought was best for his country, including peace, independence and recognition on the world stage.* ***AP***



www.elibraryofcambodia.org

**Europe 1**

កែវភ្នែកសម្លឹងទៅទិសឆ្ងាយ ហាក់បង្កប់នូវភាពទុក្ខព្រួយ បុរសវ័យក្មេងម្នាក់ចាកចេញទៅ ដោយយឺតៗជាមួយនឹងឈើច្រត់ រួចបោះស្នាមញញឹមទៅកាន់កាមេរ៉ា។ នេះគឺជារូបភាពនៅក្នុងឆ្នាំ១៩៧០ ហើយតួអង្គគឺមិនមែនអ្នកណាក្រៅពីសម្តេចព្រះនរោត្តម សីហនុ ដែលជាអតីតព្រះមហាក្សត្រកម្ពុជា ហើយដែលបានសោយទិវង្គតក្នុងព្រះជន្មាយុ ៨៩ ព្រះវស្សានៅទីក្រុងប៉េកាំង។ ខ្សែភាពយន្តដែលមានចំណងជើងថា «សន្ធ្យាកាល» ដែលត្រូវបានរក្សាទុកដោយវិទ្យាស្ថាន INA បានបង្ហាញនូវតួអង្គមួយដែលមិនសូវល្បីល្បាញ ប៉ុន្តែការពិត គឺជាបុគ្គលដ៏ឆ្នើមក្នុងប្រវត្តិសាស្ត្រនៃសតវត្សរ៍ទី២០។ ព្រះអង្គបានដាក់រាជ្យចំនួនពីរដង ខណៈដែលការសោយរាជ្យរបស់ព្រះអង្គមានរយៈពេលសរុបជាង ៦០ ឆ្នាំ ហើយព្រះអង្គក៏ជាអ្នកស្នេហាវិស័យសិល្បៈដ៏ធំធេងផងដែរ។ **Europe 1**

*Le regard dans le vague, l'air contrit, un jeune homme s'éloigne lentement, appuyé sur une canne, avant de lancer un grand sourire à la caméra. Sur ces images datant de 1970, l'acteur n'est autre que Norodom Sihanouk, ex-roi du Cambodge, décédé lundi à l'âge de 89 ans, à Pékin. Des rushes du film Le Crépuscule, conservés par l'INA, montrent une facette mal connue de ce grand personnage de l'histoire du XXe siècle, monarque qui abdiqua deux fois, dont le règne a duré au total plus de 60 ans et qui était aussi un grand amoureux des arts.* **Europe 1**

**THE INDEPENDENT**

ការយាងត្រឡប់មកកាន់អំណាចវិញនាអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ សម្តេច សីហនុ បានបញ្ជាក់ឲ្យឃើញថា ទោះបីជាខ្មែរបានជួបនូវភ័យរន្ធត់ និងទុក្ខសោកអស់រយៈពេលពីរទសវត្សរ៍ចុងក្រោយក៏ដោយ ក៏ពួកគេនៅតែអាចមើលទៅអតីតកាលជាមួយនឹងមោទនភាពខ្ពស់ចំពោះបុព្វបុរសអង្គរ។ (...) ក្នុងចំណោមអ្នកនយោបាយ និងមេបញ្ជាការនៃប្រជាជាតិជាច្រើនដែលបានឆ្លងកាត់សង្គ្រាមឥណ្ឌូចិននាអំឡុង៥ទសវត្សរ៍ចុងក្រោយ មានតែសម្តេច នរោត្តម សីហនុ មួយអង្គតែប៉ុណ្ណោះដែលទទួលបាននូវជោគជ័យដ៏គួរឲ្យកត់សម្គាល់មួយចំនួន។ **The Independent**

*On his return to power in the 1990s, Sihanouk reminded the Khmer that whatever the horror and suffering of the last two decades they still could look back with pride to medieval Angkor. (…) Of all the politicians and generals from many nations who strutted through Indo-China during the last five decades, only Prince Norodom Sihanouk came away with a certain glory.* **The Independent**



- UN PEASANT MAN AND WOMAN IN DISTRESS (១៩៩៤)
- FATALITE (១៩៩៤)
- REVOIR ANGKOR ET MOURIR (១៩៩៤)
- ទុក្ខភ័យកែម និងនិត (១៩៩៤)
- AN AMBITION REDUCED TO ASHES (១៩៩៥)
- BUDDHA DHAMMA SANGHA THE ONLY HEAVEN (១៩៩៥)
- HEIR OF A DEFEATED SECESSIONIST (១៩៩៥)
- THE LAST DAY OF COLONEL SAVATH (១៩៩៦)
- AN APOSTLE OF NON VIOLENCE (១៩៩៧)
- LE CID KHMER (មករា ២០០៥) និងខ្សែភាពយន្តជាច្រើនទៀត។



www.elibraryofcambodia.org

# បទភ្លេង និងបទចម្រៀងដែលជាព្រះរាជនិពន្ធរបស់សម្តេចឪ




បទចម្រៀង និងបទភ្លេងដែលជាព្រះរាជនិពន្ធរបស់សម្តេចឪភាគច្រើន បង្ហាញពីអារម្មណ៍ដ៏ជ្រាលជ្រៅ ចំពោះសេចក្តីស្នេហា ការនឹករឭក ចំពោះទីកន្លែង និងទេសភាពនានាទាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងទីកន្លែងនានាដែលព្រះអង្គធ្លាប់គង់នៅ។

ខាងក្រោមនេះគ្រាន់តែជាចំណងជើងនៃបទចម្រៀងដែលក្រុមការងារយើងដកស្រង់ចេញពីគេហទំព័រ norodomsihanouk.info តែប៉ុណ្ណោះ ហើយបទចម្រៀងភាគច្រើន



ប្រសូតនៅឆ្នាំ១៩២២ នៅភ្នំពេញ សម្តេចព្រះនរោត្តម សីហនុ ទើបនឹងមានព្រះជន្ម១៩ព្រះវស្សាប៉ុណ្ណោះ នៅពេលដែលបារាំងលើកព្រះអង្គអោយសោយរាជ្យ ដោយបំពាក់មកុដមាសនៃព្រះមហាក្សត្រសម័យអង្គរ និងលំហុកណ្តាលើព្រះហស្ត។ ប៉ុន្តែ នៅឆ្នាំ១៩៤៥ ជីវិតនយោបាយរបស់ព្រះអង្គក៏មានការប្រែប្រួលជាលើកដំបូង។ ប្រទេសជប៉ុនបានឈ្លានពានដែនដីអាណានិគម ហើយព្រះអង្គក៏បានប្រកាសទាមទារឯករាជ្យជូនប្រទេសកម្ពុជា។ នៅពេលដែលបារាំងត្រឡប់មកកម្ពុជាម្តងទៀត ក្សត្រដ៏វ័យក្មេងអង្គនេះដែលចូលចិត្តប្រើប្រាស់មុខងារជាក្សត្រនោះក៏បានប្រែក្លាយជាមនុស្សដែលពោរពេញដោយជំនឿចិត្តក្នុងរឿងនយោបាយ។ នៅឆ្នាំ១៩៥៣ ខណៈដែល ព្រះអង្គគង់ជាព្រះមហាក្សត្រនៃប្រទេសកម្ពុជា និងជានាយករដ្ឋមន្ត្រី ផងនោះ ព្រះអង្គបានដឹកនាំធ្វើយុទ្ធនាការអន្តរជាតិមួយ ដើម្បីទាមទារឯករាជ្យ ដ៏ពិតប្រាកដ ជូនប្រទេសជាតិ។ ថ្ងៃទី ៩ វិច្ឆិកា នាឆ្នាំដដែល យុទ្ធនាការទាមទារឯករាជ្យនេះ ក៏សម្រេចជាផ្លែផ្កា។ ក្រោយការចុះហត្ថលេខានាក្រុងហ្សឺណែវ នៅថ្ងៃទី ២១ កក្កដា ១៩៥៤ សម្តេចព្រះ នរោត្តម សីហនុ ក៏បានក្លាយទៅជាបុគ្គលដ៏សំខាន់មួយរូបនៅលើឆាកភូមិសាស្ត្រនយោបាយពិភពលោក។

**Paris Match**

*« Né en 1922 à Phnom Penh, Norodom Sihanouk n'a que dix-neuf ans quand la France le place sur le trône du Cambodge, la couronne d'or des souverains d'Angkor sur la tête et un pouvoir de pacotille entre les mains. Mais en 1945, sa vie politique bascule une première fois. Le Japon envahit la colonie et il proclame l'indépendance du Cambodge. Quand les Français reviennent, le jeune adolescent qui aimait user de son titre est devenu un homme sûr de ses convictions politiques. En 1953, alors qu'il est officiellement roi du Cambodge et Premier ministre, il mène une campagne internationale pour obtenir l'indépendance réelle de son pays. Le 9 novembre de la même année, elle devient effective. Après la signature des accords de Genève le 21 juillet 1954, Norodom Sihanouk est incontournable sur la scène géopolitique mondiale. »* **Paris Match**



www.elibraryofcambodia.org

INDIA TODAY

នៅក្នុងព្រះរាជដំណើរទស្សនកិច្ចរបស់ព្រះអង្គលើកដំបូងនៅក្នុងទីក្រុងញូវដែលីកាលពីខែឧសភា ឆ្នាំ១៩៥៦ ព្រះអង្គបានមានបន្ទូលថា «ខ្ញុំរីករាយខ្លាំងណាស់ក្នុងការមកដល់ទីនេះ និងមានឱកាសម្តងទៀតក្នុងការជួបជាមួយលោក Nehru ដែលខ្ញុំកោតសរសើរយ៉ាងខ្លាំង និងជាមិត្តដ៏អស្ចារ្យម្នាក់របស់ខ្ញុំ»។ ព្រះអង្គបានយាងមកកាន់ប្រទេសឥណ្ឌាម្តងទៀតនៅអំឡុងខែមករា-កុម្ភៈ ឆ្នាំ១៩៦៣ ពេលតែមួយឆ្នាំបន្ទាប់ពីសង្គ្រាមចិន-ឥណ្ឌា។ ព្រះអង្គបានមានបន្ទូលនាពិធីជប់លៀងសម្រាប់ព្រះអង្គនៅ Rashtrapati Bhavan កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៦៣ ថា «កម្ពុជាមានការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះឥណ្ឌា ហើយសម្រាប់ខ្ញុំផ្ទាល់ ខ្ញុំមានដឹងគុណយ៉ាងជ្រាលជ្រៅចំពោះលោក Jawaharlal Nehru អ្នកដឹកនាំដ៏អស្ចារ្យរបស់ឥណ្ឌា។ តាមរយៈការសិក្សាទ្រឹស្តី ការបង្រៀន និងតាមដំបូន្មានប្រកបដោយគតិបណ្ឌិត ខ្ញុំអាចសម្រេចបាននូវសកម្មភាពនានាដែលធានាបាននូវឯករាជភាពរបស់យើង រួមទាំងឯកភាពជាតិ ជាមួយនឹងសន្តិភាពផ្ទៃក្នុង និងគោរពបូរណភាពទឹកដីរបស់យើង»។

***India Today***

*In his first visit to New Delhi took place in May 1956 when he said: "I am very glad to be here and to have another opportunity of meeting Nehru whom I admire very much, and who is my greatest friend." He again came to India in January-February 1963, a year after the Sino-Indian war (...). "Cambodia is deeply indebted to India; and I will add that I, for my part, am much indebted personally to India's great leader Jawaharlal Nehru. "It was by studying his methods and teachings, and by following his sage counsels that I was able to decide upon a course of action which has assured our independence, and national unity, together with peaceful internal conditions and the respect of our sovereignty," he said Jan 25, 1963 at Rashtrapati Bhavan at a dinner held in his honour.*

***India Today***

CREPUSCULE







ROSE DE BOKOR

UN FILM DE NORODOM SIHANOUK
CAMBODGE, 1969





www.elibraryofcambodia.org





មានការបញ្ចេញព្រះសូរសៀង
ដោយសម្តេចព្រះវររាជបិតា
ផ្ទាល់តែម្តង។

- ម៉ូនីកា
- កុលាបភ្នំពេញ
- ព្រៃប្រសិទ្ធិ
- កែវស្នេហា
- សែនស្រឡាញ់
- ទីកែប
- បួងសួងក្នុងពេលរាត្រី
- ចូលឆ្នាំថ្មី
- សែនស្តាយ
- តម្កួញ
- ឡុកឡឺយ
- ភ្នំពេញ
- ភ្នំគូលែន
- ស្នេហា
- ស្នេហាពុំមានសង្ឃឹម
- ជំនោរវិច្ឆិកា
- អប្សរា

«បន្ទាប់ពីការដាក់រាជ្យជាលើកទីពីររបស់ព្រះអង្គកាលពីឆ្នាំ ២០០៤ ថ្វាយដល់ព្រះរាជបុត្រារបស់ព្រះអង្គ ព្រះបាទ នរោត្តម សីហមុនី ដែលជាមហាក្សត្រមួយព្រះអង្គដែលបានសោយរាជ្យយូរជាងគេនៅក្នុងតំបន់អាស៊ី ត្រូវបានគេស្គាល់ថាជាព្រះវររាជបិតានៃប្រទេស។ ព្រះអង្គបានកាន់នូវបន្ទុកជាច្រើននៅក្នុងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ ក្នុងព្រះនាមជាអ្នកការពារយ៉ាងមុតមាំលើវិស័យសង្គម និងព្រះពុទ្ធសាសនា ព្រះអង្គក៏បានហែលឆ្លងនូវសង្គ្រាមត្រជាក់ពេញមួយព្រះជន្មរបស់ព្រះអង្គផងដែរ។ ព្រះអង្គជាស្ថាបនិកមួយព្រះអង្គនៃចលនាមិនចូលបក្សសម្ព័ន្ធជាមួយលោក នេរូ លោក ណាសែរ លោកស៊ូកាណូ និងលោក ជូ អេនឡាយ ក្នុងគោលបំណងបញ្ចប់សង្គ្រាមនេះ»។

**Le Journal du Tchad**

*« Après sa 2ème abdication en 2004, en faveur de son fils, celui dont le règne a été l'un des plus longs d'Asie a été reconnu comme roi et père du pays, et a conservé un grand nombre des responsabilités qui étaient les siennes durant la monarchie constitutionnelle. Apôtre du «socialisme bouddhiste», il fut, en pleine Guerre Froide, l'un des fondateurs du mouvement des non-alignés, qui a servi dans ce conflit aux côtés de Nehru, Nasser, Sukarno et Zhou Enlai. »*

**Le Journal du Tchad**

ប្រជារាស្ត្ររបស់ព្រះអង្គបន្តគោរពព្រះអង្គដូចជាស្តេចអាទិទេពក្នុងប្រពៃណីជាង១០០០ឆ្នាំនៃអាណាចក្រអង្គរ។ ជារួម រាជានិយមគឺស្ថាប័នតែមួយដែលពួកគេនៅមានជំនឿលើ (...)។

**The Los Angeles Times**

*His people continued to revere him as a god-king in the 1,000-year tradition of the Angkor Empire—the monarchy was, after all, the only institution they were still able to believe in (...)*

**The Los Angeles Times**



www.elibraryofcambodia.org

**Le Monde**

នៅឆ្នាំ១៩៤១ ព្រះអង្គបានឡើងគ្រងរាជសម្បត្តិ។ ព្រះអង្គបានដាក់រាជ្យ នៅឆ្នាំ១៩៥៥ ហើយក៏ត្រូវបានគេធ្វើរដ្ឋប្រហារដោយខុសច្បាប់ ទម្លាក់ព្រះអង្គក្នុងឆ្នាំ១៩៧០។ បន្ទាប់មក ព្រះអង្គបានក្លាយជាអ្នកទោសរបស់ខ្មែរក្រហម នៅក្រុងភ្នំពេញ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ព្រះអង្គបានយាងមកកាន់ប្រទេសកម្ពុជានៅខែវិច្ឆិកា ឆ្នាំ១៩៩១។ ពីរឆ្នាំក្រោយមក ព្រះអង្គបានឡើងគ្រងរាជសម្បត្តិជាលើកទីពីរ ហើយនៅឆ្នាំ២០០៤ ព្រះអង្គក៏បានដាក់រាជ្យថ្វាយបុត្ររបស់ព្រះអង្គ គឺសម្តេចព្រះ នរោត្តម សីហមុនី ដោយសារបញ្ហាព្រះជន្ម និងព្រះរាជសុខភាពរបស់ទ្រង់។ តើប្រមុខរដ្ឋបណាដែលលេចធ្លោលើឆាកនយោបាយយូរជាងគេ ក្នុងស្ថានភាពផ្សេងៗគ្នា នៅសតវត្សរ៍ទី២០? គឺសម្តេចព្រះ នរោត្តម សីហនុ។ អតីតអ្នកការទូតបារាំងមួយរូបដែលជាអ្នកជំនាញដ៏ឆ្នើមប្រចាំតំបន់បានពិពណ៌នាយ៉ាងខ្លីថា ព្រះអង្គជាបុគ្គលដែល «មិនអាចលិចលង់»។ សម្តេចព្រះ នរោត្តម សីហនុ ផ្ទាល់ក៏បានថ្លែងអំពីព្រះអង្គកាលពីប៉ុន្មានឆ្នាំមុនថា ព្រះអង្គជាបុគ្គល «ដែលមិនអាចលិចលង់» ដូចគ្នាដែរ។

***Le Monde***











*En 1941, il est monté sur le trône. Il a abdiqué en 1955, a été illégalement destitué en 1970, a été prisonnier des Khmers rouges de 1975 à 1979 à Phnom Penh. Il est revenu au Cambodge en novembre 1991 et remonté sur son trône deux années plus tard avant d'abdiquer en 2004 en faveur de son fils Sihamoni, invoquant son âge et sa santé. Quel homme d'Etat, au XX° siècle, a occupé si longtemps, et avec des fortunes si diverses, le devant de la scène ? Norodom Sihanouk. "Insubmersible", a résumé d'un mot un ancien diplomate français, grand expert de la région. "Incoulable", avait jugé l'intéressé lui-même quelques années auparavant.*

***Le Monde***



www.elibraryofcambodia.org

- គោចាវីរ
- កម្មបងពុំបានដូចចិន្តា
- រាត្រីដែលបានជួបភក្ត្រ
- Revoir java
- បុប្ផារៀងចន្ទន៍
- ផ្កាយស្នេហា
- សកវាទ៍
-យប់ត្រជាក់
-ហ្លួងព្រះបាង
-បុប្ផារៀងចន្ទន៍
-ស្រណោះស្រុកចិន
-អរគុណផ្លូវហ្សឺមីញ
-Ne vous moquez pas de mon amour
-លាហើយកម្ពុជា ។






ព្រះអង្គនៅតែមានឥទ្ធិពលធំនៅក្នុងប្រទេសរបស់ព្រះអង្គ បើទោះបីជាព្រះអង្គបានដាក់រាជ្យថ្វាយបុត្ររបស់ព្រះអង្គ គឺព្រះមហាក្សត្រ នរោត្តម សីហមុនី ដែលបានចូលរួមជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន យាងព្រះបរមសពមកកាន់មាតុប្រទេសវិញ។

**BBC**

*He remained an influential figure in his country, despite his abdication in 2004 in favour of his son King Norodom Sihamoni who, along with Prime Minister Hun Sen, is accompanying his body home.*

**BBC**

នៅពេលដែលព្រះអង្គឡើងគ្រងរាជបល្ល័ង្កនៅក្នុងឆ្នាំ១៩៤១ ក្រោមការរៀបចំរបស់បារាំង ព្រះអង្គត្រូវបានគេគិតថាជាអាយ៉ងរបស់អំណាចអាណានិគម។ នាពេលនេះ ពិភពលោកបានសម្តែងនូវការទឹករលឹកដល់ព្រះអង្គដែលអស់រយៈកន្លះសតវត្សរ៍ ព្រះអង្គបាននាំឲ្យការរួបរួមនៅក្នុងប្រទេសកម្ពុជាមួយ ដែលពោរពេញទៅដោយស្លាកស្នាមសោកនាដកម្ម។ ជាព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ឬប្រមុខរដ្ឋ ជននិរទេស ឬអ្នកជាប់ទោស អ្នកផលិតភាពយន្ត និងតន្ត្រីករ ព្រះបាទព្រះនរោត្តម សីហនុ តែងតែ មានភាពបត់បែនជានិច្ចទាំងផ្លូវនយោបាយ និងការចងសម្ព័ន្ធមិត្ត ហើយអ្វីៗទាំងអស់គឺឈានដល់ការទទួលបានឯករាជ្យជាតិ។

***Jeune Afrique***

*Quand il monte sur le trône, en 1941, adoubé par la France vichyste, il passe pour une marionnette de la puissance coloniale. Aujourd'hui, le monde salue la mémoire de celui qui a maintenu pendant un demi-siècle l'unité d'un Cambodge déchiré par les drames. Roi ou prince, Premier ministre ou chef de l'État, exilé ou prisonnier, cinéaste et musicien, Norodom Sihanouk n'a cessé de changer de casquette, de trajectoire et d'alliés, tout en gardant le cap de l'indépendance nationale.*

***Jeune Afrique***



www.elibraryofcambodia.org

នៅក្នុងជីវិតឯកជន អតីតព្រះមហាក្សត្រទទួលបាននូវការស្រឡាញ់យ៉ាងខ្លាំងចំពោះព្រះរាជសកម្មភាពដ៏រស់រវើករបស់ព្រះអង្គផ្នែកសិល្បៈ។ ព្រះអង្គមានសមត្ថភាពខ្ពស់ក្នុងការប្រគំហ្សាក់សូហ្វូនសម្រាប់ភ្ញៀវ និងចំណាប់អារម្មណ៍លើការផលិតភាពយន្តដែលបានដឹកនាំឲ្យព្រះអង្គផលិតបានខ្សែរឿងជាច្រើន ដោយរឿងខ្លះព្រះអង្គបានដឹកនាំផ្ទាល់ ខ្លះព្រះអង្គជាតួអង្គឯកៗ

**Asia Society**

*In private life, the king was a charismatic bon vivant known for his lavish entertaining. He delighted in performing on the saxophone for his guests and a passion for filmmaking led him to produce numerous movies, several of which he also directed, starred in, and scored. Asia* **Society**









ជាមហាមិត្តរបស់ចិន ហើយព្រះអង្គក៏ជាមិត្តរបស់បារាំងផងដែរ។ ព្រះអង្គមានគោរពស្ញប់ស្ញែងយ៉ាងខ្លាំងក្លាចំពោះឧត្តមសេនីយ៍ដឺហ្គោល ដែលព្រះអង្គបានរៀបចំទទួលស្វាគមន៍យ៉ាងកក់ក្តៅនៅឆ្នាំ១៩៦៦ ក្នុងរាជធានីភ្នំពេញ។ ព្រះអង្គជាបិតាស្ថាបនិកមួយអង្គនៃសមាគម ហ្វ្រង់កូហ្វូនី ជាមួយលោក Bourguiba លោក Senghor លោក Diori ហើយក៏ជាស្ថាបនិកនៃចលនាមិនចូលបក្សសម្ព័ន្ធជាមួយលោក Nasser លោក Nehru លោក Tito លោក Sukarno ផងដែរ។

**InfoSud**

*Ami des Chinois, il l'est aussi des Français. Il a surtout une admiration sans mesure pour le général de Gaulle qu'il accueille avec faste en 1966 à Phnom Penh. Il sera l'un des pères fondateurs de la Francophonie - avec, Bourguiba, Senghor, Diori – et du Mouvement des non-alignés - avec Nasser, Nehru, Tito, Sukarno.*

**InfoSud**



www.elibraryofcambodia.org

www.elibraryofcambodia.org

# ទស្សនៈនានារបស់
# មហាជនក្នុង និងក្រៅ
# ព្រះរាជាណាចក្រកម្ពុជា


www.elibraryofcambodia.org

## សម្តេចឪ
## និងស្នាព្រះហស្ត
## ផ្នែកសំណេរ





គេហទំព័រ
www.norodomsihanouk.info
គឺជាឃ្លាំងផ្ទុកឯកសារដ៏ធំបំផុតមួយ
ទាក់ទងនឹងព្រះរាជសកម្មភាព
និងឯកសារប្រវត្តិសាស្ត្រនានា។ សម្តេច
ព្រះវររាជបិតាត្រូវបានមនុស្ស
ជាច្រើនក្នុងសកលលោកចាត់ទុក
ព្រះអង្គថា ជាស្តេចដែលមិនចេះមាន
ការនឿយហត់ ដោយភាគច្រើន
ព្រះអង្គទ្រង់សរសេរ
និងចារជាភាសាបារាំង។

ព្រះរាជសំណេរដ៏ច្រើនលើសលប់
របស់ព្រះអង្គត្រូវបានចុះផ្សាយនៅ
ក្នុងគេហទំព័រមួយនេះ ហើយបន្ថែម
ពីលើនេះ ក្រសួងព្រះបរមរាជវាំងក៏មាន
ការចេញផ្សាយព្រឹត្តិបត្រឯកសារប្រចាំខែ
ឈ្មោះ BMD ( Bulletin Mensuel de
Documentation ) ផងដែរ។





*«ព្រះអង្គបានបន្សល់ទុកឲ្យប្រជានុរាស្ត្រខ្មែរគ្រប់ជំនាន់នូវស្នាព្រះហស្តដ៏ល្អពិសេសជាច្រើន មានជាអាទិ៍សៀវភៅឯកសារមួយចំនួន ខ្សែភាពយន្ត ចម្រៀង ដែលជាព្រះរាជនិពន្ធនិងព្រះសូរសៀងផ្ទាល់»។*

***លោកស្រី ប៉ិច សង្វាវ៉ាន អ្នកនិពន្ធខ្មែរនៅបារាំង***

*«ព្រះបាទនរោត្តម សីហនុ មិនត្រឹមតែជាក្សត្រដែលគួរគោរពនោះទេ ប៉ុន្តែព្រះអង្គថែមទាំងចេះនិពន្ធ សម្តែងភាពយន្ត និងចម្រៀងទៀតផង។ ចំណុចទាំងអស់នេះហើយ ដែលធ្វើឱ្យប្រជារាស្ត្រខ្មែរគោរព និងកោតសរសើរជាពន់ពេកចំពោះស្នាព្រះហស្តដ៏ច្រើនសន្ធឹកសន្ធាប់របស់ព្រះអង្គ»។*

***លោក សុះ ម៉ាច ប្រធានសមាគមសិល្បករខ្មែរ***
***( គេហទំព័រសប្បាយ)***



www.elibraryofcambodia.org






ដោយឡែកចំពោះព្រះរាជនិពន្ធជាសៀវភៅវិញ មានដូចជា «អ្នកទោសខ្មែរក្រហម» «សង្គ្រាមរបស់ខ្ញុំជាមួយពួកសេអ៊ីអា» និងអនុស្សាវរីយ៍ផ្អែមល្ហែម និងជូរចត់» ជាដើម ។

ក្រៅពីនេះ គេសង្កេតមានសៀវភៅមួយចំនួនត្រូវបានចងក្រងដោយអ្នកនិពន្ធបរទេស ក្រោមព្រះរាជតម្រិះរបស់ព្រះអង្គ រួមទាំងសៀវភៅមួយចំនួនដែលសរសេរពីព្រះអង្គផងដែរ ។ សៀវភៅទាំងនោះមានដាក់លក់នៅលើគេហទំព័រ amazon.com ។

«ក្នុងដំណើរដើរលើវិថីសិល្បៈភាពយន្តជាង២០ឆ្នាំមកនេះ ខ្ញុំធ្លាប់បានធ្វើដំណើរដង្ហែតាមព្រះបាទនរោត្តម សីហនុ អស់មួយរយៈធំ ថែមទាំងធ្លាប់បានថតរឿងមួយចំនួនថ្វាយដល់ព្រះអង្គទៀតផង។ ព្រះអង្គទ្រង់ជាក្សត្រមានព្រះទ័យទូលាយជ្រះថ្លាចំពោះកូនចៅ។ រហូតមានពេលខ្លះព្រះអង្គសួរខ្ញុំថា កូនដារ៉ូ ហត់នឿយទេ បើកូនហត់នឿយសម្រាកសិនទៅ សុខភាពកូនល្អ ទើបបិតាសប្បាយចិត្ត»។

**លោក ទេព វិទ្ធដារ៉ូ តារាភាពយន្ត (ភ្នំពេញ ប៉ុស្តិ៍)**




«ការយាងចូលទិវង្គតរបស់ព្រះមហាវីរក្សត្រ ព្រះបាទនរោត្តម សីហនុ នៅពេលនេះ ដូចអ្វីដែលខ្ញុំបានបាត់បង់ឪពុកកាលពី១២ឆ្នាំមុនអីចឹង។ គឺខ្ញុំមានការអាឡោះអាល័យជាខ្លាំង ព្រះអង្គប្រៀបដូចជាឪពុករបស់ខ្ញុំដែរ»។

**កញ្ញា ខ្ចង់ ហ្សូរីដា សិល្បការិនី (គេហទំព័រសប្បាយ)**




www.elibraryofcambodia.org














*«ខណៈដែលខ្ញុំថតរឿងថ្វាយព្រះអង្គនោះ ដ្បិតតែព្រះអង្គទ្រង់ជាក្សត្រដ៏មានអំណាចស្មើមេឃ និងមានបុណ្យបារមីខ្ពស់ ហើយតារាភាពយន្តដូចខ្ញុំគ្រាន់តែជាកស្រ្តសាមញ្ញ ប៉ុន្តែរាល់ពេលដែលសម្តែង ព្រះអង្គតែងមានព្រះទ័យគិតគូរយកចិត្តទុកដាក់ខ្លាំងមែនទែន ចំពោះតារាៗដូចជារូបខ្ញុំ»។*

***លោក ពេជ្រ កិរុណា អតីតតារាភាពយន្ត (ភ្នំពេញ ប៉ុស្តិ៍)***

*«ការបាត់បង់របស់ព្រះមហាក្សត្រខ្មែរព្រះនរោត្តម សីហនុ នាពេលនេះ គឺមិនត្រឹមតែបាត់បង់មហាក្សត្រដ៏ឆ្នើមទេ ពោលគឺយើងបាត់បង់ធនធានមនុស្សដ៏ថ្លៃថ្លាបំផុតក្នុងវិស័យសិល្បៈភាពយន្ត និងសិល្បៈចម្រៀងផងដែរ»។*

***នាង កែវ ពេជ្រពិសី តារាភាពយន្ត (កោះសន្តិភាព)***



www.elibraryofcambodia.org












«ទោះបីជាយើងបាត់បង់វីរក្សត្រដ៏ឆ្នើមមួយអង្គនាពេលនេះក៏ពិតមែន តែយើងនៅតែមានភាពអង់អាចក្លាហាន ដោយប្រែក្លាយពីទុក្ខសោកមិនអាចបំភ្លេចបាននេះឲ្យទៅជាភាពមោះមុតមួយបម្រើទៅតាមមុខជំនាញរបស់ខ្លួនឲ្យបានខ្លាំងក្លា ដោយយើងមិនត្រូវតែនិយាយតែមាត់នោះទេ គឺត្រូវសម្រេចឲ្យបានសម្រាប់ទឹកដីមហាអន្តរដើបវរនៃយើង ក្នុងនាមយើងធ្លាប់មានវីរក្សត្រដ៏ឆ្នើមម្នាក់ដែលបានបូជាកម្លាំងកាយក្នុងការត្រួសត្រាយផ្លូវឲ្យយើងបានឃើញពន្លឺរហូតដល់សព្វថ្ងៃ» ។

**លោកអៀង ស៊ីផុល សិល្បៈករ (កោះសន្តិភាព)**

www.elibraryofcambodia.org












«ព្រះអង្គជាព្រះវីរក្សត្រដ៏អស្ចារ្យបំផុតរបស់កម្ពុជា។ ខ្ញុំនៅចាំថា ពេលខ្ញុំនៅរៀន ព្រះអង្គបានចុះផ្ទាល់ទៅពិនិត្យនៅតាមសាលារៀន ហើយអ្វីដែលអស្ចារ្យនោះ គឺខ្ញុំបានកើតទាន់ព្រះអង្គទាមទារបានឯករាជ្យពីបារាំង និងធ្លាប់រស់នៅក្នុងរបបសង្គមរាស្ត្រនិយមរបស់ព្រះអង្គ»។ **តារាកំប្លែងលោក ជួង ជី ហៅ កុយ (ដើមអម្ពិល)**

«ព្រះករុណា លោកមានលក្ខណសម្បត្តិដឹកនាំប្រទេសជាតិ លោកជាអ្នកឯករាជ្យមិនយកប្រទេសជាសំអាង។ លោកស្រឡាញ់ប្រទេសជាតិរបស់លោកយ៉ាងមុតមាំ ហើយសេចក្តីស្រឡាញ់នោះ បានឲ្យព្រះអង្គការពារប្រទេសយ៉ាងប្តូរផ្តាច់»។
**លោក សុន ឆ័យ អ្នកតំណាងរាស្ត្រ (វិទ្យុអាស៊ីសេរី)**



www.elibraryofcambodia.org












DÉCLARATION
de NORODOM SIHANOUK
DU CAMBODGE
Beijing, R.P. de Chine

«ខ្ញុំបម្រើព្រះអង្គតាំងពីហាត់កាំភ្លើងឈើ រហូតដល់នៅទល់ដែនដង្ហើព្រះអង្គរហូតមក គឺបានរៀនសូត្រពីព្រះអង្គច្រើនណាស់។ ខ្ញុំមានការសោកស្តាយណាស់។ យើងបាត់បង់ព្រះមហាវីរក្សត្រយើងហើយ ដូច្នេះ យើងគួរតែរួបរួមគ្នា ឈប់ឈ្លោះគ្នា អត់ឱនឲ្យគ្នា ដើម្បីជាកិច្ចតបស្នងចំពោះព្រះវិញ្ញាណក្ខន្ធព្រះអង្គឲ្យបានទៅកាន់សុគតិភព បានសុខ»។ **លោក លី ឡាយស្រេង អតីតរដ្ឋមន្ត្រីក្រសួងព័ត៌មាន (វិទ្យុអាស៊ីសេរី)**

«ការបាត់បង់អតីតព្រះមហាក្សត្រសម្តេច ព្រះនរោត្តម សីហនុ គឺជាការបាត់បង់នៃជុំពេជ្រ អ្នកដឹកនាំដែលមានថ្វីដៃ នៃនយោបាយកម្ពុជា ពីព្រោះព្រះអង្គមានស្នាព្រះហស្តសំខាន់ៗនៅក្នុងជីវិតព្រះអង្គ ក្នុងនាមព្រះអង្គជាអ្នកដឹកនាំ ក្នុងនាមព្រះអង្គជាស្តេចមួយអង្គ»។

**បណ្ឌិត សុខ ទូច អ្នកវិភាគនយោបាយឯករាជ្យនៅកម្ពុជា**



www.elibraryofcambodia.org






LA CHINE DEMEURE PLUS QUE JAMAIS L'AMIE NUMERO UN









«ព្រះមហាវីរក្សត្រ បានគង់នៅជាមួយប្រជាពលរដ្ឋខ្មែរដល់ទៅ ៨៩ព្រះវស្សា មកហើយ ដូច្នេះពេលនេះជាពេលដែលអ្នកនយោបាយខ្មែរត្រូវរៀនសូត្រតាមគន្លងកេរដំណែលពីព្រះករុណា ដែលមានខន្តីច្រើន យោគយល់ច្រើន ចេះដោះស្រាយបញ្ហាដោយសន្តិវិធី និងអនុគ្រោះគ្នាទៅវិញទៅមក»។

**លោកស្រីជា វណ្ណាត អ្នកវិភាគឯករាជ្យ (វិទ្យុអូស្ត្រាលី)**

«ព្រះអង្គធ្លាប់ជាម្លប់របស់កូនចៅប្រជាពលរដ្ឋជ្រកកោនបានសុខសាន្ត ហើយសម្តេចលោកប្រកបដោយទសពិធរាជធម៌ លោកជួយរំលែកទុក្ខប្រជាពលរដ្ឋបានច្រើន លោកល្អណាស់»។

**ព្រះតេជគុណ ស៊ិន មុនី ព្រះចៅអធិការវត្តស្រះសម្តេចសង្ឃរាជ ជួន ណាត ខេត្តកំពង់ស្ពឺ (វិទ្យុអាស៊ីសេរី)**



www.elibraryofcambodia.org


















«ខ្ញុំនៅស្រណោះដែលគាត់ចិត្តបានៗ គាត់ដើរផ្តល់ដល់កូនចៅៗ ទៅវត្តណាក៏ខ្ញុំមក វត្តណាក៏ខ្ញុំទៅជួបៗៗ ឮថាសម្តេចយាងមក ហើយខ្ញុំទៅចាំទុកហើយៗ ទៅចោលកូនចោលចៅ ដាំបាយ ទៅចាំមើលៗ គាត់ទម្លាក់ខោអាវមកទើរលើគុម្ពឫស្សីក៏មានដែរ»។

**អ្នកស្រីហ៊ិយ សៀង អាយុ៨៣ឆ្នាំ (វិទ្យុអាស៊ីសេរី)**

«គ្រាន់តែបានទទួលដំណឹងនេះភ្លាម ខ្ញុំមានការតក់ស្លុតខ្លាំងណាស់ ស្រាប់តែទឹកភ្នែកខ្ញុំស្រក់មកឯងៗតែម្តង ។ ទឹកភ្នែកដែលស្រក់មកភ្លាមៗនេះ វាជាអារម្មណ៍ពិតៗរបស់ខ្ញុំ ដោយខ្ញុំធ្លាប់មានមនោសញ្ចេតនាជ្រាលជ្រៅ តាមរយៈការងារដែលកាលនោះ ខ្ញុំជាប្រធានសាខាកាកបាទក្រហមកម្ពុជា ប្រចាំសាខារាជធានីភ្នំពេញ ខេត្តស្ទឹងត្រែង និងស្វាយរៀង ហើយរូបខ្ញុំធ្លាប់បានទទួលមេដាយ៣ ពីព្រះអង្គម្ចាស់ ស្មើសោភ័ណ្ឌ១ ពីសម្តេចឪ១ និងពីសម្តេចម៉ែ១។ ខ្ញុំពុំមិនភ្លេចទេ»។

**លោកស្រី ជឹម វិន អាយុ ៧៦ឆ្នាំ**

**អាណិកជនខ្មែររស់នៅរដ្ឋ** Portland, Origen **សហរដ្ឋអាមេរិក**



www.elibraryofcambodia.org

# ព្រះឆាយាលក្ខណ៍ ព្រះរាជសារ និងរូបថតអនុស្សាវរីយ៍ ផ្សេងៗរបស់សម្តេចឪ ត្រូវបានដាក់លក់ នៅក្នុងគេហទំព័រ

www.ebay.com



ខាងក្រោមនេះគឺផ្ទាំងរូប និងតារាងតម្លៃមួយចំនួន (ដោយគិតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣)

ផ្ទាំងព្រះឆាយាលក្ខណ៍ និងព្រះរាជសារ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៦៩ តម្លៃ ១៧ ៥០០ដុល្លារអាមេរិក។





«ព្រះអង្គបានទាមទារឯករាជ្យជូនជាតិ រៀបចំរចនាសម្ព័ន្ធក្នុងប្រទេសឱ្យមានសណ្តាប់ធ្នាប់ ព្រមទាំងទាមទារបណ្តាខេត្តខ្មែរដែលបានបាត់បង់ទៅពីប្រទេសថៃទៀតផង។ រហូតមកដល់ពេលនេះគឺខ្ញុំនៅតែមានអារម្មណ៍ថា ស្ទើរតែមិនជឿថារឿងបែបនេះកើតឡើងនោះឡើយ»។ **កញ្ញា ប៉េង សុគន្ធណារ័ត្ន អាយុ២២ឆ្នាំ និស្សិតនៅវិទ្យាស្ថានភាសាបរទេស** (dmcpost.com)

«ព្រះអង្គគឺជាក្សត្រដ៏ឆ្នើមដែលបានបង្កើតនូវស្នាព្រះហស្តដ៏ល្អឯកជាច្រើននៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ប្រសិនបើគ្មានព្រះបាទនរោត្តម សីហនុនោះទេ ប្រទេសកម្ពុជាយើងក៏គ្មានថ្ងៃឯករាជ្យ ០៩ វិច្ឆិកា ១៩៥៣នោះដែរ ហើយប្រសិនបើគ្មានថ្ងៃដ៏មហាជោគជ័យនោះទេ ក៏គ្មានព្រះរាជាណាចក្រកម្ពុជានាសព្វថ្ងៃនេះដូចគ្នា»។

**លោក លឹម សេងលាង អាយុ២១ឆ្នាំ**

**និស្សិតនៅសាកលវិទ្យាល័យ បញ្ញាសាស្ត្រ** (dmcpost.com)



www.elibraryofcambodia.org





«ព្រះបាទសម្តេចនរោត្តម សីហនុ គឺជាក្សត្រមួយអង្គដ៏អស្ចារ្យបំផុតក្នុងចិត្តរបស់ខ្ញុំ។ ការបាត់បង់រូបព្រះអង្គ គឺជាការបាត់បង់មួយយ៉ាងធំធេងចំពោះជនជាតិកម្ពុជាទាំងមូល ជាពិសេសគឺរូបខ្ញុំផ្ទាល់។ ព្រះអង្គបានធ្វើឲ្យគម្ចាត់នៃប្រជាជន និងព្រះមហាក្សត្រកាត់បន្ថយ។ ខ្ញុំពិតជាមានអារម្មណ៍ថាក្រៀមក្រំ និងសោកស្តាយជាពន់ពេកនៅក្នុងចិត្តដែលបាត់បង់មហាវីរក្សត្រដូចព្រះអង្គ»។ **កញ្ញា នី ទេវីន អាយុ២០ឆ្នាំ និស្សិតនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (dmcpost.com)**

«ព្រះអង្គបានសាងសង់នូវផ្លូវគមនាគមន៍ជាច្រើនខ្សែរួមជាមួយនឹងកំពង់ផែ អាកាសយានដ្ឋាន មន្ទីរពេទ្យ សាលារៀន សាកលវិទ្យាល័យនានា។ល។ ក្នុងនាមខ្ញុំជាកូនខ្មែរមួយរូប ខ្ញុំពិតជាមានមោទនភាពយ៉ាងក្រៃលែងចំពោះស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះបិតានរោត្តម សីហនុ»។ **លោក ម៉ៅ ទេវិន អាយុ២០ឆ្នាំ និស្សិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម (dmcpost.com)**

ព្រះឆាយាលក្ខណ៍ដែលមាន
ព្រះហស្តលេខានៅពីក្រោម
តម្លៃ ៣ ៩៩៩ដុល្លារអាមេរិក។



ព្រះរាជសារអបអរបុណ្យណូអែល
មួយសន្លឹកចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៦៨
ផ្ញើទៅកាន់លោក Danny Franklin
តម្លៃ២ ៩៩៩ ដុល្លារអាមេរិក។



និងរូបថតអនុស្សាវរីយ៍
ជាច្រើនទៀត
ដែលមានតម្លៃចាប់ពី
១,៧៥ដុល្លារអាមេរិក
ដល់២០០ដុល្លារអាមេរិក។



www.elibraryofcambodia.org













«ការសោកស្តាយវាត្រូវតែមានហើយចំពោះប្រជារាស្ត្រខ្មែរ ប៉ុន្តែយើងជាកូនខ្មែរក៏មានអារម្មណ៍រំភើបមួយដែរ ដែលមានព្រះអង្គមានព្រះជន្មរហូតដល់៩០ឆ្នាំបែបនេះ ព្រោះប្រវត្តិសាស្ត្រខ្មែរយើងដូចជាមិនមានស្តេចអង្គណាមានព្រះជន្មវែងបែបនេះទេ។ ជាងនេះទៅទៀត ស្តេចយើងសោយទិវង្គតចំថ្ងៃបុណ្យភ្ជុំបិណ្ឌ(ថ្ងៃសីល) មានជោគជតាកសិល្អខ្លាំងណាស់»។

**លោក សាន គឹមសាន អ្នកអភិរក្សក្បាច់គុន ល្បុក្កតោវ័យ៦៧ឆ្នាំ (ភ្នំពេញ ប៉ុស្តិ៍)**

«ខ្ញុំគោរពព្រះអង្គតាំងពីក្មេងៗ ព្រះអង្គតែងតែមានព្រះបន្ទូលថាកីឡាគឺជាផ្លូវមួយដែលនាំឲ្យយើងស្គាល់ច្បាស់ពីប្រទេសនានា ដូច្នេះយើងនឹងបន្តការតស៊ូទៅមុខទៀតដើម្បីបង្ហាញឲ្យឃើញថាព្រះអង្គគឺជាកម្លាំងចិត្តដ៏សំខាន់មួយរបស់យើងទាំងអស់គ្នា»។

**លោក ខេព វិទ្ធីរៃត អគ្គលេខាធិការសហព័ន្ធកីឡាវាយកូនបាល់កម្ពុជា (ភ្នំពេញ ប៉ុស្តិ៍)**



www.elibraryofcambodia.org













«ខ្ញុំនៅចាំពីវីរភាពរបស់ព្រះករុណានាជំនាន់សង្គមរាស្ត្រនិយម ដោយ នៅពេលនោះខ្ញុំបានជាប់ឈ្មោះក្នុងក្រុមកីឡាបាល់ទាត់ជម្រើសជាតិផ្នែកយុវជន។ ខ្ញុំបានឃើញសម្តេចឪចំណាយពេលវេលាច្រើនណាស់ក្នុងវិស័យកីឡាដូចជា ការចុះទៅទស្សនាផ្ទាល់នាជំនួបវគ្គផ្តាច់ព្រ័ត្រម្តងៗ»។ **លោកឈួន ឡេង មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា (ភ្នំពេញ ប៉ុស្តិ៍)**

«ព្រះអង្គជាវីរបុរសនៅក្នុងស្រុកខ្មែរ ហើយទេវតាបានប្រទានព្រះអង្គមកដើម្បីជួយសង្គ្រោះជាតិ។ ព្រះអង្គមានគោលជំហរច្បាស់លាស់ ក្នុងការជួយសង្គ្រោះប្រទេសជាតិឲ្យគេចផុតពីអាណានិគមនិយមបារាំង ស្វែងរកឯកភាពជាតិពិតប្រាកដដល់កូនចៅ និងចៅទួតជំនាន់ក្រោយៗ»។
**លោក ហែម ប៊ុនទីង កីឡាករម៉ារ៉ាតុង (ភ្នំពេញ ប៉ុស្តិ៍)**

«ព្រះអង្គចូលចិត្តអ្នកកាសែតណាស់ ហើយលោកឲ្យតម្លៃលើស[illegible]មាន។ លោកចូលចិត្តរក្សាទូរទំព័រសារព័ត៌មានអត្ថ[illegible]ឡាយ គឺលោកបានរក្សាយ៉ាងត្រឹមត្រូវបំផុត។ នេះជា[illegible]ភាពពិសេសរបស់លោក ហើយរហូតដល់លោកបានចងក្រង[illegible]ប្រចាំខែរបស់លោកថែមទៀត ដើម្បីលោកចុះផ្សាយពី[illegible]ទាំងឡាយដែលបានចុះផ្សាយពីលោក ហេតុនេះ[illegible]កសារព័ត៌មានស្រឡាញ់ចូលចិត្តលោក»។
**លោក ពុយ គា អ្នកធ្វើយទូងព័ត៌មាននៃទីភ្នាក់ងារសារព័ត៌មាន ក្យូដូ (វិទ្យុអាស៊ីសេរី)**



www.elibraryofcambodia.org

## ព្រះរាជសកម្មភាព របស់សម្ដេចឪ ជាមួយឥស្សរជន អន្តរជាតិនានា













«ព្រះអង្គជាក្សត្រដែលមានស្នាព្រះហស្តឆ្នើមអស្ចារ្យ បានលះបង់ព្រះកាយពលរំដោះជាតិខ្មែរពីរបបអាណានិគមនិយមបារាំង ដូចអង្គវីរក្សត្រខ្មែរដ៏ឆ្នើមនៅក្នុងសម័យអង្គរដែរ ។ អង្គសម្ដេចឪ សម្ដេចតា សម្ដេចតាទួតនៃយើង បានបូជាព្រះរាជហឫទ័យចំពោះព្រះពុទ្ធសាសនា ដែលនាំឲ្យរីកចម្រើនដរាបមក។ ព្រះអង្គផ្ទាល់ ទ្រង់ជាពុទ្ធសាសនូបត្ថម្ភក៏ ដ៏សំខាន់ និងបានប្រកាន់ខ្ជាប់នូវព្រះឧបោសថសីល ដែលជាសីលដ៏បរិសុទ្ធឧត្តុង្គឧត្តមបំផុតសម្រាប់ពុទ្ធសាសនិកជន»។

**មហាឧបាសិកា ពុទ្ធសាសនូបត្ថម្ភក៏ សុខ អ៊ីម**

«ព្រះបាទ សម្ដេចព្រះ នរោត្ដម សីហនុ ដែលស្នេហាជាតិមាតុភូមិ ប្រជារាស្ត្រ រួមទាំងខ្មែរកាន់សាសនាអ៊ិស្លាមផង ត្រូវបានយើងខ្ញុំចងចាំទុកក្នុងក្រអៅបេះដូង នូវស្នាព្រះហស្តនិងព្រះរាជបូជនីយកិច្ចរបស់ព្រះអង្គដ៏ស្ញប់ស្ញែង ជាពិសេស គុណូបការៈគុណព្រះអង្គដែលបានព្រះរាជទានប្រសិទ្ធិនាមជាកិត្តិយសដល់ជនកាន់សាសនាអ៊ិស្លាមនៅប្រទេសកម្ពុជា ថាជា "ខ្មែរអ៊ិស្លាម" គឺជាខ្មែរ ដែលកាន់សាសនាអ៊ិស្លាម»។

***លោក ម៉ាត់ ហ៊ីម ខ្មែរអ៊ិស្លាមនៅខេត្តបន្ទាយមានជ័យ***

«ខ្ញុំមិនបានដឹងអ្វីច្រើនឡើយពីសម្ដេចតា ប៉ុន្តែនៅពេលខ្ញុំមើលឃើញព្រះរាជសកម្មភាពរបស់ព្រះអង្គនៅតាមកញ្ចក់ទូរទស្សន៍ ខ្ញុំសង្កេតឃើញថា ព្រះអង្គធ្លាប់មានស្នាព្រះហស្តយ៉ាងច្រើន។ ព្រះអង្គមានភាពជិតដិតជាមួយប្រជារាស្ត្រខ្លាំងណាស់»។

***លោក គិន សុភា អាយុ២១ឆ្នាំ***
***និស្សិតគ្រប់គ្រងទូទៅនៃសាកលវិទ្យាល័យមៀលប្រាយ***



www.elibraryofcambodia.org











«មនុស្ស១០នាក់គឺសរសើរព្រះអង្គទាំង១០នាក់ និយាយរួម ព្រះអង្គមិនដែលបានធ្វើអ្វីដែលល្អក់កករដល់ប្រទេសជាតិនោះឡើយ។ អ្នកស្អប់ព្រះអង្គគឺមានតែអ្នកនយោបាយមួយចំនួនដែលចង់កាច់កុងព្រះអង្គតែប៉ុណ្ណោះ។ សម្តេចឪគឺជាអ្នកដឹកនាំដ៏ល្អម្នាក់ អ្នកណាៗ ក៏ស្តាយព្រះអង្គដែរ»។

**លោកស្រី ឈឹម ច័ន្ទស៊ីណាល់ អាយុ៥៥ឆ្នាំ**
**ប្រជាពលរដ្ឋរាជធានីភ្នំពេញ**

«សម្រាប់ខ្ញុំ ព្រះអង្គគឺជាស្តេចដែលញញឹមស្រស់ជាងគេបំផុត។ បើយើងពិនិត្យមើលព្រះឆាយាលក្ខណ៍ គឺភាគច្រើនបំផុតរបស់ព្រះអង្គមានភ្ជាប់ជាមួយស្នាមព្រះភក្ត្រញញឹម។ ខ្ញុំយល់ស្របនូវអ្វីដែលគាត់បាននិយាយថា សម័យសង្គមរាស្ត្រនិយមក្រោមការដឹកនាំរបស់ព្រះអង្គ ពិតជាបានធ្វើឲ្យប្រទេសកម្ពុជាមានការរីកចម្រើន»។

**កញ្ញា អ៊ឹង ចាន់ណារី អាយុ២៣ឆ្នាំ**
**បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលនៅខេត្តសៀមរាប**


www.elibraryofcambodia.org








www.elibraryofcambodia.org











www.elibraryofcambodia.org











www.elibraryofcambodia.org






www.elibraryofcambodia.org











www.elibraryofcambodia.org











www.elibraryofcambodia.org











www.elibraryofcambodia.org











www.elibraryofcambodia.org











www.elibraryofcambodia.org









www.elibraryofcambodia.org





www.elibraryofcambodia.org

# បទសម្ភាសជាមួយ
# ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ
# អតីតលេខាផ្ទាល់របស់សម្ដេចព្រះវររាជបិតា
## ដោយ
## លោក គី សុខលីម


www.elibraryofcambodia.org

## ស៊ីសុវត្ថិ ធម្មិកោ ៖

## «អ្វីដែលអស្ចារ្យសម្រាប់ខ្ញុំគឺកេរដំណែលនយោបាយរបស់សម្ដេចឪ»

*ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ដែលត្រូវជាក្មួយ និងជាអតីតលេខាផ្ទាល់របស់ព្រះមហាក្សត្រ សម្ដេចឪ នរោត្តម សីហនុ បានផ្ដល់បទសម្ភាសផ្ដាច់មុខជាមួយក្រុមការងាររចនាក្រងសៀវភៅដែលមានចំណងជើងថា «ព្រះបាទ សម្ដេចព្រះ នរោត្តម សីហនុ ជាវីរបុរសជនអមតៈ»។ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ បានចាត់ទុកសម្ដេចឪជាតួអង្គសាមញ្ញផង និងអស្ចារ្យផងក្នុងនាមជាក្សត្រមួយអង្គរបស់នគរខ្មែរ ហើយអ្វីដែលព្រះអង្គស្ញប់ស្ញែងបំផុតគឺកេរដំណែលនយោបាយរបស់សម្ដេចឪ។*

**សំណួរ៖ ព្រះអង្គបានចំណាយពេលច្រើនឆ្នាំជាមួយសម្ដេចឪក្នុងនាមជាលេខាផ្ទាល់។ បើតាមព្រះតម្រិះរបស់ព្រះអង្គ តើអ្វីខ្លះជាស្នាព្រះហស្តធំៗមិនអាចកាត់ថ្លៃបានរបស់ព្រះមហាក្សត្រក្នុងរជ្ជកាលរបស់ព្រះអង្គ?**

**ចម្លើយ៖** (គិតបន្តិច) សម្រាប់ខ្ញុំជាបញ្ញវន្តមួយរូប កេរដំណែលជាអគាររាប់ពាន់របស់សង្គមរាស្ត្រនិយមជារឿងមួយ។ ប៉ុន្តែអ្វីដែលអស្ចារ្យសម្រាប់ខ្ញុំគឺកេរដំណែលនយោបាយរបស់ព្រះករុណា។ កេរមរតកនយោបាយរបស់ព្រះអង្គមានច្រើនណាស់ ដូចជាការទាមទារឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ ដោយមិនបង្ហូរឈាម ខ្មែរក៏មិនបង្ហូរឈាម បារាំងក៏មិនបង្ហូរឈាម។ នេះជាសមិទ្ធផលសំខាន់បំផុតពីព្រោះសព្វថ្ងៃនេះយើងមានសេរីភាព មានឯករាជភាព មានអធិបតេយ្យភាពគឺបានមកពីស្នាព្រះហស្ត[illegible]ព្រះរាជបិតា។ សមិទ្ធផលទីពីរគឺសន្តិភាព។ ព្រះអង្គធ្វើ[illegible]យ៉ាងដើម្បីសុខសន្តិភាពជូនមាតុប្រទេស និងប្រជារាស្ត្ររបស់ព្រះអង្គ។

**សំណួរ៖ អតីតព្រះមហាក្សត្រខ្មែរ សម្ដេចឪ នរោត្តម សីហនុ មិនមែនល្បីល្បាញ[illegible]ងប្រទេសទេ តែព្រះអង្គក៏ល្បីល្បាញនៅលើឆាកអន្តរជាតិដែរ។ តើអ្នកដឹកនាំប្រទេសផ្សេងៗទៀតបានវាយតម្លៃព្រះអង្គយ៉ាងដូចម្ដេចដែរចំពោះនយោបាយរបស់ព្រះអង្គ?**

**ចម្លើយ៖** និយាយដោយស្មោះ ខ្ញុំមិនដែលបានឮដោយផ្ទាល់នឹងត្រចៀកខ្លួនឯងទេ ពីព្រោះខ្ញុំនៅក្មេងពេក។



ប៉ុន្តែតាមរយៈការអានឯកសារនានា ដូចជាសៀវភៅជាដើម មេដឹកនាំជាច្រើនដែលស្គាល់ព្រះអង្គបានកោតសរសើរអង្គសម្ដេចឪថាជាក្សត្រឆ្លាត ស្អាតស្អំ ស្មោះត្រង់ និងស្នេហាជាតិជាពិសេស មេដឹកនាំបារាំងតែម្ដងដែលបានសរសើរព្រះអង្គយ៉ាងដូច្នេះ។

**សំណួរ៖ មានការលើកឡើងជាច្រើនថា សម្ដេចឪ នរោត្តម សីហនុ ជាក្សត្រដែលគ្មានព្រះរាជទ្រព្យអ្វីទេ។ តើបច្ចុប្បន្ននេះព្រះអង្គមានព្រះរាជទ្រព្យជាក់ស្ដែងអ្វីខ្លះដែរ?**

**ចម្លើយ៖** បើតាមអ្វីដែលខ្ញុំដឹង ព្រះវររាជបិតាសម្ដេចព្រះនរោត្តម សីហនុ មានព្រះរាជទ្រព្យបី។ ព្រះរាជទ្រព្យទី១គឺជាប្រាក់អឺរ៉ូចំនួន ២ ម៉ឺនអឺរ៉ូ នៅក្នុងធនាគារបារាំង។ ព្រះរាជទ្រព្យទី២ គឺព្រះរាជដំណាក់នៅក្បែរគេហដ្ឋានសម្ដេចតេជោ ហ៊ុន សែន ដែលសព្វថ្ងៃនេះជាស្ថានទូតសាធារណរដ្ឋប្រជាមានិត



www.elibraryofcambodia.org







ប្រជាធិបតេយ្យកូរ៉េ (កូរ៉េខាងជើង)។ ព្រះអង្គធ្លាប់បានមានព្រះរាជបន្ទូលនៅក្នុងគេហទំព័ររបស់ព្រះអង្គថា ពេលចប់អាណត្តិ២០ឆ្នាំជាមួយស្ថានទូតកូរ៉េខាងជើងនៅឆ្នាំ២០១៣ខាងមុខនេះ ព្រះអង្គនឹងត្រូវប្រគល់ដំណាក់នេះជូនរាជរដ្ឋាភិបាលកម្ពុជាវិញ។ ប៉ុន្តែព្រះអង្គមានលក្ខខណ្ឌមួយ គឺព្រះអង្គសូមឲ្យរដ្ឋាភិបាលរក្សាព្រះដំណាក់នេះជាសារមន្ទីរជាតិ។ ចំណែកព្រះរាជទ្រព្យទី៣គឺព្រះរាជដំណាក់នៅទីក្រុងកែប។ ព្រះរាជដំណាក់ទីបីនេះគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះបរមរាជវាំង។

**សំណួរ៖ ដូច្នេះតើសម្តេចឪ នរោត្តម សីហនុ ជាក្សត្រដែលក្រជាងគេនៅក្នុងលោកមែនដែរឬទេ?**

**ចម្លើយ៖** តាមការប៉ាន់ស្មាន និងការយល់ដឹងរបស់ខ្ញុំគឺវាច្បាស់ណាស់ហើយដែលថាព្រះអង្គគឺជាក្សត្រក្រីក្រជាងគេនៅលើលោកនេះ។ គ្មានក្សត្រសោយរាជ្យណានៅលើពិភពលោកក្រដូចព្រះអង្គទេ។ ក្សត្រដទៃទៀតសុទ្ធតែមានទ្រព្យសម្បត្តិច្រើនជាងព្រះអង្គឆ្ងាយណាស់។

**សំណួរ ៖ តើហេតុអ្វីបានជាសម្តេចឪគ្មានព្រះរាជទ្រព្យច្រើនដូចគេ?**

**ចម្លើយ៖** មានមូលហេតុពីរ៖ទី១ គឺដោយសារព្រះអង្គជាពុទ្ធសាសនិកជនជ្រាលជ្រៅមួយព្រះអង្គ។ ព្រះអង្គថ្វាយបង្គំព្រះជារៀងរាល់ថ្ងៃ។ ព្រះអង្គសោយព្រះស្ងោយបួសនៅថ្ងៃសីល និងទី២ គឺដោយសារព្រះអង្គមានកំណើតនៅក្នុងវង្សត្រកូលក្សត្រដូច្នេះ ព្រះអង្គមានព្រះរាជទ្រព្យខ្លះដែលទទួលបានពីព្រះមាតា និងបិតា។ ព្រះអង្គមិនដែលមានព្រះរាជបន្ទូលថា ទ្រង់មានព្រះរាជបំណងចង់បាននេះឬនោះទេ។

**សំណួរ៖ តើអតីតព្រះមហាក្សត្រសម្តេចឪ នរោត្តម សីហនុ ចេះភាសាបរទេសចំនួនប៉ុន្មានដែរ?**

**ចម្លើយ៖** ព្រះអង្គរៀនភាសាក្រិក ភាសាឡាតាំង។ ភាសាពីរនេះជាឫសគល់នៃភាសាបារាំង។ និយាយជារួម ព្រះអង្គចេះនិយាយភាសាបារាំង អង់គ្លេស ចិន



www.elibraryofcambodia.org



និងភាសារុស្ស៊ីខ្លះដែរ។

**សំណួរ៖ ព្រះអង្គចេះភាសាច្រើន ចុះហេតុអ្វីបានជាព្រះអង្គចូលចិត្តប្រើភាសាបារាំងច្រើនជាងគេ?**

**ចម្លើយ៖** ព្រះករុណាសព្វព្រះរាជហឫទ័យភាសាបារាំងច្រើនជាងភាសាបរទេសផ្សេងទៀត ពីព្រោះលោកប្រសូត និងរៀនសូត្រក្នុងខណៈពេលដែលប្រទេសខ្មែរស្ថិតនៅក្រោមអាណានិគមនិយមបារាំង។ កាលណោះ ប្រទេសខ្មែរមានភាសាផ្លូវការពីរគឺភាសាខ្មែរដែលត្រូវបានគេប្រើប្រាស់ក្នុងចំណោមប្រជារាស្ត្រខ្មែរទូទៅ និងភាសាបារាំង។ ភាសាបារាំងត្រូវបានគេប្រើប្រាស់នៅក្នុងកិច្ចការរដ្ឋបាលនាសម័យនោះ។

**សំណួរ៖ក្នុងចំណោមក្សត្រខ្មែរទាំងអស់ តើសម្ដេចឪ នរោត្តម សីហនុ ចេះភាសាបារាំងច្បាស់ជាងគេមែនឬទេ?**

**ចម្លើយ៖** ភាសាបារាំងរបស់ព្រះអង្គពូកែខ្លាំងណាស់។ ពូកែទាំងរបៀបសរសេរ និងទាំងរបៀបប្រើប្រាស់អត្ថន័យអត្ថាបដិរូប(ន័យធៀប)។ ទាក់ទងទៅនឹងបញ្ហាភាសានេះ ខ្ញុំសូមរំឭករឿងមួយដើម្បីឲ្យប្រជារាស្ត្រខ្មែរយើងស្គាល់សម្ដេចឪឲ្យកាន់តែច្បាស់បន្ថែមទៀត។ ព្រះករុណាឧស្សាហ៍មានព្រះរាជបន្ទូលថា ព្រះអង្គមិនដែលសព្វព្រះរាជហឫទ័យចង់សោយរាជ្យទេ។ ព្រះអង្គសព្វព្រះរាជហឫទ័យចង់ក្លាយទៅជាគ្រូបង្រៀនផ្នែកអក្សរសាស្ត្រ។ មុនពេលដែលព្រះអង្គយាងសោយទិវង្គត ព្រះអង្គធ្លាប់មានបន្ទូលម្ដងទៀតថា ជាតិក្រោយព្រះអង្គសព្វព្រះរាជហឫទ័យក្លាយទៅជាគ្រូអក្សរសាស្ត្រផងដែរ។

**សំណួរ៖សម្ដេចឪ សម្ដេចតា សព្វព្រះរាជហឫទ័យច្រើនវិស័យមានដូចជា អក្សរសាស្ត្រ សិល្បៈ កីឡា ភាពយន្ត ។ល។ តើវិស័យមួយណាដែលព្រះអង្គសព្វព្រះរាជហឫទ័យខ្លាំងជាងគេ?**

**ចម្លើយ៖** ខ្ញុំគិតថា វាអាស្រ័យទៅតាមពេលវេលាទេ។ ប៉ុន្តែប្រសិនបើខ្ញុំត្រូវជ្រើសរើសមួយ ខ្ញុំគិតថា ព្រះករុណាសម្ដេចតាសព្វព្រះរាជហឫទ័យលើការសរសេរខ្លាំងជាងគេ។ សរសេរគ្រប់រឿងរ៉ាវទាំងអស់។ បន្ទាប់មកវិស័យភ្លេង និងបន្ទាប់មកទៀត គឺវិស័យភាពយន្ត។



www.elibraryofcambodia.org



**សំណួរ ៖ ចុះក្នុងវិស័យកីឡាវិញ តើសម្តេចតាចូលចិត្តកីឡាអ្វីខ្លះដែរ ?**

**ចម្លើយ ៖** សម្តេចតាសព្វព្រះរាជហឫទ័យខ្លាំងលើកីឡាជិះសេះ បន្ទាប់មកកីឡាបាល់ទាត់។ ព្រះអង្គស្គាល់ក្រុមកីឡាបារាំង អង់គ្លេសនិងអាល្លឺម៉ង់ច្បាស់តែម្តង។ ក្រៅពីកីឡាជិះសេះ និងកីឡាបាល់ទាត់ ព្រះអង្គសព្វព្រះរាជហឫទ័យលើកីឡាវាយសី។

**សំណួរ ៖ ចំពោះម្ហូបអាហារវិញ តើសម្តេចតាសព្វព្រះរាជហឫទ័យម្ហូបអ្វីដែរ ?**

**ចម្លើយ ៖** ( និយាយជាភាសាបារាំងបន្តិចមុននឹងឆ្លើយ )។ បើនិយាយតាមពាក្យបារាំងមានន័យថា លោកសព្វព្រះរាជហឫទ័យខ្លាំងតែម្ហូបណាដែលឆ្ងាញ់ មិនថាម្ហូបខ្មែរឬម្ហូបបារាំងទេ។ នៅទីក្រុងប៉េកាំង ព្រះករុណាសោយម្ហូបបីមុខ។ ម្ហូបខ្មែរ ចិន និងម្ហូបបារាំង។ ម្ហូបខ្មែរធ្វើដោយចុងភៅខ្មែរ។ ម្ហូបបារាំង និងម្ហូបចិនរៀបចំចម្អិនដោយចុងភៅជនជាតិចិន។ លើសពីនេះទៅទៀត នៅមានរឿងពិសេសមួយដែលមិនសូវត្រូវបានគេផ្សព្វផ្សាយគឺព្រះករុណាចេះធ្វើម្ហូបអាហារផ្ទាល់ព្រះអង្គតែម្តង។ ពេលខ្លះក្នុងឆ្នាំ១៩៧០ ព្រះអង្គថែមទាំងបង្រៀនចុងភៅជនជាតិចិនពីរបៀបធ្វើម្ហូបបារាំងថែមទៀតផង។

**សំណួរ ៖ តើសម្តេចតាចេះធ្វើម្ហូបខ្មែរឬទេ ?**

**ចម្លើយ ៖** ( សើចញឹមៗ ) និយាយឲ្យត្រង់ទៅ ខ្ញុំមិនដែលឃើញព្រះអង្គធ្វើម្ហូបខ្មែរទេ។

**សំណួរ ៖ តើព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ សព្វព្រះរាជហឫទ័យធ្វើការនៅពេលណាដែរ ពេលព្រឹក ពេលយប់ ឬពេលថ្ងៃ ?**

**ចម្លើយ ៖** កាលពីជំនាន់សង្គមរាស្ត្រនិយម ព្រះករុណាចូលចិត្តទ្រង់ការ( ធ្វើការ ) ពេលព្រឹកព្រលឹម និងពេលយប់ជ្រៅ។ ពេលខ្លះទៀត ព្រះករុណាទ្រង់ទតភាពយន្តផង និងធ្វើការផង។ ប៉ុន្តែចាប់តាំងពីឆ្នាំ២០១០មក ព្រះករុណាទ្រង់ការតិចជាងមុនដោយសារព្រះអង្គមានព្រះជន្មច្រើនហើយ។

**សំណួរ ៖ តើព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ ជាក្សត្រដែលមានបុគ្គលិកលក្ខណៈយ៉ាងដូចម្តេចដែរ ស្លូត កាច តឹងរ៉ឹង ?**

**ចម្លើយ ៖** ខ្ញុំគិតថា ព្រះករុណាជាអង្គក្សត្រទន់ភ្លន់ ប៉ុន្តែមិនមែនមានន័យថាស្លូតទេ។ ក្នុងការងារ ព្រះអង្គតឹងរ៉ឹង និងហ្មត់ចត់ខ្លាំងណាស់។ រឿងមួយទៀតដែលព្រះករុណាតឹងរ៉ឹងបំផុតគឺការគោរពពេលវេលា។ ព្រះអង្គតែងតែមកចាំគេ ១ម៉ោងមុន ប្រសិនបើមានភ្ញៀវចង់ចូលមកគាល់ព្រះអង្គ។ ព្រះករុណាគោរពឃ្លាជាភាសាបារាំងមួយដែលនិយាយថា ភាពទៀងពេលវេលាឬការគោរពពេលវេលាគឺជាការគួរសមរបស់ព្រះមហាក្សត្រ( La ponctualité est la politesse du Roi )។ ព្រះករុណាតែងតែយកឃ្លានេះមកធ្វើជាច្បាប់របស់ព្រះអង្គ។

**សំណួរ ៖ តើព្រះអង្គធ្លាប់មានមោទនភាពដែរឬទេ ដែលបានធ្វើការជាមួយសម្តេចឪអស់រយៈពេលជាង៣០ឆ្នាំមកនេះ ?**

**ចម្លើយ ៖** ដូចលោកបានដឹងហើយថា ព្រះករុណាជាអង្គក្សត្រមួយអង្គដែលមានភាពល្បីល្បាញមិនត្រឹមតែក្នុងប្រទេសទេ តែជាលក្ខណៈអន្តរជាតិថែមទៀតផង។ ដូច្នេះ ក្នុងនាមខ្ញុំដែលបានបម្រើក្សត្រល្បីល្បាញមួយអង្គ ស្ថិតនៅកៀក និងយូរយ៉ាងដូច្នេះ ខ្ញុំគិតថាគឺជាកិត្តិយសដ៏ធំរបស់ខ្ញុំមិនអាចបំភ្លេចបាន។ ខ្ញុំគិតថា គ្មានអ្វីអាចប្រៀបធៀបនឹងកិត្តិយសនេះបានឡើយ៕



www.elibraryofcambodia.org

www.elibraryofcambodia.org

វិភាគ ៖

ព្រះមហាវីរក្សត្រ

និងការងារសង្គម

ដោយ

លោក ប៉ែន បូណា



www.elibraryofcambodia.org

# ព្រះមហាវីរក្សត្រ នរោត្តម សីហនុ ចាប់យកការងារសង្គមកិច្ចជាស្នូល

***ប្រជាប្រិយភាពគ្មានគូប្រៀបរបស់អង្គសម្តេចឪដែលបានស្តែងឡើងយ៉ាងច្បាស់ខណៈដែលព្រះអង្គសោយទិវង្គតនៅពេលនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការងារសង្គមកិច្ចដែលព្រះអង្គបានបំពេញយ៉ាងសកម្មបំផុត។ តាំងពីវ័យក្មេងរហូតដល់វ័យចាស់ជរា ក្នុងនាមជាមហាក្សត្រនិងក្នុងនាមជាអ្នកនយោបាយ សម្តេចព្រះ នរោត្តម សីហនុ បានចាត់ទុកការងារសង្គមកិច្ចជាជីវិតប្រចាំថ្ងៃរបស់ទ្រង់។ តើហេតុអ្វីបានជាសម្តេចព្រះ នរោត្តម សីហនុ ឲ្យតម្លៃខ្លាំងទៅលើការងារសង្គមកិច្ច ?***

ក្នុងចំណោមសកម្មភាពរបស់សម្តេចព្រះ នរោត្តម សីហនុ ក្នុងនាមជាមេដឹកនាំប្រទេសក៏ដូចជាក្នុងនាមព្រះមហាក្សត្រដែរ សកម្មភាពមួយដែលព្រះអង្គតែងបំពេញជាប្រចាំគឺការងារសង្គមកិច្ច។ ការជីកស្រះអណ្តូងទឹក សង់សាលារៀន មណ្ឌលសុខភាពរហូតដល់សង់ផ្ទះជូនជនក្រីក្រ... ជាអ្វីដែលគេបានឃើញ ចាប់តាំងពីព្រះអង្គលេចមុខមាត់ក្នុងសង្គម និងឆាកនយោបាយប្រទេសកម្ពុជារយៈពេល៧០ឆ្នាំចុងក្រោយនេះ។



អង្គសម្តេចឪមិនត្រឹមតែឲ្យតម្លៃទៅលើគោលនយោបាយសង្គមកិច្ចប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គថែមទាំងបានចុះធ្វើកិច្ចការនេះដោយផ្ទាល់ព្រះអង្គទៀតផង ។អ្នកដែលបានឃើញផ្ទាល់ឬឯកសារនានាដែលនៅសេសសល់ គឺជាតឹកតាងបញ្ជាក់ពីបញ្ហានេះបាន។ ចុងក្រោយនេះ បើទោះបីជាព្រះអង្គមានវ័យកាន់តែចាស់ជរាមិនអាចយាងចុះធ្វើសកម្មភាពបាន តែសម្តេចឪក៏នៅតែមិនបោះបង់ការងារសង្គមកិច្ចនេះដែរ។ ព្រះអង្គសុខចិត្តបើកសម្ពោធសមិទ្ធផលនានាដូចជាស្រះទឹក ប្រឡាយទឹក ឬមណ្ឌលសុខភាពជាដើម ជានិមិត្តរូបនៅក្នុងព្រះបរមរាជវាំងតាមរយៈពិព័រណ៍រូបថតដោយអនុញ្ញាតឲ្យតំណាងប្រជាពលរដ្ឋ និងអាជ្ញាធរដែនដីចូលរួម។

ជួនកាលទៀត ទោះជាពេលដែលព្រះអង្គគង់ប្រថាប់ព្យាបាលព្រះកាយនៅឯទីក្រុងប៉េកាំងប្រទេសចិនក៏ដោយ ក៏ព្រះអង្គឆ្លៀតសម្ពោធសមិទ្ធផលជានិមិត្តរូបដូចនៅក្នុងព្រះបរមរាជវាំងទីក្រុងភ្នំពេញដែរ។ នេះសបញ្ជាក់ឲ្យឃើញថាការងារសង្គមកិច្ចត្រូវបានព្រះមហាវីរក្សត្រចាត់ទុកជាការងារចម្បង និងកិច្ចការប្រចាំថ្ងៃរបស់ព្រះអង្គមិនអាចខកខានបាន។

ជាការពិត ប្រសិនបើគេសិក្សាអំពីចរិតលក្ខណៈរបស់សម្តេចព្រះនរោត្តម សីហនុ កាលពីទ្រង់នៅក្មេងគេពិបាកនឹងជឿណាស់ថាព្រះអង្គអាចក្លាយជាមហាក្សត្រ និងជាអ្នកដឹកនាំដែលយកការងារសង្គមកិច្ច និងភាពស្និទ្ធស្នាលជាមួយប្រជារាស្ត្រជាកិច្ចការសំខាន់របស់ព្រះអង្គយ៉ាងដូច្នេះសោះ។ ពិបាកជឿដោយហេតុថា ព្រះអង្គជាសមាជិករាជវង្ស ដែលចូលចិត្តការសប្បាយជាមួយបទភ្លេង ចម្រៀង សិល្បៈ ភាពយន្តជាដើម។ លក្ខណៈនេះហើយដែលត្រូវគេមើលឃើញថាបារាំងបានជ្រើសរើសព្រះអង្គឲ្យសោយរាជ្យដោយសង្ឃឹមថា ពួកគេអាចងាយនឹងបង្វិលព្រះអង្គតាមអ្វីដែលពួកគេចង់បាន។

ប៉ុន្តែផ្ទុយស្រឡះចាប់តាំងពីពេលដែលព្រះអង្គបានឡើងគ្រងរាជ្យតាំងពីឆ្នាំ១៩៤១ត្រឹមព្រះជន្ម១៩ព្រះវស្សាសោះ អតីតព្រះមហាក្សត្របានចាប់យកការងារសង្គមកិច្ចជាសំខាន់ និងបានបំពេញព្រះរាជបុជនីយកិច្ចសំខាន់ៗជាច្រើន ដើម្បីប្រយោជន៍ប្រទេសជាតិ ក្នុងនោះក៏មានការទាមទារឯករាជ្យពីបារាំងផងដែរ។

www.elibraryofcambodia.org

ជាការពិតណាស់ ការងារសង្គមកិច្ចគឺជាកិច្ចការសំខាន់ខ្លាំងណាស់សម្រាប់អ្នកនយោបាយ និងអ្នកដឹកនាំប្រទេស។ សំខាន់នៅត្រង់ថា ការងារនេះផ្ដល់ប្រយោជន៍ដល់សាធារណជនផង និងផ្ដល់ប្រជាប្រិយភាពដល់ខ្លួនឯងផង។ នៅក្នុងសង្គមមួយដែលក្រីក្រដូចកម្ពុជា សេចក្ដីត្រូវការចម្បងរបស់ពលរដ្ឋជាពិសេសអ្នកក្រីក្របំផុត គឺគ្មានអ្វីក្រៅពីស្រះទឹក ប្រឡាយទឹកសម្រាប់ប្រើប្រាស់ និងបង្កបង្កើនផលមណ្ឌលសុខភាពសម្រាប់ព្យាបាលជំងឺ និងសាលារៀនសម្រាប់ឲ្យកូនចៅបានរៀនសូត្រនោះឡើយ។ ការឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ពួកគេគឺជាគន្លឹះក្នុងការកសាងប្រជាប្រិយភាពដ៏រឹងមាំ។



ក្រៅពីការចាប់យកការងារសង្គមកិច្ចនៅក្នុងដៃព្រះមហាវីរក្សត្រសម្ដេចព្រះនរោត្តម សីហនុនៅមានចំណុចពិសេសមួយទៀតដែលពិបាកនឹងមានអ្នកធ្វើដូចនោះ គឺការបង្ហាញភាពស្និទ្ធស្នាលកក់ក្ដៅប្រកបដោយកាយវិការទន់ភ្លន់យ៉ាងពិសេសទៅកាន់ប្រជារាស្ត្ររបស់ព្រះអង្គ។ កាយវិការនេះបានធ្វើឲ្យអ្នកដែលបានជួបជាមួយព្រះអង្គមិនថាប្រជារាស្ត្រសាមញ្ញឬភ្ញៀវជាតិអន្តរជាតិឡើយពិតជាដក់ជាប់អនុស្សាវរីយ៍មិនអាចបំភ្លេចបាន។

សរុបមក ទាំងការងារនយោបាយ សង្គមកិច្ច និងទាំងចរិតលក្ខណៈផ្ទាល់របស់ព្រះអង្គសុទ្ធតែបានឆ្លើយតបយ៉ាងល្អ និងយ៉ាងស៊ីចង្វាក់ទៅនឹងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋខ្មែរ។ ដោយឡែកការងារសង្គមកិច្ចដែលត្រូវបានព្រះអង្គចាត់ទុកជាស្នូលនៃជីវិតរបស់ព្រះអង្គតាំងពីក្មេងរហូតដល់ចាស់នោះ គឺជាទស្សនវិជ្ជាដែលផ្ដល់អត្ថប្រយោជន៍ធំធេងដល់ប្រទេសជាតិ និងប្រជាពលរដ្ឋ។ ទស្សនវិជ្ជានេះគឺជាកេរដំណែលដ៏មានតម្លៃសម្រាប់កូនចៅជំនាន់ក្រោយ ជាពិសេសសម្រាប់អ្នកនយោបាយ និងអ្នកដឹកនាំប្រទេសតែម្ដង។













www.elibraryofcambodia.org

# អតីតព្រះមហាវីរក្សត្រ
# និង ភាពអច្ឆរិយៈ
ដោយ
**លោក ម៉ែន មុណា**


www.elibraryofcambodia.org

# ជំនឿលើ «បុណ្យបារមី»

# របស់ព្រះអង្គនៅតែពេញនិយម

***រយៈពេល៧ថ្ងៃនៃការកាន់ទុក្ខសម្រាប់ការសោយទិវង្គតរបស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ បានដល់ទីបញ្ចប់ហើយកាលពីល្ងាចថ្ងៃទី២៣តុលា។ ពិធីជួបជុំសូត្រធម៌ដ៏ធំមួយត្រូវបានរៀបចំធ្វើឡើងនៅមុខព្រះបរមរាជវាំង ដោយមានព្រះសង្ឃ១ម៉ឺនអង្គ និងពលរដ្ឋមកពីគ្រប់ទិសទីចំនួនជាង ១០ ម៉ឺននាក់។ នេះសបញ្ជាក់ឲ្យឃើញថា ប្រជាប្រិយភាពរបស់សម្តេចឪ មានសភាពធំធេងខ្លាំងណាស់នៅក្នុងចំណោមប្រជាពលរដ្ឋខ្មែរ។ ប្រជាប្រិយភាពដ៏ខ្លាំងក្លានេះត្រូវគេមើលឃើញថា បានមកពីអានុភាពពីរយ៉ាង គឺភាពប៉ិនប្រសប់ក្នុងការដឹកនាំ និងជំនឿលើបុណ្យបារមីរបស់ព្រះអង្គ។***

មានព្រឹត្តិការណ៍ច្រើនយ៉ាងណាស់ដែលបានកើតឡើងចាប់តាំងពីការសោយទិវង្គតរបស់ព្រះមហាវីរក្សត្រសម្តេចព្រះ នរោត្តម សីហនុ ហើយដែលគេអាចលើកយកពន្យល់បានអំពីប្រជាប្រិយភាពដ៏អស្ចារ្យរបស់ព្រះអង្គ។

សម្រាប់ក្រុមអ្នកវិភាគព្រឹត្តិការណ៍សង្គម និងនយោបាយប្រទេសកម្ពុជា ប្រជាប្រិយភាពដល់កម្រិតកំពូលរបស់អ្នកដឹកនាំ ( និយាយជារួម ) និងរបស់សម្តេចព្រះ នរោត្តម សីហនុ ( និយាយដោយឡែក ) កើតឡើងដោយសារអានុភាពពីរគឺ ទី១ជា «អានុភាពក្នុងខ្លួន» គឺទេពកោសល្យក្នុងការដឹកនាំដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ទី២គឺជា«អានុភាពក្រៅខ្លួន» គឺជំនឿរបស់ប្រជារាស្ត្រខ្មែរដែលថាព្រះអង្គជាក្សត្រដែលមាន«បុណ្យបារមី»។

ជាការពិតណាស់ សម្តេចឪជាអង្គព្រះមហាក្សត្រ និងជាអ្នកដឹកនាំដ៏មានទេពកោសល្យម្នាក់ ដែលពិបាកនឹងមានអ្នកណាធ្វើដូច។ ទេពកោសល្យពិសេសរបស់ព្រះអង្គគឺការចេះដាក់ខ្លួននៅកៀកកិតជាមួយប្រជារាស្ត្រសាមញ្ញ។ ក្នុងនាមជាមហាក្សត្រ និងជាអ្នកដឹកនាំ ព្រះអង្គបានបង្ហាញឲ្យប្រជារាស្ត្របានឃើញថា ទ្រង់មិនប្រកាន់ខ្លួនថាជាក្សត្រដែលត្រូវនៅពីលើខ្ពស់ផុតពីប្រជារាស្ត្រឡើយ ប៉ុន្តែ ព្រះអង្គបានដាក់ខ្លួនឲ្យនៅជាប់នឹងប្រជារាស្ត្រជានិច្ច។ ម្យ៉ាងទៀត សមិទ្ធផលធំៗដែលព្រះអង្គសម្រេចបានសម្រាប់ប្រទេសជាតិ និងប្រជារាស្ត្រ គឺជាតឹកតាងមិនអាចប្រកែកបាន។ នេះជាសមត្ថភាពដែលកើតចេញពីការខិតខំប្រឹងប្រែងរបស់ព្រះអង្គក្នុងនាមជាអ្នកដឹកនាំ។

ប៉ុន្តែ ទន្ទឹមនឹងនោះដែរ សម្តេចព្រះ នរោត្តម សីហនុ



*រូបដែលកែច្នៃដោយអ្នកប្រើប្រាស់បណ្តាញហ្វេសប៊ុក ខណៈមហាជនបាននិយាយប្រកបដោយភាពជឿជាក់ និងស្ញប់ស្ញែងថា ពួកគាត់បានឃើញព្រះភក្ត្ររបស់សម្តេចឪនៅក្នុងព្រះខែ។*

ត្រូវបានពលរដ្ឋខ្មែរជាទូទៅជឿថា ជាអ្នកមាន«បុណ្យបារមី» លើសពីមនុស្សធម្មតា។ ជំនឿនេះហើយដែលបានបន្ថែមប្រជាប្រិយភាពដល់ព្រះអង្គកាន់តែខ្លាំងឡើងថែមទៀត។ មានហេតុការណ៍ច្រើនយ៉ាងណាស់ដែលគេអាចលើកជាឧទាហរណ៍បញ្ជាក់ពីបញ្ហានេះបាន។ ជាក់ស្តែង តាំងពីព្រះអង្គស្ថិតនៅជាអ្នកដឹកនាំសង្គមរាស្ត្រនិយម ពលរដ្ឋខ្មែរជាទូទៅជឿថា ពេលដែលព្រះអង្គយាងចេញទៅទីណាម្តងៗ មេឃក៏ចាប់ផ្តើមស្រទំគ្មានពន្លឺថ្ងៃដែលអនុញ្ញាតឲ្យព្រះអង្គបានបំពេញព្រះរាជបេសកកម្មសួរសុខទុក្ខប្រជារាស្ត្រ ដោយគ្មានការរំខានពីអាកាសធាតុ។ ហេតុការណ៍នេះត្រូវបានគេជឿថា បណ្តាលមកពីបុណ្យបារមីរបស់ព្រះអង្គ។

ជំនឿបែបនេះនៅតែជិតជាមជាប់យ៉ាងរឹងមាំក្នុងផ្នត់គំនិត



www.elibraryofcambodia.org











ពលរដ្ឋខ្មែរជាទូទៅហ្មតមកទល់បច្ចុប្បន្នដោយឥតប្រែប្រួល បើទោះបីជាសង្គមមានការវិវត្តយ៉ាងណាក៏ដោយ។ ជាក់ស្តែង ពេលដែលបានទទួលព័ត៌មានស្តីពីការសោយទិវង្គតរបស់ព្រះអង្គ កាលពីថ្ងៃទី១៥តុលា ពលរដ្ឋខ្មែរជាទូទៅបាននាំគ្នាសម្តែងក្តីរន្ធត់តក់ស្លុតយ៉ាងខ្លាំង។ មហាជនរាប់លាននាក់ដែលចេញមកដង្ហែព្រះបរមសពរបស់សម្តេចឪកាលពីថ្ងៃទី១៧តុលា គឺជាឧទាហរណ៍មិនអាចប្រកែកបានអំពីទឹកចិត្តគោរពស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ពួកគេចំពោះអង្គសម្តេចឪ។

លើសពីនេះ មានហេតុការណ៍មួយចំនួនដែលមហាជនខ្មែរនៅតែចាត់ទុកជា«អព្ភូតហេតុ»ដ៏អស្ចារ្យដែលភ្ជាប់ទៅនឹងបុណ្យបារមីរបស់ព្រះអង្គ។ ឧទាហរណ៍ មហាជនបាននាំគ្នាផ្អើលនិយាយថា មេឃបានប្រែក្លាយជាស្រទំ នៅពេលដែលព្រះបរមសពរបស់ទ្រង់បានមកដល់ព្រលានយន្តហោះ។ បន្ទាប់មកទៀត មហាជនទូទាំងប្រទេសបាននាំគ្នាផ្អើលមើលព្រះចន្ទកាលពីយប់ថ្ងៃទី២១តុលា ដោយពួកគេអះអាងថា បានឃើញព្រះភក្ត្រសម្តេចឪនៅក្នុងផ្ទៃព្រះចន្ទ។

ទោះជាគ្មានអ្វីមកបញ្ជាក់ឲ្យបានច្បាស់លាស់ ទោះជារឿងពិត ឬមិនពិត ? ទោះជាសមហេតុផល ឬមិនសម ? និងទោះជាអ្នកខ្លះចាត់ទុកជាជំនឿហួសសម័យ ប៉ុន្តែ នេះជាអ្វីដែលមហាជនខ្មែរជាទូទៅនៅតែជឿយ៉ាងមុតមាំ ហើយជាជំនឿចេញពីបេះដូង។ ដូច្នេះ គេប្រាកដជាអាចនិយាយបានថា ប្រជាប្រិយភាពគ្មានគូប្រៀបរបស់អង្គសម្តេចឪពិតជាបានមកពីអានុភាពក្នុងខ្លួនផង និងក្រៅខ្លួនផងរបស់ព្រះអង្គ។ ជំនឿនេះនៅតែមានឥទ្ធិពលយ៉ាងខ្លាំង និងបានចាក់ឫសយ៉ាងជ្រៅទៅក្នុងសង្គមតាំងពីយូរយោរណាស់មកហើយ។

ទោះជាពិត ឬមិនពិត ប៉ុន្តែ មេដឹកនាំណាដែលអាចទាញយកអានុភាពទាំងពីរយ៉ាងនេះបាន គឺជាអ្នកដែលមានប្រជាប្រិយភាពគ្មានគូប្រជែង។ នេះមានន័យថា សង្គមកម្ពុជាក្នុងសតវត្សរ៍ទី ២១ នេះ នៅតែផ្តល់តម្លៃដល់ជំនឿលើបុណ្យបារមីយ៉ាងខ្លាំងដដែល៕



www.elibraryofcambodia.org





www.elibraryofcambodia.org

សំណង់
ព្រះបរមមេរុ
តម្លៃប្រហែល ១,២លានដុល្លារអាមេរិក
( ប្រភព ៖ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន )
និង
កម្រងរូបភាពផ្សេងៗ
នៃព្រះរាជពិធីជង្ហែសាកល្បង


www.elibraryofcambodia.org









www.elibraryofcambodia.org









www.elibraryofcambodia.org











www.elibraryofcambodia.org













www.elibraryofcambodia.org

















www.elibraryofcambodia.org















www.elibraryofcambodia.org











www.elibraryofcambodia.org











www.elibraryofcambodia.org







www.elibraryofcambodia.org













www.elibraryofcambodia.org





www.elibraryofcambodia.org











www.elibraryofcambodia.org











www.elibraryofcambodia.org











www.elibraryofcambodia.org











www.elibraryofcambodia.org









ការបាញ់សាកល្បងបច្ចេកទេសកាំភ្លើងធំ១០៥មិល្លីម៉ែត្រ ១០១ណាត់នៅកងពលតូចទ័ពពិសេស
ឆត្រយោង៩១១ ក្នុងខណ្ឌពោធិ៍សែនជ័យ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣។



www.elibraryofcambodia.org





www.elibraryofcambodia.org

# សេចក្តីជូនដំណឹង
# សារាចរណែនាំ
# និងព្រះរាជក្រឹត្យផ្សេងៗ
# ក្រោយការយាងចូលទិវង្គត
# របស់
# ព្រះមហាវីរក្សត្រ
# ព្រះវររាជបិតាឯករាជ្យ
# បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ


www.elibraryofcambodia.org

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣១សរ

# សេចក្ដីថ្លាយ និងជូនដំណឹង

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សូមក្រាបបង្គំទូលថ្វាយ សម្ដេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្ដេចព្រះសង្ឃនាយក សម្ដេចព្រះសង្ឃ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជម្រាបជូន បងប្អូនជនរួមជាតិ និងប្រិយមិត្តបរទេសទាំងអស់ សូមព្រះមេត្តាជ្រាប និងសូមមេត្តាជ្រាបថា៖

**ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ព្រះអង្គបានយាងចូលព្រះទីវង្គត់ នៅថ្ងៃ ១៥ រោជ ខែកត្តិកបទផ្ទាំពេងចត្វាស័ក ព.ស. ២៥៥៦ត្រូវនឹងថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០១:២០ នាទីរំលងអធ្រាត (ម៉ោងនៅរាជធានីភ្នំពេញ) ក្នុងព្រះជន្មាយុ ៩០ ព្រះវស្សា ដោយព្រះជរាពាធ នៅមន្ទីរពេទ្យ ទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នឹងដង្ហែព្រះសពពីសាធារណរដ្ឋប្រជាមានិតចិន មកកាន់រាជធានីភ្នំពេញ ដើម្បីតម្កល់ និងប្រារព្ធព្រះរាជពិធីបុណ្យតាមប្រពៃណីជាតិនៅព្រះបរមរាជវាំង។

សេចក្ដីដូចបានក្រាបបង្គំទូលថ្វាយ និងជម្រាបជូនខាងលើនេះ សូមសម្ដេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្ដេចព្រះសង្ឃនាយក សម្ដេចព្រះសង្ឃ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ និងជូនបងប្អូនជនរួមជាតិនិងប្រិយមិត្តបរទេសទាំងអស់សូមព្រះមេត្តាជ្រាបនិងសូមមេត្តាជ្រាប។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២


www.elibraryofcambodia.org

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១១ សរណន

# សារាចរណែនាំ

## ស្តីពី

## ការចូលរួមគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ

ដើម្បីចូលរួមគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមសព **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ និងជាព្រះស្វាមី **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ដែលព្រះអង្គបានសោយទិវង្គត នៅថ្ងៃទី ១៥ រោច ខែ ភទ្របទ ឆ្នាំ រោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០១:២០ នាទី រំលងអធ្រាត្រ (ម៉ោងនៅរាជធានីភ្នំពេញ) ក្នុងព្រះជន្មាយុ ៩០ ព្រះវស្សា ដោយព្រះជរាពាធ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ៖

១. ប្រកាសថ្ងៃកាន់ទុក្ខគោរពព្រះវិញ្ញាណក្ខន្ធ ជាផ្លូវការរយៈពេល ០៧ ថ្ងៃ ចាប់ពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១២ រហូតដល់ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ ។

២. ក្នុងរយៈពេលកាន់ទុក្ខនេះ គ្រប់ស្ថាប័នរដ្ឋ និងឯកជន ព្រមទាំងប្រជាពលរដ្ឋទូទាំងប្រទេស ត្រូវបង្ហូតទង់ជាតិ ត្រឹម ១/៣ (មួយភាគបី) នៃដងទង់ជាតិ ចាប់ពីលើ ។

៣. គ្រប់ស្ថានីយ៍វិទ្យុនិងទូរទស្សន៍ជាតិ និងឯកជន ព្រមទាំងកន្លែង កំសាន្តសប្បាយ ត្រូវផ្អាក ការផ្សាយនូវទស្សនីយភាព ការសម្តែង និងការប្រគុំតន្ត្រីផ្សេងៗ ដែលមានលក្ខណៈ សប្បាយត្រឹកត្រអាល ក្នុងរយៈពេល៧ថ្ងៃនេះ។

៤. គ្រប់ស្ថានទូត និងស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវត្រៀមរៀបចំ ទីកន្លែង ព្រះឆាយាលក្ខណ៍ នៃ **ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** និងសៀវភៅសម្រាប់ចុះមរណទុក្ខ។



www.elibraryofcambodia.org

កាលបរិច្ឆេទជាក់ស្តែង ដែលអនុញ្ញាតឱ្យភ្ញៀវទាំងអស់អញ្ជើញចូលរួមមរណទុក្ខ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនឹងជូនព័ត៌មាននៅពេលក្រោយ ។

៥. ប្រជាពលរដ្ឋគ្រប់រូប ពាក់សញ្ញាកាន់មរណទុក្ខ និងតុបតែងសញ្ញាកាន់មរណទុក្ខនៅលើព្រះឆាយាលក្ខណ៍ក្នុងរយៈពេលកាន់ទុក្ខនេះ។

៦. ខាងលើនេះគឺជាការកាន់មរណទុក្ខលើកទី១។ ព្រះបរមសពនឹងត្រូវតម្កល់ទុកក្នុងរយៈពេលមិនតិចជាង៣ខែនៅព្រះបរមរាជវាំង មុនពេលប្រារព្ធព្រះរាជពិធីបូជាព្រះបរមសព ហើយកាលបរិច្ឆេទជាក់ស្តែងនៃព្រះរាជពិធីបូជាព្រះបរមសព នឹងជម្រាបជូននៅពេលក្រោយ។ ក្នុងរយៈពេល៣ខែនេះ មន្ត្រីរាជការ ប្រជាពលរដ្ឋ និងមិត្តភក្តិបរទេសទាំងអស់អាចចូលមកគោរពព្រះវិញ្ញាណក្ខន្ធបាន។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន គ្រប់អាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គ្រប់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងជនរួមជាតិ ប្រជាជនទូទាំងប្រទេសត្រូវចូលរួមអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាកិច្ចចូលរួមមរណទុក្ខដ៏ក្រៀមក្រំរកទីបំផុតគ្មាននេះ។

ថ្ងៃទី១៥ ខែ តុលា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ



www.elibraryofcambodia.org

# ព្រះរាជក្រឹត្យ

នស/រកត/០០១២/៤៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា នីតិកាលទី៣ នាសម័យប្រជុំដំបូងនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១២
- បានទ្រង់យល់លទ្ធផលបោះឆ្នោតជាកញ្ចប់របស់រដ្ឋសភាកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៦៥ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០៤ ស្តីពីការតែងតាំងសម្តេចចៅហ្វាវាំង វរៀងជ័យ អធិបតីស្រីវង្ការ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព ព្រះករុណាព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ដូចមានសមាសភាពខាងក្រោម៖

| | | | |
|---|---|---|---|
| ១. សម្តេចអគ្គមហាធម្មពោធិសាល | ជា ស៊ីម | ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២. សម្តេចអគ្គមហាពញាចក្រី | ហេង សំរិន | ប្រធានរដ្ឋសភា | អនុប្រធាន |
| ៣. សម្តេចអគ្គមហាសេនាបតីតេជោ | ហ៊ុន សែន | នាយករដ្ឋមន្ត្រី | អនុប្រធានប្រចាំការ |
| ៤. សម្តេចចៅហ្វាវាំង | គង់ សំអុល | ឧបនាយករដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. ឯកឧត្តម | ស ខេង | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៦. ឯកឧត្តម | សុខ អាន | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |

ROYAUME du CAMBODGE · LE MINISTRE du PALAIS ROYAL



www.elibraryofcambodia.org

| | | | |
|---|---|---|---|
| ៧. ឯកឧត្តម | ទៀ បាញ់ | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៨. ឯកឧត្តម | ហោ ណាំហុង | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៩. លោកជំទាវ | ម៉ែន សំអន | ឧបនាយករដ្ឋមន្ត្រីប្រចាំការ | អនុប្រធាន |
| ១០. ឯកឧត្តម | ប៊ិន ឈិន | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១១. ឯកឧត្តម | ញឹក ប៊ុនឆៃ | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១២. ឯកឧត្តម | គាត ឈន់ | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១៣. ឯកឧត្តម | យឹម ឆៃលី | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១៤. ឯកឧត្តម | កែ គឹមយ៉ាន | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១៥. ឯកឧត្តម | អ៊ឹម ឈុនលឹម | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៦. ឯកឧត្តម | ឱម យ៉ិនទៀង | ទេសរដ្ឋមន្ត្រី | សមាជិក |
| ១៧. ឯកឧត្តម | ខៀវ កាញារីទ្ធ | រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| ១៨. ឯកឧត្តម | ហ៊ឹម ឆែម | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៩. ឯកឧត្តម | មិន ឃិន | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | សមាជិក |
| ២០. ឯកឧត្តម | ម៉ម ប៊ុនហេង | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ២១. ឯកឧត្តម | អ៊ឹម សិទ្ធី | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២២. ឯកឧត្តម | នេត សាវឿន | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ២៣. ឯកឧត្តម | សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៤. ឯកឧត្តម | ម៉ៅ ហាវណ្ណាល់ | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ២៥. ឯកឧត្តម | ស្វាយ ស៊ីថា | ប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស | សមាជិក |
| ២៦. ឯកឧត្តម | កែប ជុតិមា | អភិបាលរាជធានីភ្នំពេញ | សមាជិក |
| ២៧. ឯកឧត្តម | ស្បោង សារ៉ាត | អភិបាលខេត្តព្រះសីហនុ | សមាជិក |
| ២៨. ឯកឧត្តម | កែន សត្ថា | អភិបាលខេត្តកែប | សមាជិក |
| ២៩. ឯកឧត្តម | អ៊ី ឈាន | អភិបាលខេត្តប៉ៃលិន | សមាជិក |
| ៣០. ឯកឧត្តម | ឈុន ស៊ីរុន | អភិបាលខេត្តកណ្ដាល | សមាជិក |
| ៣១. ឯកឧត្តម | ហាស់ សារ៉េត | អភិបាលខេត្តព្រៃវែង | សមាជិក |
| ៣២. ឯកឧត្តម | ជៀង អំ | អភិបាលខេត្តស្វាយរៀង | សមាជិក |
| ៣៣. ឯកឧត្តម | ហ៊ុន ណេង | អភិបាលខេត្តកំពង់ចាម | សមាជិក |
| ៣៤. ឯកឧត្តម | ស្រី ថេន | អភិបាលខេត្តតាកែវ | សមាជិក |
| ៣៥. ឯកឧត្តម | ខួយ ឃុនហួរ | អភិបាលខេត្តកំពត | សមាជិក |
| ៣៦. ឯកឧត្តម | ប៊ុន លឿត | អភិបាលខេត្តកោះកុង | សមាជិក |
| ៣៧. ឯកឧត្តម | កង ហ៊ាង | អភិបាលខេត្តកំពង់ស្ពឺ | សមាជិក |
| ៣៨. ឯកឧត្តម | ឈុន ឈន់ | អភិបាលខេត្តកំពង់ធំ | សមាជិក |
| ៣៩. ឯកឧត្តម | ទូច ម៉ារឹម | អភិបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| ៤០. ឯកឧត្តម | ខួយ សុខា | អភិបាលខេត្តពោធិ៍សាត់ | សមាជិក |
| ៤១. ឯកឧត្តម | ប្រាជ ចន្ទ | អភិបាលខេត្តបាត់ដំបង | សមាជិក |
| ៤២. ឯកឧត្តម | អ៊ុង អឿន | អភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL



www.elibraryofcambodia.org

៤៣.ឯកឧត្តម ប៊ុច សុខិន អភិបាលខេត្តឧត្តរមានជ័យ សមាជិក
៤៤.ឯកឧត្តម ស៊ុ ភិរិន្ទ អភិបាលខេត្ត[illegible] សមាជិក
៤៥.ឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលខេត្តព្រះវិហារ សមាជិក
៤៦.ឯកឧត្តម ឡូយ សុផាត អភិបាលខេត្តស្ទឹងត្រែង សមាជិក
៤៧.ឯកឧត្តម ប៉ាវ ហាមផាន អភិបាលខេត្តរតនគិរី សមាជិក
៤៨.ឯកឧត្តម ចាន់ យឿន អភិបាលខេត្តមណ្ឌលគិរី សមាជិក
៤៩.ឯកឧត្តម សរ ចំរុង អភិបាលខេត្តក្រចេះ សមាជិក

**មាត្រា ២.-**

គណៈកម្មាធិការនេះមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំព្រះរាជពិធីបុណ្យព្រះបរមសពឱ្យមានដំណើរការល្អ ឧត្តុង្គឧត្តមសក្តិសមនឹងព្រះគោរមងាររបស់ព្រះអង្គជាព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ
- សម្របសម្រួលការងាររៀបចំព្រះរាជពិធីបុណ្យព្រះបរមសពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំព្រះរាជពិធីទទួល និងដង្ហែព្រះបរមសព
- រៀបចំតម្កល់ព្រះបរមសព គោរពព្រះវិញ្ញាណក្ខន្ធ និងកិច្ចការពាក់ព័ន្ធផ្សេងៗ
- រៀបចំព្រះរាជពិធីបូជាព្រះបរមសពឱ្យមានដំណើរការល្អ និងឧត្តុង្គឧត្តម

**មាត្រា ៣.-**

គណៈកម្មាធិការនេះអាចបង្កើតអនុគណៈកម្មការដើម្បីបំពេញការងារ តាមការចាំបាច់។

**មាត្រា ៤.-**

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ការ.ល.១៤១០-៩៥៦

លេខ:៤៩១០.ល

[illegible]ចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែតុលា ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល

ធ្វើនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១២

[illegible] សុខា


www.elibraryofcambodia.org

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០១២៨៩

# សារាចរ

## ស្តីពី

## ការតាំងព្រះឆាយាលក្ខណ៍ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ និងព្រះឆាយាលក្ខណ៍សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ

យោងតាមច្បាប់ស្តីពីការរៀបចំព្រះបរមងារ និងព្រះរាជបុព្វសិទ្ធិ ថ្វាយអតីតព្រះមហាក្សត្រ និងព្រះរាជមហេសីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១០០៤/០០១ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤ ក្រសួង ស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជន បានតាំងព្រះឆាយាលក្ខណ៍ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ និងព្រះឆាយាលក្ខណ៍ សម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល អមជាមួយនឹងព្រះឆាយាលក្ខណ៍ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា រហូតមកទល់បច្ចុប្បន្ន ។

នៅថ្ងៃទី១៥រោជ ខែកត្រុបទ ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ អតីតព្រះមហាក្សត្រ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះអង្គបានយាងចូលទិវង្គត រាជរដ្ឋាភិបាលសូមធ្វើការណែនាំឱ្យរក្សាការតាំងព្រះឆាយាលក្ខណ៍ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ និងព្រះឆាយាលក្ខណ៍ សម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល អមជាមួយនឹងព្រះឆាយាលក្ខណ៍ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅតាមក្រសួង ស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជន ដូចដែលធ្លាប់បានអនុវត្តកន្លងមក ។



www.elibraryofcambodia.org

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ និងរដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់ចែងផ្សព្វផ្សាយនិងអនុវត្តឱ្យមានប្រសិទ្ធភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ៩ ៧ ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.elibraryofcambodia.org

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ០៣ សរ

# សារាចរ

## ស្តីពី

## ការប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ
## ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ
## ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ

ដោយព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា **ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** មានគុណូបការៈដ៏ថ្លៃថ្លា វិសេសវិសាល និងឧត្តុង្គឧត្តម ចំពោះជាតិមាតុភូមិ ដែលក្នុងមួយជីវិតរបស់ព្រះអង្គ ព្រះអង្គបានលះបង់ទាំងព្រះកាយពល និង ព្រះបញ្ញាញាណ ដើម្បីបុព្វហេតុឯករាជ្យជាតិ បូរណភាពទឹកដី ការបង្រួបបង្រួមជាតិ សាសនា សេរីភាព សមភាព សមធម៌ យុត្តិធម៌ មនុស្សធម៌ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ជាពិសេសព្រះរាជវីរសកម្មភាពដ៏ច្រើនរបស់ព្រះអង្គ ដែលធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាទទួលបានឯករាជ្យ បូរណភាពទឹកដី ឯកភាពជាតិ អព្យាក្រឹតភាព និងកិត្យានុភាពដ៏ល្បីល្បាញនៅលើសកលលោក និងដោយយោង តាមអនុក្រឹត្យលេខ១៨៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១៣ រាជរដ្ឋាភិបាលកំណត់យកថ្ងៃទី១៥ ខែតុលា ជាទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** និងសូមធ្វើការណែនាំដូចតទៅ ៖

១. គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងឯកជន ត្រូវរៀបចំទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ១៥តុលា ឱ្យបានឧត្តុង្គឧត្តម សក្តិសមនឹងព្រះគុណូបការៈរបស់ព្រះអង្គចំពោះជាតិមាតុភូមិ និងប្រជាជន តាមទំនៀមទម្លាប់ប្រពៃណីជាតិខ្មែរ។



www.elibraryofcambodia.org

២. គ្រប់ស្ថានអគ្គរាជទូត និងស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេសត្រូវរៀបចំប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធនេះឱ្យបានសក្តិសមនឹងកិត្យានុភាពនិង[illegible] ឆាកអន្តរជាតិ។

៣. រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ រួមមាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវរៀបចំប្រារព្ធពិធីនេះ ឱ្យបានទូលំទូលាយ និងសមស្របតាមព្រះបរមរាជបំណងរបស់ព្រះអង្គជា ព្រះវររាជបិតាឯកភាពជាតិខ្មែរ។

៤. គ្រប់វត្តអារាម បូជនីយដ្ឋានសាសនា អាស្រមបែបសួនា និង[illegible] ត្រូវរៀបចំប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ ឱ្យបានវិសេសវិសាលថ្លៃថ្លាសក្តិសមនឹងសេចក្តីគោរពស្រឡាញ់ ដែលផុសចេញពីបេះដូងរបស់ប្រជារាស្ត្រខ្មែរគ្រប់រូប ទៅតាមលទ្ធភាព។

៥. ក្រសួងព័ត៌មាន ត្រូវចាត់តាំងរៀបចំកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ជាតិ-ឯកជន អំពីព្រះរាជជីវប្រវត្តិ ព្រះរាជសកម្មភាព និងស្នាព្រះហស្តរបស់សម្តេច ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ជាទីសក្ការៈ ចំពោះប្រទេសជាតិ និងចំពោះ ប្រជារាស្ត្រ ឱ្យបានទូលំទូលាយ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ និងរដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់ចែងផ្សព្វផ្សាយនិងអនុវត្តឱ្យមានប្រសិទ្ធភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ


www.elibraryofcambodia.org

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០១ សរ.ណ

**សារាចរ**

**ស្តីពី**

**ការផ្អាកការប្រារព្ធពិធីបុណ្យអុំទូក**

**បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ឆ្នាំ ២០១២ នៅរាជធានីភ្នំពេញ**

អនុវត្តតាមសារាចរណែនាំលេខ០៩ សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទូទាំងប្រទេស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ បុណ្យអន្តរជាតិ ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលតែងតែប្រារព្ធពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុកចំនួន៣ថ្ងៃ ដើម្បីអបអរសាទរព្រះរាជពិធីបុណ្យប្រពៃណីជាតិ និងបន្តរក្សាទំនៀមទម្លាប់ដ៏ប្រពៃរបស់ប្រជាពលរដ្ឋកម្ពុជាដែលមានតាំងពីយូរលង់មកហើយ។ ក្នុងឱកាសដ៏មហោឡារិកនេះ រាជរដ្ឋាភិបាលបានរៀបចំពិធីប្រណាំងទូកង បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅតាមដងទន្លេសាប មុខព្រះបរមរាជវាំង រាជធានីភ្នំពេញ និងដោយឡែកនៅតាមបណ្តាខេត្ត និងស្រុកមួយចំនួនក៏បានរៀបចំពិធីនេះផងដែរ។

នៅក្នុងអំឡុងពេលនៃការប្រារព្ធពិធីបុណ្យនាឆ្នាំនេះ រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋទូទាំងប្រទេសកំពុងមានមហាទុក្ខសោកដ៏សែនក្រៀមក្រំរកទីបំផុតគ្មាន ដោយ **ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ព្រះអង្គបានយាងចូលទិវង្គត នាថ្ងៃទី១៥រោច ខែភទ្របទ ឆ្នាំរោង ចត្វាស័ក ព.ស២៥៥៦ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង ១:២០នាទីរំលងអធ្រាត (ម៉ោងនៅរាជធានីភ្នំពេញ) ក្នុងព្រះជន្មាយុ ៩០ព្រះវស្សា ដោយព្រះជរាពាធ ហើយព្រះបរមសពនឹងត្រូវតម្កល់នៅក្នុងព្រះបរមរាជវាំងក្នុងរយៈពេលមិនតិចជាង៣ខែ ដើម្បីប្រារព្ធព្រះរាជពិធីបុណ្យឱ្យបានឧត្តុង្គឧត្តមតាមប្រពៃណីជាតិ។

ដើម្បីចូលរួមការទុក្ខ និងគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះអតីតអង្គព្រះមហាក្សត្រខ្មែរ** រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ៖



www.elibraryofcambodia.org

១. ផ្អាកការរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅតាមដងទន្លេសាប មុខព្រះបរមរាជវាំង រាជធានីភ្នំពេញ ដែលគ្រោងនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៧ ទី២៨ និងទី២៩ ខែវិច្ឆិកា ឆ្នាំ២០១២។

២. ការរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅតាមទីកន្លែងដទៃទៀតអាចប្រព្រឹត្តទៅជាធម្មតា តាមទំនៀមទម្លាប់ប្រពៃណី និងតាមលទ្ធភាពរបស់ប្រជាពលរដ្ឋ។

៣. ការឈប់សម្រាករបស់មន្ត្រីរាជការ និយោជិត កម្មករ ចំនួន ៣ថ្ងៃ ក្នុងព្រះរាជពិធីនេះ នៅតែក្សាដដែល ដូចខ្លឹមសារដែលមានចែងក្នុងអនុក្រឹត្យលេខ២៣១ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១២។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ និងរាជធានីខេត្ត ត្រូវចាត់ចែងផ្សព្វផ្សាយនិងអនុវត្តឱ្យមានប្រសិទ្ធភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅភ្នំពេញ ថ្ងៃទី [illegible] ខែតុលា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.elibraryofcambodia.org

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០១.សរ.

# សារាចរ

## ស្តីពី

## ព្រះរាជពិធីដង្ហែនិងថ្វាយព្រះភ្លើងព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ

ដើម្បីឱ្យព្រះរាជពិធីដង្ហែនិងថ្វាយព្រះភ្លើងព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ **ព្រះបរមរតនកោដ្ឋ** ប្រព្រឹត្តទៅប្រកបដោយភាពវិសេសវិសាល និងឧឡារិកឧត្តម រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅៈ

១. ប្រកាសថ្ងៃកាន់មរណៈទុក្ខ គោរពព្រះវិញ្ញាណក្ខន្ធជាផ្លូវការលើកទី២ រយៈពេល៧ថ្ងៃ ចាប់ពីថ្ងៃសុក្រ ៦រោច ខែបុស្ស ឆ្នាំរោង ចត្វាស័ក ព.ស ២៥៥៦ ត្រូវនឹងថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៣ ដល់ថ្ងៃព្រហស្បតិ៍ ១២រោច ខែបុស្ស ឆ្នាំរោង ចត្វាស័ក ព.ស ២៥៥៦ ត្រូវនឹងថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣។

២. គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងឯកជន ព្រមទាំងប្រជាពលរដ្ឋទូទាំងប្រទេស ត្រូវបង្ហូតទង់ជាតិត្រឹមមួយភាគបីនៃដងចាប់ពីលើ និងត្រូវតុបតែងសញ្ញាកាន់មរណៈទុក្ខលើព្រះឆាយាលក្ខណ៍ ហើយប្រជាពលរដ្ឋគ្រប់រូបត្រូវពាក់សញ្ញាកាន់មរណៈទុក្ខក្នុងរយៈពេលកាន់មរណៈទុក្ខនេះ។

៣. គ្រប់ស្ថានីយវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ព្រមទាំងកន្លែងកំសាន្តសប្បាយ ត្រូវផ្អាកការផ្សាយនូវទស្សនីយភាព ការសម្តែង និងការប្រគុំតន្ត្រីផ្សេងៗ ដែលមានលក្ខណៈសប្បាយគ្រឹកគ្រេង ក្នុងរយៈពេល៧ថ្ងៃនេះ។

៤. មន្ត្រីរាជការទាំងអស់ត្រូវបានឈប់សម្រាកពីការងារនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលជាថ្ងៃព្រះរាជពិធីដង្ហែព្រះបរមសព និងនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលជាថ្ងៃថ្វាយព្រះភ្លើងព្រះបរមសព។

៥. គ្រប់គ្រឹះស្ថានសាធារណៈ និងឯកជន អគារពាណិជ្ជកម្ម និងអាជីវកម្មគ្រប់ប្រភេទស្ថិតនៅតាមដងវិថី និងមហាវិថី ដែលត្រូវដង្ហែក្បួនព្រះបរមសព ត្រូវផ្អាកសកម្មភាពការងារ និងអាជីវកម្មរបស់ខ្លួននៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៣។

៦. គ្រប់វត្តអារាម បុជនីយដ្ឋានសាសនា និងអាស្រមវិបស្សនា ត្រូវរៀបចំពិធីគោរពព្រះវិញ្ញាណក្ខន្ធ ឱ្យបានវិសេសវិសាល សក្តិសម នឹងសេចក្តីគោរពស្រឡាញ់ ដែលផុសចេញពីក្រអឺតក្រទម (ក្រឡៅបេះដូង) ដោយរៀបចំនិមន្តព្រះសង្ឃ សូត្រមន្ត បង្សុកូល និងទូងស្គរ វាយគង-ឃ្មោះ នៅពេលចាប់ផ្តើមព្រះរាជពិធីដង្ហែព្រះបរមសព ចេញពីព្រះបរមរាជវាំង ពេលព្រះបរមសពយាងដល់ទីលានវាលព្រះមេរុ និងពេលថ្វាយព្រះភ្លើងព្រះបរមសព ទៅតាមព្រះរាជកម្មវិធី។





www.elibraryofcambodia.org

៧. ក្នុងព្រះរាជពិធីដង្ហែនិងថ្វាយព្រះភ្លើងព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ **ព្រះបរមរតនកោដ្ឋ** នឹងមានការបាញ់កាំភ្លើងធំ១០១ណាត់ ចំនួន៣លើកគឺ លើកទីមួយនឹងប្រព្រឹត្តទៅនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៣ នៅពេលដែលព្រះបរមសពត្រូវដង្ហែចេញពីព្រះបរមរាជវាំង និងលើកទីពីរប្រព្រឹត្តទៅនៅពេលដែលព្រះបរមសពដង្ហែដល់ទីលានវាលព្រះមេរុ។ ការបាញ់លើកទីបី នឹងប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៣ នៅពេលប្រារព្ធព្រះរាជពិធីថ្វាយព្រះភ្លើង។

៨. ក្នុងព្រះរាជពិធីដង្ហែនិងថ្វាយព្រះភ្លើងព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ **ព្រះបរមរតនកោដ្ឋ** នឹងមានការរៀបចំបាញ់កាំជ្រួច ទៅតាមព្រះរាជកម្មវិធីបុណ្យ។

៩. ក្បួនដង្ហែព្រះបរមសពអាចនឹងមានប្រវែងប្រមាណ ១.៥គីឡូម៉ែត្រ ទៅ២គីឡូម៉ែត្រ ដែលត្រូវដង្ហែតាមវិថី នឹងមហាវិថីចំងាយ៦គីឡូម៉ែត្រ។ ក្នុងព្រះរាជពិធីដង្ហែព្រះបរមសព នឹងមានបំពាក់ឧបករណ៍ឃោសនាសំឡេង នៅតាមបណ្តោយវិថី និងមហាវិថី ដែលត្រូវដង្ហែព្រះបរមសព ដើម្បីងាយស្រួលផ្តល់ការណែនាំ និងជូនព័ត៌មានដល់មហាជនទូទៅ។ អាស្រ័យហេតុនេះ ប្រជាពលរដ្ឋ ដែលចូលរួមក្នុងព្រះរាជពិធីដង្ហែព្រះបរមសព ត្រូវយកចិត្តទុកដាក់ស្តាប់ គោរពតាមការណែនាំ របស់អ្នកចាត់ចែងព្រះរាជពិធីបុណ្យឱ្យបានម៉ឺងម៉ាត់។ ជាងនេះទៅទៀត ព្រះរាជពិធីដង្ហែនិងថ្វាយព្រះភ្លើងព្រះបរមសព នឹងត្រូវ បានផ្សាយបន្តផ្ទាល់នៅលើកញ្ចក់ទូរទស្សន៍ LED ខ្នាតធំ ទំហំ 2m x 3m នៅតាមទីតាំងសំខាន់ៗ ដូចជា៖

- ចំណតរថយន្តពហុកីឡាដ្ឋានជាតិអូឡាំពិក
- ចំណតឡានចោមចៅ មុខផ្សារចោមចៅ
- សួនក្នុងបរិវេណមហោស្រពចេនឡា
- លំហរទល់មុខផ្សារស៊ិនជូវិថីផ្លូវសាពោធិចិនតុង
- ចំណតឡានផ្ទេរទំនិញក្បាលថ្នល់
- ចំណតឡានវាលស្បូវរបស់ក្រុមហ៊ុនផានអ៊ីម៉ិច
- អតីតចំណតឡានព្រែកលាភរបស់ក្រុមហ៊ុនផានអ៊ីម៉ិច
- បរិវេណខាងក្នុងរមណីយដ្ឋានចំការព្រីងជិតវត្តសំពៅងអណ្តែត
- ទីវាលទីក្រុងកោះពេជ្រ
- ទីលានប្រជាធិបតេយ្យ
- សួនច្បារផ្សារចាស់
- លើសួនច្បារស្តុតម៉ិចផ្លូវជាតិលេខ៥
- សួនច្បាក្រុងតាខ្មៅ
- មុខសាលមហោស្រពចតុមុខ

១០. ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងសាលារាជធានីភ្នំពេញ ត្រូវបង្កើនការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាព ជូនប្រជាពលរដ្ឋចូលរួមក្នុងព្រះរាជពិធីបុណ្យនេះ ឱ្យបានល្អប្រសើរ។

១១. អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស ក្រសួងព័ត៌មាន គ្រប់ស្ថានីយវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ត្រូវផ្សព្វផ្សាយអំពីព្រះរាជកម្មវិធីបុណ្យ ពិធីដង្ហែនិងថ្វាយព្រះភ្លើងព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ **ព្រះបរមរតនកោដ្ឋ** ឱ្យបានទូលំទូលាយ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត និងគ្រឹះស្ថានសាធារណៈ និងឯកជន ត្រូវចាត់ចែងផ្សព្វផ្សាយសារាចរនេះឱ្យមានប្រសិទ្ធភាពដោយយកចិត្តទុកដាក់ទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមករា ឆ្នាំ២០១៣

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**



www.elibraryofcambodia.org

**សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (សទទក)**

CAMBODIA ASSOCIATION OF TRAVEL AGENTS (CATA)

លេខ ៖ ៧-០២០/១២

**សូមក្រាបបង្គំទូលថ្វាយ**

**សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ**

**ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**

**និង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

បពិត្រ **អង្គសម្តេចម៉ែ** ជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

បពិត្រ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ** ជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងនាមសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា(CATA) និងក្នុងនាមទូលព្រះបង្គំបាទ មានសេចក្តីតក់ស្លុតក្តុកក្តួលរន្ធត់ចិត្តរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយចាប់តាំងពីពេលដែលបានទទួលដំណឹងដ៏សែនក្រៀមក្រំបំផុតថា **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ព្រះអង្គទ្រង់បានយាងចូលទីវង្គត នាថ្ងៃទី១៥រោច ខែភទ្របទ ឆ្នាំរោង ចត្វាស័ក ពុទ្ធសករាជ ២៥៥៦ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង០១និង២០នាទី រំលងអាធ្រាត្រ (ម៉ោងនៅកម្ពុជា) ក្នុងព្រះជន្មាយុ ៩០ព្រះវស្សា ដោយព្រះជរាពាធ នៅសាធារណរដ្ឋប្រជាមានិតចិន។

នាឱកាសដ៏សែនព្រះវិយោគនេះ ទូលព្រះបង្គំជាខ្ញុំសូមបរមរាជានុញ្ញាតសម្តែងនូវក្តីកតញ្ញូកតវេទិតានិងសមានចិត្តដ៏មហាសែនក្តុកក្តួលរំជួលចិត្ត ចូលរួមរំលែកនូវព្រះរាជមរណទុក្ខដ៏មហាក្រៀមក្រំក្រៃបំផុតគ្មានទំពោះការបាត់ព្រះជន្មលាចាកប្រជាជាតិខ្មែរ ទៅកាន់បរលោកនៃ **អង្គព្រះមហាវីរក្សត្រ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ជាទីគោរពសក្ការៈនៃយើង ។ ទ្រង់ពិតជាអង្គក្សត្រប្រកបដោយទសពិធរាជធម៌ មិនមានអង្គក្សត្រក្រោយសម័យអង្គរអង្គណាមានព្រះទេពកោសល្យ និងស្នាព្រះហស្តប្រៀបស្មើបានឡើយ ។ មហាសមិទ្ធិផលជាស្នាព្រះហស្ត និងព្រះកិត្តិវីរភាពដ៏ជំនត្តុង្គឧត្តមរបស់ **អង្គសម្តេចព្រះវររាជបិតាជាតិ** នឹងចារឹកជាប់ជានិច្ចក្នុងក្រអៅបេះដូងរបស់កុលបុត្រកុលធីតាខ្មែរគ្រប់រូប និងបានក្លាយជាគោលមាគ៌ាស្នេហាជាតិដ៏ខ្ពង់ខ្ពស់សម្រាប់ខេមរជនទុកប្រតិបត្តិតាមគ្រប់ៗគ្នាអស់កាលជាអមតៈតទៅ ។

ជាទីអវសាននេះ ទូលព្រះបង្គំជាខ្ញុំ សូមតាំងនិក្ខាយរាជាចិត្តឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយទ្រទ្រង់ដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** ទ្រង់យាងចាប់បដិសន្ធិក្នុងព្រះបរមសុគតិភពជាបរាបរៀងទៅកុំបីឃ្លៀងឃ្លាតឡើយ ។

សូម **អង្គសម្តេចម៉ែ** និង **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈ សូមទ្រង់ព្រះមេត្តាប្រោសទទួលនូវសេចក្តីកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ។

ក្រាបបង្គំទូលថ្វាយ រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ តុលា ឆ្នាំ២០១២

ប្រធាន

**អេង គីមអៀង**



www.elibraryofcambodia.org

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ**
**នរោត្តម សីហមុនី**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

ជូន លោក **អាង គីមអៀង**
ប្រធានសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា
( សទទក )

លោក ជាទីរាប់អាន

ខ្ញុំ បានទទួលរួចហើយ នូវលិខិតរបស់លោក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១២ ដែលមានអត្ថន័យ ដ៏ជ្រាលជ្រៅ ចូលរួមមរណទុក្ខដ៏ក្រៀមក្រំ ចំពោះ **ព្រះករុណាព្រះមហាវីរក្សត្រ នរោត្តម សីហនុ ព្រះបរមរាជបិតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គ បានយាងចូលព្រះទិវង្គត កាលពីថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១២ នេះ ។

ខ្ញុំ សូមអរគុណដ៏ជ្រាលជ្រៅ ចំពោះ លោក ដែលបានរំលឹកព្រះរាជគុណូបការៈដ៏ធំធេង របស់ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះបរមរាជបិតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គ បានបំពេញ ព្រះរាជកិច្ចដ៏ឧត្តុង្គឧត្តម ជាគុណប្រយោជន៍ដ៏ថ្លៃថ្លា ជូនជាតិ មាតុភូមិកម្ពុជាយើង ។

ខ្ញុំ សូមជូនពរ លោក និងបុគ្គលិកសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា ( សទទក ) បានប្រកបតែនឹង ព្រះពុទ្ធពរ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម លោក ទទួលនូវសេចក្តីរាប់អាន អំពីខ្ញុំ ។

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១២



www.elibraryofcambodia.org







www.elibraryofcambodia.org







www.elibraryofcambodia.org




www.elibraryofcambodia.org

**រៀបរៀង និងចងក្រងដោយ ៖**

លោក អាង គីមអៀង
ប្រធានទីភ្នាក់ងារទេសចរណ៍ Great Angkor Tours
និង
លោក គី សុខលីម
នាយកគ្រប់គ្រងសេវាកម្មផលិតឯកសារគ្រប់ប្រភេទ HDS
និងជាសមាជិកគណៈកម្មាធិការនាយកនៃក្លិបអ្នកកាសែតកម្ពុជា

**ជំនួយការរៀបរៀង និងចងក្រងដោយ ៖**

លោក អ៊ឹង ចំរើន
និពន្ធនាយកគេហទំព័រព័ត៌មាន www.thmeythmey.com

លោក ប៉ែន បូណា
សាស្ត្រាចារ្យសារព័ត៌មាន

លោក ណាង ជីលុច
អ្នកឆ្លងឆ្លើយព័ត៌មាននៃវិទ្យុបារាំងអន្តរជាតិ

រចនាទំព័រដោយ ៖ លោក គង់ សំបូរ

រូបថត ៖ លោក ស៊ុំ ចាន់ណា

រូបភាពមួយចំនួនផ្សេងទៀតបានដកស្រង់ពី៖
www.norodomsihanouk.info
www.norodomsihamoni.org
www.pressocm.gov.kh
និងគេហទំព័រផ្សេងៗទៀត

អ្នកកែសម្រួលអក្ខរាវិរុទ្ធ ៖ លោក ម៉ី សុមុនី និង លោក អាង គីមអៀង

អ្នកផ្តល់ប្រឹក្សា ៖ លោក Pierre Gillette ( ព្យែរ ហ្ស៊ីល្វែត )
អតីតនិពន្ធនាយកកាសែតបារាំង Cambodge Soir

លោក អាង គីមអៀង និង លោក គី សុខលីម ជាសហកម្មសិទ្ធិនៃសៀវភៅនេះ
ទូរស័ព្ទ ៖ (+៨៥៥) ១៧ ៣២៨ ៣៣៣ | (+៨៥៥) ១២ ៨៦២ ៥០៩
អ៊ីម៉ែល ៖ angkimeang@gmail.com | soklimky@yahoo.com

បោះពុម្ពលើកទី១ ចំនួន៥០០០ក្បាល

រក្សាសិទ្ធិគ្រប់យ៉ាង
ឆ្នាំ ២០១៣

បោះពុម្ពដោយ ៖ រោងពុម្ព ពន្លឺខ្មែរ



www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេនជា eBook ដោយ សៀង ស៊ីវ៉ាន់
ខែឧសភា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្មៅ យុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

# លាហើយកម្ពុជា !

## Goodbye Cambodia !

ព្រះរាជនិពន្ធ និង ព្រះសូរសៀង:
ព្រះករុណាព្រះបាទសម្តេចព្រះមហាវីរក្សត្រ **នរោត្តម សីហនុ**



I. លាហើយ កម្ពុជាអើយ
សូមលាដោយអាឡោះអាល័យ
ចិត្តខ្ញុំ រៀងរាបរាល់ថ្ងៃ សុំភ្ជាប់និស្ស័យ
នឹងអ្នកហើយៗ

II. ពេលមុន យើងធ្លាប់រួមរស់
រួមទុក្ខរួមសុខជាមួយគ្នា
ឥឡូវ ទោះបីយ៉ាងណា ខ្ញុំសូមសច្ចា
ស្មោះត្រង់នឹងអ្នកៗ

R- នៅឆ្ងាយ ខ្ញុំគ្មានណាយ
ចំពោះខ្លួនអ្នកសោះឡើយ
ស្នេហា ខ្ញុំគ្មានស្បើយ ព្រោះអ្នកជា
មាតុភូមិខ្ញុំៗ

III. លុះត្រា ខ្ញុំក្ស័យជីវា ខ្ញុំសុំបម្រើការពារអ្នក
បម្រើ ដោយសែនស្មោះស្ម័គ្រ រួមរក្សនឹងអ្នក
លុះអវសានៗ

www.elibraryofcambodia.org